00633990

D417/2/3

**នៅចំពោះមុខ អង្គបុរេជំនុំជម្រះ**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អបជ ៧៤)

ភាគីដាក់ឯកសារ: សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី

ដាក់ជូន: អង្គបុរេជំនុំជម្រះ

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១០

| |
|---|
| **ឯកសារទទួល** |
| DOCUMENT RECEIVED/DOCUMENT REÇU |
| ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 04 / 01 / 2011 |
| ម៉ោង (Time/Heure): 15:20 |
| មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Ratanak |

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សម្ងាត់

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះ: ~~សម្ងាត់ / Confidential / Confidentiel~~

ស្ថានភាពនៃចំណាត់ថ្នាក់ឯកសារ: សាធារណៈ / Public

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះ

អាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចស្តីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលមានអាសយដ្ឋាននៅខេត្តកំពង់ឆ្នាំង (D417)**

---

__ដាក់ដោយ__៖

**សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក នី ច័ន្ទឌី

លោកស្រី Lyma NGUYEN

**មេធាវីតំណាងភាគីដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ហុង គីមសួន

លោក ឡោ ជុនធី

__ផ្ញើជូន__៖

**អង្គបុរេជំនុំជម្រះ**

ចៅក្រម ប្រាក់ គីមសាន

ចៅក្រម ន័យ ធុល

ចៅក្រម ហួត វុទ្ធី

ចៅក្រម Catherine MARCHI-UHEL

ចៅក្រម Rowan DOWNING

លោក វ៉ែន ពៅ

លោក គង់ ពិសី

លោក យ៉ុង ផានិត

លោកស្រី ស៊ិន សុវ៉ន

លោក គីម ម៉េងឃី

លោកស្រី ម៉ុច សុវណ្ណារី

លោកស្រី ជេត វណ្ណលី

លោក ពេជ អង្គ

លោកស្រី Silke STUDZINSKY

លោក Olivier BAHOUGNE

លោក Mahdev MOHAN

លោក Ferdinand DJAMMEN-NZEPA

លោក Patrick BAUDOIN

លោកស្រី Fabienne TRUSSES-NAPROUS

លោក Phillipe CANONNE

លោកស្រី Elizabeth RABESANDRATANA

លោកស្រី Annie DELAHAIE

លោកស្រី Marie GUIRAUD

លោកស្រី Christine MARTINEAU

លោកស្រី Francoise GAUTRY

លោកស្រី Laure DESFORGES

លោកស្រី Isabelle DURAND

លោក Emmanuel ALTIT

លោក Emmanuel JACOMY

លោក Barnabe NEKUIE

លោក Daniel LOSQ

លោក Julien RIVET

លោក Pascal Aubion

**សហមេធាវីការពារក្តីជនត្រូវចោទ៖**

**អៀង សារី**

លោក អាង ឧត្តម

លោក Michael G. KARNAVAS

**អៀង ធីរិទ្ធ**

លោក ផាត់ ពៅស៊ាង

លោកស្រី Diana ELLIS

**នួន ជា**

លោក សុន អរុណ

លោក Michiel PESTMAN

លោក Victor KOPPE

**ខៀវ សំផន**

លោក ស សុវាន

លោក Jacques VERGES

**កាំង ហ្គេកអ៊ាវ ហៅ ឌុច**

លោក ការ សាវុត្ថ

លោក កង ឫទ្ធារី

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Andrew T. CAYLEY

លោកស្រី Martine JACQUIN

00633993

# I. ប្រវត្តិនីតិវិធី និងសេចក្តីផ្តើម

១. នៅថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១០ សហចៅក្រមស៊ើបអង្កេត *("ស.ច.ស")* បានចេញ "ដីកាសម្រេចស្តីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលមានអាសយដ្ឋាននៅខេត្តកំពង់ឆ្នាំង" (**ដីកាសម្រេចខេត្តកំពង់ឆ្នាំង**)[1]។ នៅថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១០ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានទទួលការជូនដំណឹងអំពីដីកាសម្រេចខេត្តកំពង់ឆ្នាំងនេះ។

២. នៅក្នុងដីកាសម្រេចនេះ សហចៅក្រមស៊ើបអង្កេតបានប្រកាសមិនទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន ២៥ ដែលមានលេខសម្គាល់ D22/1901, D22/3180, D22/3183, D22/2057, D22/2154, D22/438, D22/3179, D22/3182, D22/816, D22/3177, D22/2157, D22/3181, D22/817, D22/2155, D22/2153, D22/404, D22/2156, D22/1136, D22/1969, D22/3175, D22/3176, D22/3178, D22/2158, D22/1092, និង D22/2758។

៣. ឧបសម្ព័ន្ធ១ នៃដីកាសម្រេចខេត្តកំពង់ឆ្នាំងកំណត់ថា អ្នកដាក់ពាក្យសុំ D22/1901 ត្រូវបានតំណាងតែដោយសហមេធាវីជាតិមួយរូបប៉ុណ្ណោះគឺលោក នី ច័ន្ទឌី។ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីអន្តរជាតិ លោកស្រី Lyma NGUYEN ធ្វើការបញ្ជាក់បន្ថែមថា លោកស្រីក៏តំណាងឱ្យអ្នកដាក់ពាក្យសុំ D22/1901 ដែរដោយគាត់មានលិខិតប្រគល់សិទ្ធិដោយអាណត្តិជាភស្តុតាង ហើយលិខិតនេះ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១០ និងត្រូវបានចុះហត្ថលេខាដោយលោកស្រីផ្ទាល់ លោក នី ច័ន្ទឌី និងកូនក្តី ដែលជាអ្នកដាក់ពាក្យសុំ D22/1901 និងបានដាក់ជូនយ៉ាងត្រឹមត្រូវទៅឱ្យអង្គភាពគាំពារជនរងគ្រោះ នៅថ្ងៃទី៣ ខែសីហា ឆ្នាំ២០១០។ ច្បាប់ថតចម្លងនៃលិខិតប្រគល់សិទ្ធិដោយអាណត្តិនេះ មានភ្ជាប់នៅក្នុង**ឧបសម្ព័ន្ធ ក**។

៤. នៅក្នុងចំណោមអ្នកដាក់ពាក្យសុំទាំង២៥ ដែលត្រូវបានបដិសេធមិនទទួលយកក្នុងដីកាសម្រេចខេត្តកំពង់ឆ្នាំង មានកូនក្តីចំនួន៤នាក់ ដែលមានលេខសម្គាល់ D22/2156, D22/2154,

[1] ក.ស.ច.ស "ដីកាសម្រេចស្តីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលមានអាសយដ្ឋាននៅក្នុងខេត្តកំពង់ឆ្នាំង ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១០ ឯកសារលេខ D417 (ចាប់ពីនេះតទៅហៅថា ដីកាសម្រេចខេត្តកំពង់ឆ្នាំង)។

D22/1203 និង D22/2057 ត្រូវបានចាត់តាំងឱ្យមានតំណាងដោយសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី តាមរយៈដីកាសម្រេចរបស់ ស.ច.ស នៅថ្ងៃទី២ ខែសីហា ឆ្នាំ២០១០[2]។

៥. ក្នុងចំណោមអ្នកដាក់ពាក្យសុំទាំង២៥នាក់ដែលការទាមទាររបស់ពួកគេមិនត្រូវបានទទួលយកនោះ មានម្នាក់ជាជនជាតិខ្មែរ។ អ្នកដាក់ពាក្យ ២៤ នាក់ផ្សេងទៀតគឺជាជនជាតិភាគតិចវៀតណាម។ ព័ត៌មានដែលប្រមូលបានពីអង្គភាពគាំពារជនរងគ្រោះ ក្រុមមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីផ្សេងទៀត គណៈកម្មាធិការប្រព្រឹត្តកម្មនៃអង្គការសមាគមការពារសិទ្ធិមនុស្សកម្ពុជា និងអង្គការមិនមែនរដ្ឋាភិបាលដែលជាអន្តរការីមួយចំនួនទៀត ដូចជា មជ្ឈមណ្ឌលឯកសារកម្ពុជា (DC-Cam), ADHOC និង KID បង្ហាញថា អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីមកពីខេត្តកំពង់ឆ្នាំងទាំងនេះ គឺជាក្រុមអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងប្រទេសកម្ពុជាជាជនជាតិភាគតិចវៀតណាមតែមួយក្រុមគត់។

៦. ក្នុងបណ្តឹងឧទ្ធរណ៍នេះ សេចក្តីសន្និដ្ឋានទាក់ទងនឹងម្ចាស់បណ្តឹងឧទ្ធរណ៍ ដែលជាជនជាតិភាគតិចវៀតណាមទាំង ២៤នាក់ នឹងត្រូវធ្វើឡើងជាបណ្តឹងឧទ្ធរណ៍ក្រុមរួមគ្នាមួយ ពីព្រោះម្ចាស់បណ្តឹងឧទ្ធរណ៍ជនជាតិវៀតណាមទាំងអស់នេះលើកឡើងអង្គហេតុប្រហាក់ប្រហែលគ្នា និងមានសេចក្តីសន្និដ្ឋានអង្គច្បាប់ដូចគ្នាបេះបិទ។ បណ្តឹងឧទ្ធរណ៍នេះនឹងធ្វើសេចក្តីសន្និដ្ឋានដោយឡែកមួយសម្រាប់ម្ចាស់បណ្តឹងឧទ្ធរណ៍ជាជនជាតិខ្មែររូបនេះដោយចាប់ផ្តើមពីកថាខណ្ឌ ៦៩ ដល់កថាខណ្ឌ ៧៨ក្នុងបណ្តឹងនេះ។ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីស្នើសុំឱ្យអង្គបុរេជំនុំជម្រះ (អ.ប.ជ) បដិសេធការសម្រេចរបស់ ស.ច.សក្នុងដីកាសម្រេចខេត្តកំពង់ឆ្នាំង និងប្រកាសទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាំង ២៥រូប ដូចរៀបរាប់ខាងលើ។

## II. ច្បាប់ និងវិធានជាធរមាន

៧. ច្បាប់ និងវិធានពាក់ព័ន្ធដែលបណ្តឹងឧទ្ធរណ៍នេះបានយោងនោះគឺ វិធាន២១ វិធាន២៣ (*"IR"*) (វិសោធនកម្មលើកទី៣) វិធាន២៣*ស្ទួន* វិធាន៥៥ វិធាន៧៧*ស្ទួន* វិធាន១១៤ (វិសោធនកម្មលើក

[2] ក.ស.ច.ស "Ordonnance portant organisation de la représentation des parties civiles en application de la règle 23 *ter* du Règlement" ចុះថ្ងៃទី២ ខែសីហា ឆ្នាំ២០១០ ឯកសារលេខ D337/10។

ទី៥) មាត្រា១៣ នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា[3] មាត្រា ១៤ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ[4] (*"ICCPR"*)។

## III. បទដ្ឋាននៃបណ្តឹងឧទ្ធរណ៍

៨. វិធាន៧៧*ស្ទួន* នៃវិធានផ្ទៃក្នុង គឺជាវិធានពិសេសមួយសម្រាប់ការធ្វើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចអំពីការទទួលយករបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត *("ក.ស.ច.ស")* និងត្រូវបានអនុម័តកាលពីថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០១០ ថ្មីៗនេះ។ យោងតាមវិធាន ១១៤(៣) នៃវិធានផ្ទៃក្នុង វិសោធនកម្មអំពីការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីបានយកមកអនុវត្តលើរឿងក្តីដែលដីកាដំណោះស្រាយនៃរឿងក្តីនោះមិនទាន់បានដាក់ចេញនៅឡើយខណៈពេលអនុម័តវិធាននោះ។

៩. បទបញ្ញត្តិពិសេសសម្រាប់បណ្តឹងឧទ្ធរណ៍លើការទទួលយក បានកំណត់យ៉ាងជិតដល់បំផុតអំពីបទដ្ឋាននៃបណ្តឹងឧទ្ធរណ៍។

១០. ជាងនេះទៀត យោងតាមវិធាន ៧៧ *ស្ទួន*(២)នៃវិធានផ្ទៃក្នុង ម្ចាស់បណ្តឹងឧទ្ធរណ៍ត្រូវបានអនុញ្ញាតឱ្យដាក់ "ឯកសារគាំទ្រ" ក្នុងបណ្តឹងឧទ្ធរណ៍ស្តីពីភាពអាចទទួលយកបាន ទៅអង្គបុរេជំនុំជម្រះ។ ពាក្យថា "ឯកសារគាំទ្រ" មិនត្រូវបានកំណត់ន័យ និងអាចចាត់ទុកថាជា (i) ឯកសារបន្ថែម ដោយរាប់បញ្ចូលទាំងអង្គហេតុថ្មី ដែលគាំទ្រដល់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និង/ឬ (ii) ឯកសារទាំងឡាយណា ដែលជួយពង្រឹងដល់អង្គហេតុដែលបានដាក់រួចហើយ។

---

[3] កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទិននឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ នៅគេហទំព័រ http://www.eccc.gov.kh/english/cabinet/agreement/5/Agreement_between_UN_and_RGC.pdf

[4] ត្រូវបានអនុម័ត និងបើកចំហ សម្រាប់ការចុះហត្ថលេខា ការផ្តល់សច្ចាប័ន និងការចូលរួម ដោយសេចក្តីសម្រេចរបស់មហាសន្និបាត 2200A (XXI) ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦ ចូលជាធរមានថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៧៦ អនុលោមតាមមាត្រា ៤៩ នៅគេហទំព័រ http://www2.ohchr.org/english/law/ccpr.htm

១១. នៅក្នុងសារអេឡិចត្រូនិចដែលបានផ្ញើទៅអង្គបុរេជំនុំជម្រះ ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១០ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានស្នើឱ្យបញ្ជាក់ពីចៅក្រមអង្គបុរេជំនុំជម្រះជាមុន ថាតើ "ឯកសារគាំទ្រ" ប្រភេទណា ដែលអាចទទួលយកបាន ក្នុងបណ្តឹងឧទ្ធរណ៍[5]។ អ.ប.ជ បានឆ្លើយតបថា ៖ "ចៅក្រមអង្គបុរេជំនុំជម្រះគ្មានតួនាទីក្នុងការផ្តល់ការបញ្ជាក់លើបញ្ហានេះបានឡើយ។ ប្រសិនបើភាគីដាក់បណ្តឹងឧទ្ធរណ៍នោះ ការផ្តល់សេចក្តីសន្និដ្ឋានដល់អង្គបុរេជំនុំជម្រះ គឺអាស្រ័យលើភាគីនោះ ឬមេធាវីរបស់ខ្លួន នៅពេលមេធាវីយល់ឃើញថាមានភាពសមស្របក្នុងការគាំទ្រដល់ការអះអាង ដែលបម្រើផលប្រយោជន៍របស់កូនក្តីខ្លួនច្រើនបំផុត។ ការដាក់ពាក្យសុំបញ្ចូលភស្តុតាងបន្ថែម នឹងត្រូវពិចារណា ស្របតាមច្បាប់ជាធរមាន"[6]។ (**<u>ឧបសម្ព័ន្ធ ខ</u>**)

១២. សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីសន្និដ្ឋានថា វិធានផ្ទៃក្នុងត្រូវតែបកស្រាយក្នុងន័យការពារជានិច្ចដល់ផលប្រយោជន៍របស់ជនរងគ្រោះ ស្របតាមវិធាន ២១(១) និងក្នុងន័យផ្តល់ព័ត៌មានដល់ជនរងគ្រោះថាសិទ្ធិរបស់ជនរងគ្រោះត្រូវបានការគោរព ស្របតាមវិធាន២១(១)(គ)។

១៣. សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីដាក់ក្នុង**<u>ឧបសម្ព័ន្ធ គ</u>**នៃបណ្តឹងឧទ្ធរណ៍នូវកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ដែលធ្វើឡើងដោយអ្នកស៊ើបអង្កេតពី ក.ស.ច.ស ជាមួយនឹងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងជាជនជាតិភាគតិចវៀតណាមក្នុងខេត្តកំពង់ឆ្នាំង។ ឯកសារ និងព័ត៌មានក្នុងឧបសម្ព័ន្ធនោះមានតម្លៃជាភស្តុតាង ដោយចាត់ទុកជា "ឯកសារគាំទ្រ" ស្របតាមខ្លឹមសារនៃវិធាន ៧៧ *ស្ទួន* នៃវិធានផ្ទៃក្នុង។

## IV. **ភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍**

១៤. យោងទៅលើវិធានផ្ទៃក្នុង (វិសោធនកម្មលើកទី៥) ពោលគឺ វិធាន៧៧ *ស្ទួន*(1) និង(២) ដីកាសម្រេចទាក់ទិននឹងភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អាច

[5] សារអេឡិចត្រូនិចរបស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី លោកស្រី Lyma NGUYEN ផ្ញើជូនក្រឡាបញ្ជីអ.ប.ជ មានចំណងជើងថា "បន្ទាន់ ៖ វិធីសាស្ត្ររបស់ អ.ប.ជ ទាក់ទងនឹងព័ត៌មានគាំទ្រលើបណ្តឹងឧទ្ធរណ៍លើសេចក្តីសម្រេចមិនទទួលស្គាល់" ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១០ ត្រង់ឧបសម្ព័ន្ធ ក។

[6] សារអេឡិចត្រូនិចរបស់ក្រឡាបញ្ជីអ.ប.ជ ឆ្លើយតបនឹងសារអេឡិចត្រូនិចរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី លោកស្រី Lyma Nguyen ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១០ ត្រង់ឧបសម្ព័ន្ធ ក។

ត្រូវយកទៅប្តឹងឧទ្ធរណ៍ក្នុងរយៈពេលដប់ថ្ងៃ ចាប់ពីថ្ងៃជូនដំណឹងនៃដីកាសម្រេចនេះ។ ដោយសារតែទាំងដីកាសម្រេចខេត្តកំពង់ឆ្នាំងនេះត្រូវបានផ្តល់ដំណឹងដល់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីនៅថ្ងៃអង្គារ ទី១៤ ខែកញ្ញា ឆ្នាំ២០១០ ដូច្នេះកាលបរិច្ឆេទផុតកំណត់សម្រាប់បណ្តឹងឧទ្ធរណ៍លើដីកាសម្រេចនេះគឺថ្ងៃសុក្រ ទី២៤ ខែកញ្ញា ឆ្នាំ២០១០។ ទោះជាយ៉ាងនេះក្តី ដោយសារ ថ្ងៃសុក្រ ទី២៤ ខែកញ្ញា គឺជាថ្ងៃឈប់សម្រាកបុណ្យជាតិ (ទិវាប្រកាសប្រើរដ្ឋធម្មនុញ្ញ) យោងតាមវិធាន ៣៩(៣)នៃវិធានផ្ទៃក្នុង បណ្តឹងឧទ្ធរណ៍នេះត្រូវបានដាក់នៅថ្ងៃធ្វើការនាថ្ងៃបន្ទាប់ គឺថ្ងៃច័ន្ទ ទី២៧ ខែកញ្ញា ឆ្នាំ២០១០។

១៥. នៅថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១០ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានដាក់សេចក្តីជូនដំណឹងដ៏សំខាន់ពីការដាក់បណ្តឹងឧទ្ធរណ៍ និងសំណើសុំបន្ថែមចំនួនទំព័រសម្រាប់បណ្តឹងឧទ្ធរណ៍នេះ[7]។ នៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១០ អ.ប.ជ បានអនុញ្ញាតឱ្យបន្ថែមចំនួនទំព័រសម្រាប់ដាក់បណ្តឹងឧទ្ធរណ៍ ដោយលើកឡើងថា សំណើដើមបានបង្ហាញយ៉ាងច្បាស់ថា បណ្តឹងឧទ្ធរណ៍ជាភាសាអង់គ្លេសអាចមានប្រមាណ៥០ទំព័រ ដោយមិនរាប់បញ្ចូលក្របមុខ ឯកសារយោង និងឧបសម្ព័ន្ធ[8]។

១៦. នៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទទួលបានការជូនដំណឹងពីអង្គភាពបកប្រែភាសារបស់ អ.វ.ត.ក ថា អង្គភាពបកប្រែមិនអាចបកប្រែបណ្តឹងឧទ្ធរណ៍នេះឱ្យទាន់កាលបរិច្ឆេទចុងក្រោយដែលបានកំណត់ទេ។ អាស្រ័យហេតុនេះ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីនឹងដាក់បណ្តឹងឧទ្ធរណ៍នេះជាភាសាអង់គ្លេស នៅថ្ងៃទី២៧ ខែ

---

[7] សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី "សំណើសុំបន្ថែមចំនួនទំព័រសម្រាប់បណ្តឹងឧទ្ធរណ៍ជំទាស់នឹងដីកាសម្រេចអំពីការទទួលយកអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីមកពីខេត្តកំពង់ឆ្នាំង", ចុះថ្ងៃទីថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១០, ឯកសារលេខ D417/2/1។

[8] អ.ប.ជ សេចក្តីសម្រេចលើសំណើរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីសុំបន្ថែមចំនួនទំព័រសម្រាប់បណ្តឹងឧទ្ធរណ៍ជំទាស់នឹងដីកាសម្រេចអំពីការទទួលយកអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីមកពីខេត្តកំពង់ឆ្នាំង", ចុះថ្ងៃទីថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១០, ឯកសារលេខ D417/2/1។

00633998



កញ្ញា ឆ្នាំ២០១០ ដែលជាថ្ងៃចុងក្រោយ ហើយបណ្តឹងឧទ្ធរណ៍នេះជាភាសាខ្មែរនឹងត្រូវដាក់នៅពេលបកប្រែរួច។

១៧. ដីកាសម្រេចខេត្តកំពង់ឆ្នាំងរបស់ ស.ច.សនេះមានបញ្ចូលនូវសេចក្តីសម្រេចស្តីពីភាពអាចទទួលយកបាននៃអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។ ដូចនេះ បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចនេះត្រូវតែទទួលស្គាល់ដោយផ្អែកលើអង្គហេតុ និងបានដាក់ទាន់ពេលវេលាកំណត់។

## V. សេចក្តីសង្ខេបបឋម

១៨. សហាមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីលើកឡើងថា ដីកាសម្រេចខេត្តកំពង់ឆ្នាំងរបស់ ក.ស.ច.ស នេះ មានមូលហេតុទូទៅ ដែលមានរៀបរាប់ក្នុងកថាខណ្ឌ ៤ ដល់១៨ ដូចគ្នាបេះបិទនឹងមូលហេតុ ដែលបានលើកឡើងក្នុងដីកាសម្រេចផ្សេងៗ ស្តីពីភាពទទួលយកបាន ចេញដោយ ក.ស.ច.ស។ ផ្នែក "ការវាយតម្លៃលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនីមួយៗ" គ្រាន់តែផ្តល់មូលហេតុទូទៅទៅតាមលេខសំណុំរឿងដែលបញ្ជាក់ពីអត្តសញ្ញាណរបស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីប៉ុណ្ណោះ។ ដីកាសម្រេចនេះធ្វើការយោងទៅលើជើងទំព័រមួយ ដែលយោងទៅលើឧបសម្ព័ន្ធមួយដោយមានបញ្ជាក់មូលដ្ឋានចំពោះការបដិសេធចំនួនប្រាំមួយខុសៗគ្នា[9]។ មូលដ្ឋានទាំងអស់នេះមានលក្ខណៈទូទៅ និងមិនបានកំណត់ឲ្យដាច់ពីគ្នានូវពាក្យសុំនីមួយៗឡើយ។ ដូច្នេះ អ្នកដាក់ពាក្យសុំមិនអាចកំណត់បានឡើយនូវហេតុផលជាក់លាក់ទាក់ទងទៅនឹងអង្គហេតុនៅក្នុងពាក្យសុំដាច់ដោយឡែកពីគ្នា ដែលស.ច.សយកមកសំអាងជាមូលដ្ឋានសម្រាប់ធ្វើការបដិសេធពាក្យសុំទាំងនេះ។

១៩. ក្នុងអំឡុងពេលនៃការដាក់បណ្តឹងឧទ្ធរណ៍ស្តីពីភាពអាចទទួលយកបាននោះ សហាមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីមើលឃើញច្បាស់ថា អង្គជំនុំជម្រះ ឬអង្គភាពផ្សេងៗរបស់ អ.វ.ត.ក មានការយល់ឃើញ និងវិធីសាស្ត្រខុសៗគ្នា ទៅលើ *"វិសាលភាពនៃកិច្ចស៊ើបសួរ"*។ នៅក្នុងបណ្តឹងឧទ្ធរណ៍នេះ សហាមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីមានបំណងវែកញែកពីភាពផ្សេងគ្នាថាតើពេលណាទើបយោងដល់វិធីសាស្ត្ររបស់ការិយាល័យសហព្រះរាជអាជ្ញា ដែលវិធីសាស្ត្រ

---

[9] ឧបសម្ព័ន្ធ ៣ នៃដីកាសម្រេច ដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវបានបដិសេធមិនទទួលស្គាល់។

នេះខុសពីវិធីសាស្ត្ររបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត។ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីនឹងបង្ហាញពីបញ្ហានេះ ដោយយោងទៅលើវិសាលភាពរបស់ ក.ស.ច.ស ដែលបានកំណត់ពី "**វិសាលភាពនៃកិច្ចស៊ើបសួរ**" (អក្សរតូចជាភាសាអង់គ្លេស) និងយោងទៅលើអង្គហេតុផ្សេងៗ ដែល ក.ស.ព បានបញ្ជូនទៅឱ្យ ក.ស.ច.ស ដើម្បីធ្វើការស៊ើបអង្កេតថាជា "**វិសាលភាពនៃកិច្ចស៊ើបសួរ**" (អក្សរធំជាភាសាអង់គ្លេស)។

## VI. **ឧទ្ធរណ៍**

## **ក. មូលដ្ឋានទីមួយនៃបណ្តឹងឧទ្ធរណ៍**

*ដីកាទាំងនេះផ្អែកលើការអនុវត្តដោយមិនត្រឹមត្រូវលើវិធាន ២៣(១)(ខ) នៃវិធានផ្ទៃក្នុង (វិសោធនកម្មលើកទី៥) និងការបកស្រាយដោយមិនត្រឹមត្រូវលើវិធាន ២១(១) វិធាន ២១(១)(ក)/(គ) វិធាន ២៣(២) នៃវិធានផ្ទៃក្នុង (វិសោធនកម្មលើកទី៤ និងវិសោធនកម្មមុនៗ) ហេតុដូច្នេះហើយបានបំពានលើលក្ខខណ្ឌអំពីភាពយុត្តិធម៌ផ្នែកនីតិវិធី។*

### 1. **ការអនុវត្តវិសោធនកម្មវិធានផ្ទៃក្នុងលើកទី៥ នៅក្នុងការកំណត់សម្រេចអំពីភាពអាចទទួលយកបានមានការភ័ន្តច្រឡំ និងបង្កើតបានជាការបំពានលើភាពយុត្តិធម៌ផ្នែកនីតិវិធី**

២០. ស.ច.ស បានយកវិសោធនកម្មលើកទី៥ នៃវិធានផ្ទៃក្នុងមកអនុវត្តដោយភ័ន្តច្រឡំនៅក្នុងការកំណត់សម្រេចអំពីភាពអាចទទួលយកបាននៃអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី[10]។ ភាពយុត្តិធម៌ផ្នែកនីតិវិធីកំណត់ថា វិធានផ្ទៃក្នុងដែលកំពុងស្ថិតនៅជាធរមាន នៅពេលដែលជនរងគ្រោះបានដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី គួរយកមកអនុវត្តនៅពេលសម្រេចអំពីឋានៈនៃដើមបណ្តឹងរដ្ឋប្បវេណី។

[10] ដីកាដែលរងការជំទាស់ កថាខណ្ឌ ៧ និង ៨។

២១. សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី យោង និងដាក់បញ្ចូលជាឯកសារយោងនូវសេចក្តីសន្និដ្ឋានផ្នែកច្បាប់នៅកថាខណ្ឌ ១៦ ដល់២៥ នៃ“បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចស្តីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលមានអាសយដ្ឋាននៅក្នុងខេត្តកែប”[11]។

២២. ដោយសារតែជនរងគ្រោះមានក្តីសង្ឃឹមដ៏សមស្របថា ភាពអាចទទួលយកបាននៃពាក្យសុំរបស់ខ្លួននឹងត្រូវបានសម្រេចយោងតាមសេចក្តីណែនាំអនុវត្ត និងយោងតាមបញ្ញត្តិវិធានផ្ទៃក្នុងដែលស្ថិតនៅជាធរមាននៅពេលដាក់ពាក្យសុំ វាមានភាពអយុត្តិធម៌ណាស់ក្នុងការអនុវត្តវិធានដែលបានធ្វើវិសោធនកម្មរួចជាប្រតិសកម្មនោះ ដែលបានប៉ះពាល់ជាសំខាន់ និងយ៉ាងធ្ងន់ធ្ងរដល់សិទ្ធិរបស់ជនរងគ្រោះ។ វិធានដែលត្រូវបានធ្វើវិសោធនកម្ម កំហិតសិទ្ធិរបស់ជនណាម្នាក់ក្នុងការទាមទារអ្វីមួយ តាមរយៈការអនុវត្តលក្ខណវិនិច្ឆ័យ ដែលកាន់តែស្មុគស្មាញ សម្រាប់ភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលផ្ទុយទៅនឹងលក្ខខណ្ឌកំណត់សម្រាប់ភាពយុត្តិធម៌ផ្នែកនីតិវិធី ស្របតាមវិធាន ១៤(១) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ[12]។

## ២. ការអនុវត្ត និងការចាត់ចែងយន្តការនៃភាពអាចទទួលយកបានរបស់ ស.ច.ស ផ្ទុយទៅនឹងភាពយុត្តិធម៌ផ្នែកនីតិវិធី

២៣. គោលការណ៍ណែនាំជាសាធារណៈដំបូងដែលបានលើកឡើងពីភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបានចេញផ្សាយជាងពីរឆ្នាំមកហើយនៅក្នុងយន្តការនៃការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលត្រូវបានកំណត់ទុកដោយវិធានផ្ទៃក្នុងដើមដំបូង តាមរយៈសេចក្តីប្រកាសព័ត៌មានរបស់ ក.ស.ច.ស ចុះថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០០៩ ដោយប្រកាសអំពី “វិសាលភាពនៃកិច្ចស៊ើបសួរ” ចំពោះទីកន្លែងកើតហេតុផ្សេងៗជាច្រើន និងអំពើនានាដែលប្រឆាំង

[11] ដាក់ជូននៅថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១០ ដោយសហមេធាវីលោក ហុង គឹមសួន លោក នី ចាន់ឌី និងលោកស្រី Silke STUDZINSKY។ នៅពេលសរសេរឯកសារ លេខឯកសារសម្រាប់បណ្តឹងឧទ្ធរណ៍ខេត្តកែបមិនទាន់មាននៅឡើយទេ។

[12] ដូចខាងលើ នៅកថាខណ្ឌទី១២ ដែលនិយាយពីរឿងក្តី *Obermeier* តទល់នឹង *Austria* និងរឿងក្តី *Golder* តទល់នឹង*UK*។ បណ្តឹងឧទ្ធរណ៍របស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីប្រឆាំងនឹងដីកាសម្រេចស្តីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលមានអាសយដ្ឋាននៅខេត្តកំពង់ឆ្នាំង (D417)

និងប្រជាជន[13]។ សេចក្តីប្រកាសព័ត៌មាននេះ លើកឡើងថា "ប្រសិនបើជនរងគ្រោះចង់តាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ការទទួលរងនូវព្យសនកម្មរបស់ពួកគាត់ត្រូវតែផ្ទាល់ខ្លួន និងដោយផ្ទាល់ដែលជាប់ទាក់ទងនឹងស្ថានភាព អង្គហេតុមួយ ឬច្រើនដែលបង្កើតបានជាមូលដ្ឋាននៃការស៊ើបសួរដែលកំពុងដំណើរការ"។

២៤. នៅថ្ងៃទី១៣ ខែមករា ឆ្នាំ២០១០ ស.ច.ស បានចេញដីកាមួយដោយប្រកាសថា អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួន មិនអាចទទួលយកបានទេ ដោយហេតុថាអ្នកដាក់ពាក្យសុំ ខកខានមិនបានបង្កើតចំណងទាក់ទងរវាងព្យសនកម្មដែលបានលើកឡើង និងអង្គហេតុនានាដែលស្ថិតក្រោមកិច្ចស៊ើបសួរ ទោះបីជាសេចក្តីប្រកាសព័ត៌មានដែលបានប្រកាសពី "វិសាលភាពនៃកិច្ចស៊ើបសួរ" បានលើកឡើងថា "ព័ត៌មាននេះមិនត្រូវបាន គេយល់ឃើញថាជាសេចក្តីសម្រេចរបស់តុលាការពាក់ព័ន្ធនឹងវិសាលភាពនៃកិច្ចស៊ើបសួរ នៅក្នុងសំណុំរឿង ០០២ នោះទេ" [14]។

២៥. ចំពោះអ្នកដាក់ពាក្យសុំដែលមិនទាន់ត្រូវបានគេសម្រេចអំពីឋានៈរបស់ខ្លួននោះ ដោយដឹងថាសង្គមស៊ីវិលបានជួយជនរងគ្រោះក្នុងការបំពេញទម្រង់បែបបទរបស់ខ្លួនដោយគ្មានគោលការណ៍ណែនាំណាមួយអស់រយៈជាងពីរឆ្នាំហើយនោះ នៅថ្ងៃទី២៨ ខែមករា ឆ្នាំ២០១០ ក.ស.ច.ស បានពន្យារពេលកំណត់សម្រាប់ការផ្តល់ព័ត៌មានបន្ថែម ដើម្បីធានាថា ពាក្យសុំដែលត្រូវបានដាក់ បានចប់សព្វគ្រប់ហើយ[15]។ បន្ទាប់មកទៀត ក.ស.ច.ស បានពន្យារពេលកំណត់នេះដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១០ ដែលទំនងជាពិចារណាដល់ការជូនដំណឹងជាសាធារណៈយឺតយ៉ាវអំពី "វិសាលភាពនៃកិច្ចស៊ើបសួរ" កាលពីខែ វិច្ឆិកា ឆ្នាំ២០០៩។ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើម

---

[13] សេចក្តីប្រកាសព័ត៌មានរបស់ ក.ស.ច.ស ចុះថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០០៩ នៅ http://www.eccc.gov.kh/english/cabinet/press/138/ECCC_Press_Release_5_Nov_2009_Eng.pdf.

[14] ដីការបស់ ក.ស.ច.ស D250/3/2 ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១០ ស្តីពីភាពអាចទទួលយកបានពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។

[15] សារណារបស់ ក.ស.ច.ស ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១០ ឯកសារលេខ D 337។ ក.ស.ច.ស បានពន្យារពេលកំណត់នេះតាមសំណើសុំ និងបន្ទាប់ពីមានការបដិសេធសំណើសុំឱ្យធ្វើការពិចារណាឡើងវិញ រហូតដល់ថ្ងៃទី៣០ ខែ មិថុនា ឆ្នាំ២០១០ ឯកសារលេខ D337/6។

បណ្ដឹងរដ្ឋប្បវេណីដែលត្រូវបានចាត់ទុកថាមិនអាចទទួលយកបានកាលពីថ្ងៃ១៣ ខែមករា ឆ្នាំ ២០១០ មិនត្រូវបានផ្ដល់ឱកាសឱ្យផ្ដល់ព័ត៌មានបន្ថែមដើម្បីគាំទ្រដល់ការទាមទាររបស់ ខ្លួនឡើយ។ អ្នកដាក់ពាក្យ សុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ដែលគ្មានមេធាវីតំណាង ក៏មិនត្រូវបានចាត់តាំងឱ្យមានមេធាវីតំណាងផងដែរ កាលពីថ្ងៃទី២ ខែសីហា ឆ្នាំ ២០១០ តាមរយៈដីការបស់ ស.ច.ស[16]។ ផ្នែកក្រោយៗទៀតនៃបណ្ដឹងឧទ្ធរណ៍នេះនឹងបង្ហាញពីសេចក្ដីសន្និដ្ឋានមួយចំនួនទៀតអំពីកង្វះខាតនៃនីតិវិធីទាំងនេះ។

២៦. ផ្ទុយទៅនឹងក្ដីសង្ឃឹមដ៏សមហេតុផល ដែលដើមបណ្ដឹងរដ្ឋប្បវេណីមាននៅចំពោះមុខតុលាការនេះ ក.ស.ច.ស បានរំលោភម្ដងហើយម្ដងទៀតលើកាតព្វកិច្ចរបស់ខ្លួន ក្នុងការធានាអំពីភាពយុត្តិធម៌ផ្នែកនីតិវិធីសម្រាប់ដើមបណ្ដឹងរដ្ឋប្បវេណី និងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងការប្រព្រឹត្ដ និងការចាត់ចែងយន្ដការនៃភាពអាចទទួលយកបាន។ ជាពិសេស ក.ស.ច.ស បានរំលោភលើសិទ្ធិរបស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ក្នុងការទទួលបាននូវការសម្រេចលើបញ្ហាណាមួយដោយយុត្តិធម៌។ ជាពិសេស ភាពប្រាកដប្រជា និងភាពច្បាស់លាស់នៅក្នុងការសង្ឃឹមថា បញ្ហានឹងត្រូវបានដោះស្រាយក្នុងលក្ខណៈមួយដែលអាចព្យាករទុកជាមុន និងអាចកំណត់បាន។

២៧. នៅក្នុងបណ្ដឹងឧទ្ធរណ៍នេះ សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីស្នើសុំឱ្យ អ.ប.ជ រារាំង ក.ស.ច.ស មិនឱ្យសម្រេចលើពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីជាប្រតិសកម្ម តាមវិធានផ្ទៃក្នុងថ្មីនោះទេ។

## ៣. ការបកស្រាយអំពីវិធានផ្ទៃក្នុងជាធរមានរបស់ ស.ច.ស មានការភ័ន្ដច្រឡំ

២៨. បន្ទាប់ពីបានអនុវត្តវិសោធនកម្មលើកទី៥ នៃវិធានផ្ទៃក្នុងចំពោះរឿងក្ដីនេះដោយភ័ន្ដច្រឡំមក ស.ច.ស មានកំហុសក្នុងការលើកឡើងថា ភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ត្រូវបានកំហិតចំពោះជនរងគ្រោះដែលទទួលរងព្យសនកម្ម ដែលជាផលវិបាក

[16] Ordonnance portant organisation de la représentation des parties civiles en application de la règle 23 *ter* du Règlement, ថ្ងៃទី២ ខែសីហា ឆ្នាំ២០១០ ឯកសារលេខ D337/10.

ផ្ទាល់ពី *បទឧក្រិដ្ឋដែលបានចោទប្រកាន់លើជនត្រូវចោទ* នេះជាឧក្រិដ្ឋកម្មដែលមាននៅក្នុងកថាខណ្ឌ ៣៧ ដល់កថាខណ្ឌ៧២ នៃដីកាសន្និដ្ឋានស្ថាពរបញ្ជូនរឿងឲ្យស៊ើបសួរ និងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម[17]។

២៩. មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីលើកឡើងម្តងទៀតថា វិធានត្រឹមត្រូវដែលត្រូវអនុវត្ត គឺវិធានផ្ទៃក្នុងចាស់ (មុនវិសោធនកម្មលើកទី៥) ពីព្រោះវិធានទាំងនេះបានបង្កើតនូវមូលដ្ឋាននៃក្តីសង្ឃឹមដែលជនរងគ្រោះមាន នៅពេលដែលខ្លួនបានដាក់ពាក្យសុំ។

៣០. នៅក្នុងការបកស្រាយវិធាន ២៣(២) នៃវិធានផ្ទៃក្នុង (*ចាស់*) ជាបឋម គេត្រូវស្វែងយល់អត្ថន័យនៃបទប្បញ្ញត្តិ ទៅតាមអត្ថន័យដែលមាននៅក្នុងបទប្បញ្ញត្តិនោះ ហើយប្រសិនបើអត្ថន័យនោះមានភាពច្បាស់លាស់ តួនាទីរបស់តុលាការគឺអនុវត្តបទប្បញ្ញត្តិយោងតាមអត្ថន័យនៃបទប្បញ្ញត្តិនោះ។ អត្ថន័យនៃប្រយោគទីមួយនៃវិធាន ២៣(២) នៃវិធានផ្ទៃក្នុង (*ចាស់*) គឺងាយយល់ និងច្បាស់លាស់ - វិធាននេះ ផ្តល់ឲ្យជនរងគ្រោះនូវសិទ្ធិក្នុងការធ្វើបណ្តឹងរដ្ឋប្បវេណី ប្រសិនបើខ្លួនគឺជាជនរងគ្រោះនៃ "***បទឧក្រិដ្ឋដែលស្ថិតនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក***"។ ពាក្យ "យុត្តាធិការ" ត្រូវបានកំណត់និយមន័យច្បាស់លាស់នៅក្នុងកិច្ចព្រមព្រៀង និងច្បាប់ អ.វ.ត.ក ដែលអាចអនុវត្តបាន និងគ្របដណ្តប់លើបទឧក្រិដ្ឋអន្តរជាតិ និងបទឧក្រិដ្ឋជាតិ ដែលបានប្រព្រឹត្តដោយមេដឹកនាំជាន់ខ្ពស់ ឬអ្នកទាំងឡាយណាដែលទទួលខុសត្រូវខ្ពស់បំផុត នៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ (ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩)។

៣១. វិធាន ២៣(២)(ខ) នៃវិធានផ្ទៃក្នុង (*ចាស់*) ពេលនោះបានសំដៅដល់ព្យសនកម្មដែលបានទទួលរងជាផលវិបាកផ្ទាល់នៃ***បទល្មើស***។ បទប្បញ្ញត្តិនេះត្រូវបានបកស្រាយនៅក្នុងបរិបទនៃ បទប្បញ្ញត្តិ*ទាំងមូល* រួមទាំងប្រយោគទីមួយដែលសំដៅលើបទឧក្រិដ្ឋ "ដែលស្ថិតនៅ ក្នុងយុត្តាធិការរបស់ អ.វ.ត.ក"។ ការបកស្រាយជារួមនាំឲ្យមានការយល់ថា ការនិយាយថា "ផលវិបាកផ្ទាល់នៃបទល្មើស" មានន័យថាជាការនិយាយថា "បទល្មើសដែលស្ថិតនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក"។ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីលើកឡើងថា វិធានផ្ទៃក្នុង

---

[17] សេចក្តីប្រកាសព័ត៌មានរបស់ ក.ស.ច.ស ចុះថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០០៩ នៅ http://www.eccc.gov.kh/english/cabinet/press/138/ECCC_Press_Release_5_Nov_2009_Eng.pdf.

ជាធរមានពាក់ព័ន្ធនឹងពេលដែលជនរងគ្រោះបានដាក់ពាក្យសុំ មិនបានកំណត់អំពីភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចំពោះអ្នកទាំងឡាយណាដែលទាក់ទងទៅនឹងការចោទប្រកាន់នោះឡើយ។

៣២. សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីយោង និងដាក់បញ្ចូលជាឯកសារយោងនូវសេចក្តីសន្និដ្ឋានផ្នែកច្បាប់នៅ កថាខណ្ឌ ៣៦ ដល់កថាខណ្ឌ៤១នៃបណ្តឹងឧទ្ធរណ៍ខេត្តកែប[18]។

៣៣. មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ស្នើសុំឱ្យ អ.ប.ជ បដិសេធសេចក្តីសម្រេចរបស់ ស.ច.ស ដែលបានប្រកាសថា ដើមបណ្តឹងរដ្ឋប្បវេណីខាងក្រោមមិនអាចទទួលយកបាន ដោយហេតុថាអ្នកដាក់ពាក្យសុំទាំងអស់នេះមិនបានទទួលភាពយុត្តិធម៌ផ្នែកនីតិវិធីឡើយ ពីព្រោះ ស.ច.ស បានអនុវត្តវិធានផ្ទៃក្នុងខុស និង/ឬបានបកស្រាយបទប្បញ្ញត្តិជាធរមានដោយភ័ន្តច្រឡំ សម្រាប់អ្នកដាក់ពាក្យសុំដែលមានលេខសម្គាល់ D22/1901, D22/3180, D22/3183, D22/2057, D22/2154, D22/438, D22/3179, D22/3182, D22/816, D22/3177, D22/2157, D22/3181, D22/817, D22/2155, D22/2153, D22/404, D22/2156, D22/1136, D22/1969, D22/3175, D22/3176, D22/3178, D22/2158, D22/1092 និង D22/2758។ អ្នកដាក់ពាក្យសុំទាំងនេះបានទទួលរងព្យសនកម្ម ដែលជាផលវិបាកដោយផ្ទាល់នៃបទឧក្រិដ្ឋស្ថិតក្នុងយុត្តាធិការរបស់ អ.វ.ត.ក ដោយផ្អែកលើការបកស្រាយត្រឹមត្រូវនៃវិធានផ្ទៃក្នុងត្រឹមត្រូវ។

៣៤. ប្រសិនបើចៅក្រមនៃ អ.ប.ជ សម្រេចថា វិសោធនកម្មលើកទី៥នៃវិធានផ្ទៃក្នុង គឺជាបញ្ញត្តិត្រឹមត្រូវសម្រាប់យកមកអនុវត្តក្នុងការសម្រេចពីភាពទទួលយកបាននៃដើមបណ្តឹងរដ្ឋប្បវេណីនោះ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីធ្វើអំណះអំណាងក្នុងសេចក្តីសន្និដ្ឋាន ក្នុងផ្នែកទី៤នៃមូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍ថា ទោះបីជាមានការអនុវត្តវិសោធនកម្មទី ៥នៃវិធានផ្ទៃក្នុង និងផ្អែកលើការវាយតម្លៃសមស្របលើព្យសនកម្មដែលមានទំនាក់ទំនងជាមួយនឹង*ឧក្រិដ្ឋកម្មដែលបានចោទប្រកាន់នឹងជនត្រូវចោទ* អ្នកដាក់ពាក្យតាំងខ្លួនជាដើមបណ្តឹរដ្ឋប្បវេណី ដែលជាជនជាតិភាគតិចវៀតណាម<u>ទាំងអស់</u> ពីខេត្តកំពង់ឆ្នាំង គួរតែទទួលយកជាដើមបណ្តឹងរដ្ឋប្បវេណី ពីព្រោះអង្គហេតុដែលបានលើកឡើងដោយអ្នកដាក់ពាក្យទាំងនេះ និងត្រូវបានបញ្ជូនទៅឱ្យ ក.ស.ច.ស ទទួលបាន

---

[18] ដាក់ជូននៅថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១០ ដោយសហមេធាវីលោក ហុង គឹមសួន លោក នី ចាន់ឌី និងលោកស្រី Silke STUDZINSKY។ នៅពេលសរសេរឯកសារ លេខឯកសារសម្រាប់បណ្តឹងឧទ្ធរណ៍ខេត្តកែបមិនទាន់មាននៅឡើយទេ បណ្តឹងឧទ្ធរណ៍របស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីប្រឆាំងនឹងដីកាសម្រេចស្តីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលមានអាសយដ្ឋាននៅខេត្តកំពង់ឆ្នាំង (D417)

ដើម្បីស៊ើបសួរ គឺមានទំនាក់ទំនងផ្ទាល់ជាមួយនឹងឧក្រិដ្ឋកម្ម ដែលដីកាដំណោះស្រាយរបស់ ស.ច.សបានធ្វើការចោទប្រកាន់លើជនជាប់ចោទទាំង ៤។

៣៥. បន្តទៅទៀតនេះ បណ្តឹងឧទ្ធរណ៍នេះងាកទៅពិនិត្យលើការរំលោភបំពានរបស់ស.ច.សលើលក្ខខណ្ឌជាសារវន្តនៃស្ថាប័នតុលាការ ដែលតម្រូវឱ្យចេញសេចក្តីសម្រេច*ដែលមានសំអាងហេតុ* ។

**ខ. មូលដ្ឋានទីពីរ នៃបណ្តឹងឧទ្ធរណ៍**

***នៅពេលចេញដីកាសម្រេចបដិសេធរួម សហចៅក្រមស៊ើបអង្កេតមានការភ័ន្តច្រឡំលើអង្គច្បាប់ ហើយបានរំលោភបំពានលើវិធាន ២៣(២) (វិសោធនកម្មលើកទី៣) និងលើគោលការណ៍ជាសារវន្តនៃភាពយុត្តិធម៌ផ្នែកនីតិវិធី ដែលតម្រូវឱ្យចេញសេចក្តីសម្រេចដោយមានសំអាងហេតុ។***

៣៦. ស.ច.ស បានសម្រេចបដិសេធមិនទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលមានលេខសម្គាល់ CPAs D22/1901, D22/3180, D22/3183, D22/2057, D22/2154, D22/438, D22/3179, D22/3182, D22/816, D22/3177, D22/2157, D22/3181, D22/817, D22/2155, D22/2153, D22/404, D22/2156, D22/1136, D22/1969, D22/3175, D22/3176, D22/3178, D22/2158 និង D22/1092 ដោយគ្រាន់តែលើកឡើងថា "(៦) ព្យសនកម្មពុំមានទំនាក់ទំនងទៅនឹងអង្គហេតុដែលស្ថិតនៅក្រោមកិច្ចស៊ើបអង្កេត (ស្ថិតនៅក្រៅវិសាលភាពភូមិសាស្ត្រ/ការធ្វើទុក្ខបុកម្នេញលើប្រជាជនវៀតណាម"។ សម្រាប់អ្នកដាក់ពាក្យសុំដែលមានលេខសម្គាល់ CPA D22/2758 ដីកាសម្រេចនេះគ្រាន់តែបញ្ជាក់ថា "(៦)ព្យសនកម្មមិនពាក់ព័ន្ធនឹងអង្គហេតុ ដែលស្ថិតក្រោមកិច្ចស៊ើបសួរ"។

៣៧. ជាអកុសល ដោយសារហេតុផលមួយចំនួនដែលបានលើកឡើងក្នុងបណ្តឹងឧទ្ធរណ៍ និងដោយហេតុថា ស.ច.សមានការភ័ន្តច្រឡំលើការយល់ឃើញនូវអ្វី ដែលជាអង្គហេតុ ស្ថិតក្នុង "វិសាលភាពនៃកិច្ចស៊ើបសួរ" វាគ្មានភាពច្បាស់លាស់*ទាល់តែសោះ* នៅក្នុងសេចក្តីសម្រេចរបស់ ស.ច.ស ថាតើ ការកំណត់ថា "មិនមានទំនាក់ទំនងរវាងព្យសនកម្មទៅនឹងអង្គហេតុដែលស្ថិតក្រោមការស៊ើបអង្កេត" គឺជាការលើកឡើងក្នុងការកំណត់ថាគ្មានព្យសនកម្ម (ដែលអាចមានទំនាក់ទំនងជាមួយ អង្គហេតុស្ថិតក្រោមការស៊ើបអង្កេត) *ឬ* ថាគ្មានព្យសនកម្ម តែម្តង (បើទោះបីពាក្យសុំបានលើកឡើងយ៉ាងច្បាស់ពីអង្គហេតុមួយចំនួនស្ថិតក្រោមការស៊ើបអង្កេតហើយក៏ដោយ)។

៣៨. វាហាក់ដូចជាថា ការយោងថា អ្នកដាក់ពាក្យសុំ "ស្ថិតនៅក្រៅវិសាលភាពភូមិសាស្ត្រ/ការធ្វើទុក្ខបុកម្នេញ" គឺជាការទទួលស្គាល់របស់ ស.ច.សថា ឃើញថាមានព្យសនកម្ម ដែលទាក់ទងនឹងទង្វើឧក្រិដ្ឋកម្មស្ថិតក្រោមវិសាលភាពនៃការធ្វើទុក្ខបុកម្នេញលើប្រជាជនវៀតណាម ប៉ុន្តែព្យសនកម្មនោះពុំមានទំនាក់ទំនងជាមួយនឹង "អង្គហេតុស្ថិតក្រោមការស៊ើបអង្កេត"ទេ។

៣៩. ការបដិសេធលើកដំបូងរបស់ ស.ច.ស ចំពោះអ្នកដាក់ពាក្យសុំ ដែលជាជនភាគតិចវៀតណាមទាំង ១៦នាក់ មានទីលំនៅក្នុងខេត្តកំពង់ឆ្នាំងក្នុង "ដីកាសម្រេចស្តីពីភាពអាចទទួលយកបាននូវពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាក់ទងនឹងសំណើ ២៥០/៣" ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១០ (**ដីការបស់ ស.ច.ស លើកទីមួយសម្រេចបដិសេធដើមបណ្តឹងជាជនជាតិវៀតណាម**)[19] បានបង្ហាញយ៉ាងច្បាស់ "សំអាងហេតុនានា" ដោយប្រើប្រាស់ពាក្យច្រើនជាង ១៤ ពាក្យក្នុងការបដិសេធអ្នកដាក់ពាក្យម្នាក់ៗ ក្នុងចំណោមអ្នកដាក់ពាក្យសុំដែលជាជនជាតិភាគតិចវៀតណាមទាំង ២៤នាក់ ដែលជាកម្មវត្ថុនៃបណ្តឹងឧទ្ធរណ៍នេះ។ ទោះជាណាក្តី នៅក្នុងដីកាបដិសេធលើកទីមួយលើជនជាតិភាគតិចវៀតណាមក៏ដោយ ក៏ដីកានេះមានកង្វះខាតភាពច្បាស់លាស់ក្នុងការ "ផ្តល់សំអាងហេតុ" ដោយក្នុងសំអាងហេតុនោះ ពុំមានអង្គហេតុណាមួយដែលបានលើកឡើងក្នុងពាក្យសុំរបស់អ្នកដាក់ពាក្យសុំម្នាក់ៗ ត្រូវបានលើកយោងជាពិសេស ដើម្បីជាមូលដ្ឋានទូទៅសម្រាប់បដិសេធអ្នកដាក់ពាក្យសុំទាំងអស់*រួមគ្នា* ឡើយ។ ស.ច.ស ក៏មិនបានផ្តល់ការពន្យល់ណាមួយអំពីមូលដ្ឋានច្បាប់ ដែលការិយាល័យរបស់ខ្លួនយកជាមូលដ្ឋានក្នុងការធ្វើសម្ភាសជាមួយអ្នកដាក់ពាក្យសុំក្នុងខេត្តកំពង់ឆ្នាំងដែល ស.ច.ស បានទទួលយកពួកគេជាដើមបណ្តឹងរដ្ឋប្បវេណីពីដំបូង ហើយចុងក្រោយបានច្រានចោលទៅវិញ។

៤០. សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់ ស.ច.ស លើកទីមួយសម្រេចបដិសេធដើមបណ្តឹងជាជនជាតិវៀតណាមនៅក្នុង"បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចអំពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាក់ទងនឹងសំណើ D250/3"

---

[19] ក.ស.ច.ស "ដីកាសម្រេចស្តីពីភាពអាចទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាក់ទងនឹងសំណើ ២៥០/៣" ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១០ ឯកសារលេខ (ជាបន្តបន្ទាប់ទៅនេះ ហៅថា "**ដីកាលើកទីមួយសម្រេចបដិសេធដើមបណ្តឹងជាជនជាតិវៀតណាម**")។

ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១០[20]។ បណ្តឹងឧទ្ធរណ៍នេះ ត្រូវបានលើកយោងជា "បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចបដិសេធដើមបណ្តឹងរដ្ឋប្បវេណីជាជនជាតិវៀតណាម" នៅក្នុងបណ្តឹងឧទ្ធរណ៍នេះ។

៤១. វិការៈដោយសារការផ្តល់សំអាងហេតុមិនបានលម្អិត និងមិនសមស្របនេះ ធ្វើឱ្យមានការភ័ន្តច្រឡំលើអង្គច្បាប់ និងធ្វើឱ្យដីកាសម្រេចបដិសេធ មិនមានសុពលភាព។ សំអាងហេតុរបស់ ស.ច.ស ដែលមិនសមស្រប និងមិនគ្រប់គ្រាន់ បានរំលោភបំពានលើគោលការណ៍ជាសារវន្តនៃច្បាប់ ដែលតម្រូវឱ្យសេចក្តីសម្រេចរបស់តុលាការត្រូវផ្តល់សំអាងហេតុឱ្យបានសមស្រប។ បន្ថែមទៀតនោះ វាបណ្តាលឱ្យសិទ្ធិប្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី អនុលោមតាមវិធាន ៧៤(៤)(ខ) និងវិធាន ៧៧ *ស្ទួន* នៃវិធានផ្ទៃក្នុង ពុំមានអត្ថន័យអ្វីឡើយ ដោយសារដើមបណ្តឹងរដ្ឋប្បវេណីមិនមានព័ត៌មានគ្រប់គ្រាន់ ដើម្បីខ្លួនអាចយកមកសម្រេចធ្វើជាមូលដ្ឋានក្នុងការដាក់បណ្តឹងឧទ្ធរណ៍ទៅ អ.ប.ជ[២១]។ ដូចគ្នានេះដែរ សំអាងហេតុមិនសមស្រប និង/ឬ មិនគ្រប់គ្រាន់នេះ ក៏ផ្តល់ឱ្យ អ.ប.ជ នូវព័ត៌មានមិនគ្រប់គ្រាន់ ដើម្បីឱ្យ អ.ប.ជ អាចពិនិត្យបណ្តឹងឧទ្ធរណ៍លើដីកាសម្រេចបដិសេធឱ្យបានសមស្រប និងមានប្រសិទ្ធភាពនោះទេ[២២]។

## ១. សិទ្ធិទទួលបានសេចក្តីសម្រេចដោយមានសំអាងហេតុ លើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អនុលោមតាមវិធានផ្ទៃក្នុង

---

[20] សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ក្នុង "បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាអំពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ទាក់ទងនឹងសំណើលេខ D250/3/2" ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១០ ឯកសារលេខ (ជាបន្តទៀតហៅថា "**បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់ ស.ច.ស លើកទីមួយសម្រេចបដិសេធដើមបណ្តឹងរដ្ឋប្បវេណីជាជនជាតិវៀតណាម**")។

[២១] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់សហមេធាវីការពារក្តី អៀង ធីរិទ្ធ ប្រឆាំងនឹង "ដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួររបស់សហមេធាវីការពារក្តី អៀង ធីរិទ្ធ" ថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១០ (*ចាប់ពីពេលនេះទៅហៅ កាត់ថា* សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ក្រុមមេធាវីការពារក្តី អៀង ធីរិទ្ធ) ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១០ D353/2/3 កថាខណ្ឌ ២៣។

[២២] *ដូចខាងលើ*។

៤២. សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីសូមលើកឡើងម្តងទៀតថា វិធានផ្ទៃក្នុងលើកមុនគួរយកមកអនុវត្ត ដោយសារវិធានទាំងនោះ មានចែងអំពីសិទ្ធិសំខាន់ៗ នៅពេលដែលអ្នកដាក់ពាក្យសុំបានដាក់ពាក្យសុំរបស់ខ្លួន។ វិធាន ២៣(៣) និង(៤) (វិសោធនកម្មលើកទី៣ និងវិសោធនកម្មមុនៗ) ចែងថា ដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិទទួលបានសេចក្តីសម្រេច ដោយមានសំអាងហេតុលើដីកាសម្រេចអំពីភាពអាចទទួលយកបាន។ វិធាន ២៣(៣) នៃវិធានផ្ទៃក្នុងចែងថា៖ *"...សហចៅក្រមស៊ើបអង្កេតអាចសម្រេចចេញដីកា ដោយមានសំអាងហេតុបដិសេធពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីបាន"*។ វិធាន ២៣(៤) ចែងថា៖ *"...អង្គជំនុំជម្រះសាលាដំបូងអាចសម្រេចតាមរយៈសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរ ដោយមានសំអាងហេតុថាពាក្យស្នើសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនោះ មិនអាចទទួលយកបាន"*។

៤៣. វិធាន ២៣*ស្ទួន* (៤) នៃវិធានផ្ទៃក្នុង ដែលបានធ្វើវិសោធនកម្មលើកទី៤ ចែងថា ស.ច.ស ត្រូវសម្រេចលើការទទួលស្គាល់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងដីកាដោយឡែក។ វិធាននេះចែងថា៖ *"នៅពេលចេញដីកាដំណោះស្រាយ សហចៅក្រមស៊ើបអង្កេតត្រូវសម្រេចអំពីភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលនៅសេសសល់ទាំងអស់ ដោយដីកាដោយឡែក។ ដីកានេះត្រូវបើកផ្លូវប្តឹងឧទ្ធរណ៍សង្ខេបដោយភាគី ឬអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដូចមាន ចែងក្នុងវិធាន ៧៧ស្ទួន"*។

៤៤. ទោះបីជាវិធានផ្ទៃក្នុង ដែលបានធ្វើវិសោធនកម្ម បានដកចេញនូវលក្ខខណ្ឌក្នុងការចេញដីកា **ដោយមានសំអាងហេតុ**ក៏ដោយ ការចេញដីកាដោយមានសំអាងហេតុនៅតែជាកាតព្វកិច្ចរបស់ស្ថាប័នតុលាការដដែល គ្រាន់តែវាមិនចែងត្រង់ៗតែប៉ុណ្ណោះ។ ដោយសារតែវិធានផ្ទៃក្នុងមិនមានចែងអំពីលក្ខខណ្ឌនេះ ច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (ច្បាប់ **អ.វ.ត.ក** ) អនុញ្ញាតឱ្យ អ.ប.ជ ស្វែងរកការណែនាំនៅក្នុងបទដ្ឋានទីតិវិធីអន្តរជាតិ[២៣]។

## ២. សិទ្ធិទទួលបានសេចក្តីសម្រេចដោយមាន សំអាងហេតុ ដែលជាគោលការណ៍ជាសារវន្តនៃច្បាប់

[២៣] សូមមើលច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មាត្រា ២០ថ្មី មាត្រា ២៣ថ្មី និងមាត្រា ៣៣ថ្មី។

៤៥. សិទ្ធិទទួលបានការសម្រេចដោយយុត្តិធម៌លើបញ្ហាណាមួយ មានចែងធានានៅក្នុងមាត្រា ១៤.១ នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ[២៤]។ ការខកខានរបស់ ស.ច.ស នៅក្នុងការចេញសេចក្តីសម្រេចដោយមានសំអាងហេតុសមរម្យ ច្បាស់ណាស់ថាជាការបដិសេធលើសិទ្ធិទទួលបានការសម្រេចដោយយុត្តិធម៌លើបញ្ហាទាំងនេះ។ ជាពិសេស សិទ្ធិទាំងនេះរួមបញ្ចូលទាំងសិទ្ធិដឹងជាក់លាក់ ថាហេតុអ្វីបានជាខ្លួនមិនត្រូវបានគេទទួលស្គាល់ និងលើសពីនេះទៀត សិទ្ធិក្នុងការដាក់ពាក្យសុំរបស់ខ្លួនឱ្យបានសមរម្យ ពីព្រោះខ្លួនមិនអាចឆ្លើយតបទៅនឹងការបដិសេធនេះ ដោយសារខ្លួនមិនបានដឹងអំពីសំអាងហេតុ។

៤៦. សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី យោង និងដាក់បញ្ចូលជាឯកសារយោងនូវកថាខណ្ឌ ៥១-៥៥ នៃបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចខេត្តកែប[25]។

៤៧. ការខកខានមិនបានចេញសេចក្តីសម្រេចដែលមានសំអាងហេតុឱ្យបានត្រឹមត្រូវ គឺជាការរំលោភគោលការណ៍ ៤ នៃ*សេចក្តីប្រកាសអំពីគោលការណ៍ជាសារវន្តនៃយុត្តិធម៌សម្រាប់ជនរងគ្រោះនៃឧក្រិដ្ឋកម្ម និងការរំលោភបំពានអំណាច* ដែលចែងថា ជនរងគ្រោះគួរត្រូវបានប្រព្រឹត្តដោយសេចក្តីមេត្តា និងគោរពសេចក្តីថ្លៃថ្នូររបស់ពួកគាត់[២៦]។ ការបដិសេធដោយគ្មានមូលដ្ឋានសំអាងហេតុត្រឹមត្រូវ គឺមិនត្រឹមតែជាការដកហូតសិទ្ធិនីតិវិធីជាមូលដ្ឋានប៉ុណ្ណោះទេ ក៏ប៉ុន្តែវាថែមទាំងជាការប្រមាថដល់សេចក្តីថ្លៃថ្នូររបស់ជនរងគ្រោះ ហើយអាចនឹងធ្វើឱ្យជនរងគ្រោះទាំងនោះក្លាយជាជនរងគ្រោះម្តងទៀត ម្តងនេះដោយសារស្ថាប័នតុលាការដែលមានលក្ខណៈអន្តរជាតិ។

---

[២៤] មាត្រា ១៤.១ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយចែងថា "ជនគ្រប់រូប ត្រូវមានភាពស្មើគ្នាចំពោះមុខតុលាការ និងសាលាជម្រះក្តី។ ជនគ្រប់រូបត្រូវមាន សិទ្ធិឱ្យសាលាក្តីមានសមត្ថកិច្ច ឯករាជ្យ និងមិនលម្អៀង ដែលបង្កើតឡើងដោយច្បាប់ជំនុំជម្រះរឿងក្តីរបស់ខ្លួន ដោយសមធម៌ និងសាធារណៈ ដើម្បីសម្រេចលើការចោទប្រកាន់ប្រឆាំងមកលើខ្លួនក្នុងវិស័យព្រហ្មទណ្ឌ ឬលើសិទ្ធិ និងករណីយកិច្ចក្នុងវិស័យរដ្ឋប្បវេណី"។

[25] ដាក់ជូននៅថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១០ ដោយសហមេធាវីលោក ហុង គឹមសួន លោក នី ចាន់ឌី និងលោកស្រី Silke STUDZINSKY។ នៅពេលសរសេរឯកសារ លេខឯកសារសម្រាប់បណ្តឹងឧទ្ធរណ៍ខេត្តកែបមិនទាន់មាននៅឡើយទេ។

[២៦] សេចក្តីប្រកាសអំពីគោលការណ៍ជាមូលដ្ឋាននៃយុត្តិធម៌សម្រាប់ជនរងគ្រោះនៃឧក្រិដ្ឋកម្ម និងការរំលោភបំពានអំណាច ដែលបានអនុម័តដោយសេចក្តីសម្រេចមហាសន្និបាតអង្គការសហប្រជាជាតិ 40/34 ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ១៩៨៥ គោលការណ៍ ៤។

៤៨. ជាទីបញ្ចប់ និងសំខាន់បំផុតចំពោះជនរងគ្រោះខ្លួនគាត់ផ្ទាល់ គ្រប់សេចក្តីសម្រេចទាំងអស់របស់តុលាការនេះ "ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ក្នុងវិធីណាមួយ ដែលធ្វើយ៉ាងណាឱ្យបុគ្គល ដែលមិនមានចំណេះដឹងផ្នែកច្បាប់ អាចយល់បានពេញលេញ។ ជាពិសេស វាមានសារៈសំខាន់ចំពោះសេចក្តីសម្រេចលើពាក្យសុំរបស់បុគ្គល ដែលអះអាង ខ្លួនជាជនរងគ្រោះ និងមានសិទ្ធិជាដើមបណ្តឹងរដ្ឋប្បវេណី"[២៧]។

## ៣. វិសាលភាពនៃការបង្ហាញហេតុផល

៤៩. វិធានផ្ទៃក្នុង ២១ ចែងថា ៖

> *"ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ វិធានផ្ទៃក្នុង សេចក្តីណែនាំអនុវត្ត និងបទបញ្ជារដ្ឋបាលទាំងអស់ជាធរមាន ត្រូវតែបកស្រាយក្នុងន័យការពារជានិច្ចដល់ប្រយោជន៍របស់ជនសង្ស័យ ជនត្រូវចោទ ជនជាប់ចោទ និងជនរងគ្រោះ ដើម្បីធានាអំពីសច្ចភាពផ្លូវច្បាប់ និងតម្លាភាពនៃកិច្ចដំណើរការនីតិវិធី... ក្នុងអត្ថន័យនេះ ៖... (គ) អង្គជំនុំជម្រះវិសាមញ្ញត្រូវធានាថា ជនរងគ្រោះត្រូវទទួលបានការជូនព័ត៌មាន ហើយសិទ្ធិរបស់ជនរងគ្រោះ ត្រូវបានការពារក្នុងអំឡុងពេលនៃដំណើរការនីតិវិធីរឿងក្តី..."*។

៥០. ក្នុងការខកខានមិនបានផ្តល់នូវហេតុផលលម្អិតគ្រប់គ្រាន់ ស.ច.ស មិនបានបំពេញកាតព្វកិច្ចរបស់ខ្លួនអនុលោមតាមវិធានផ្ទៃក្នុង ២១ "ធានាអំពីសច្ចភាពតាមផ្លូវច្បាប់ និងតម្លាភាព"។ ពួកគាត់ថែមទាំងបានរំលោភលើវិធាន ២១ (គ) ដោយមិនបានជូនព័ត៌មានដល់ជនរងគ្រោះឱ្យបានត្រឹមត្រូវអំពីមូលដ្ឋានក្នុងការធ្វើសេចក្តីសម្រេច ដែលប៉ះពាល់ដល់ផលប្រយោជន៍ជនរងគ្រោះ ហើយដូច្នេះ ជាការមិនបានគោរពសិទ្ធិរបស់ជនរងគ្រោះ ក្នុងអំឡុងពេលនៃដំណើរការនីតិវិធីរឿងក្តីឡើយ។

---

[២៧] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នលើ កាំង ហ្កេកអ៊ាវ ហៅ "ឌុច" កថាខណ្ឌ ៣ ដកស្រង់ពីក្នុងសាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចប្រកាសមិនទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី D22/288 ការខ្វែងយោបល់រវាងចៅក្រម Rowan Downing និងចៅក្រម ប្រាក់ គឹមសាន កថាខណ្ឌ ១៦។

៥១. យុត្តិសាស្ត្រអន្តរជាតិ ទទួលស្គាល់ហេតុផលសំខាន់ពីរដែលគូសបញ្ជាក់អំពីសិទ្ធិក្នុងការទទួលបាននូវសេចក្តីសម្រេចដែលមានសំអាងហេតុ។ ទីមួយ បុគ្គលដែលពាក់ព័ន្ធត្រូវតែអាចដឹងអំពីហេតុផលចំពោះការបដិសេធ ដែលគាត់មានបំណងប្តឹងឧទ្ធរណ៍ចំពោះហេតុផលបដិសេធនោះ ។ ទីពីរ អង្គជំនុំជម្រះសាលាឧទ្ធរណ៍ មិនអាចធ្វើការពិនិត្យឡើងវិញនូវសេចក្តីសម្រេចប្រកបដោយយុត្តិធម៌ និងទូលំទូលាយបានឡើយ ប្រសិនបើមិនមានការផ្តល់នូវហេតុផលទេនោះ។

៥២. តុលាការអន្តរជាតិ បានសម្រេចមិនកំណត់អត្ថន័យវិសាលភាពពិតប្រាកដនៃការបង្ហាញហេតុផលដែលតម្រូវឱ្យមាន ប៉ុន្តែបានសម្រេចថា វិសាលភាពនៃការបង្ហាញហេតុផល ត្រូវតែពិចារណាដោយផ្អែកតាមករណីនីមួយៗ ដោយផ្អែកលើកាលៈទេសៈ។ តុលាការព្រហ្មទណ្ឌអន្តរជាតិ បានបញ្ជាក់នៅក្នុងរឿងក្តីរដ្ឋអាជ្ញា ទល់នឹង *Lubanga*[២៨]៖

> *"សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ ដែលអនុញ្ញាតមិនឱ្យមានការផ្សព្វផ្សាយព័ត៌មានទៅដល់មេធាវីការពារក្តីអំពីអត្តសញ្ញាណនៃសាក្សីរបស់រដ្ឋអាជ្ញា ត្រូវតែមានការបង្ហាញ ហេតុផលឱ្យបានគ្រប់គ្រាន់។ វិសាលភាពនៃការបង្ហាញហេតុផល នឹងផ្អែកលើកាលៈទេសៈ នៃរឿងក្តី ប៉ុន្តែវាមានសារៈសំខាន់ដែលថា អង្គបុរេជំនុំជម្រះចង្អុលបង្ហាញដោយមានលក្ខណៈច្បាស់លាស់គ្រប់គ្រាន់នូវមូលដ្ឋាននៃសេចក្តីសម្រេច។ ការបង្ហាញហេតុផលបែបនេះ នឹងមិនតម្រូវចាំបាច់ឱ្យមានការរៀបរាប់គ្រប់កត្តានីមួយៗ ដែលមាននៅចំពោះមុខអង្គបុរេជំនុំជម្រះ ដើម្បីយកមកបង្ហាញដាច់ដោយឡែកពីគ្នាឡើយ ប៉ុន្តែការបង្ហាញហេតុផលនេះ ត្រូវតែបង្ហាញអំពីអង្គហេតុណាខ្លះដែលអង្គបុរេជំនុំជម្រះរកឃើញថាជាប់ពាក់ព័ន្ធនៅក្នុងការឈានទៅដល់ការធ្វើសេចក្តីសម្រេច"*[២៩] ។

---

[២៨] អង្គបុរេជំនុំជម្រះរបស់ អ.វ.ត.ក បានយោងទៅលើយុត្តិសាស្ត្ររបស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍របស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី និងបានវិភាគយុត្តិសាស្ត្ររបស់តុលាការសិទ្ធិមនុស្សអឺរុប និងបានសន្និដ្ឋានថា គោលការណ៍ក្នុងការមានសិទ្ធិទទួលបាននូវសេចក្តីសម្រេចដែលមានសំអាងហេតុ "អនុវត្តដោយមានអានុភាពស្រដៀងគ្នាចំពោះរឿងក្តីនៅក្នុងដៃ" ត្រង់កថាខណ្ឌ ២៩ នៃសេចក្តីសម្រេចចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៦ កថាខណ្ឌ ៣០។

[២៩] សូមមើលកំណត់សម្គាល់ខាងលើ ៦ រឿងក្តីរដ្ឋអាជ្ញា ទល់នឹង Thomas Lubanga Dyilo សាលក្រម ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៦ កថាខណ្ឌ ៣០។ ស្ថានភាពនៅក្នុងសាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោ រឿងក្តីរដ្ឋអាជ្ញា ទល់នឹង Thomas Lubanga Dyilo សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក Thomas Lubanga Dyilo ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ I ដែលមានចំណងជើងថា "សេចក្តីសម្រេចលើកទីពីរស្តីពី សំណើរបស់រដ្ឋអាជ្ញា និងសំណើបណ្តឹងឧទ្ធរណ៍របស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីប្រឆាំងនឹងដីកាសម្រេចស្តីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលមានអាសយដ្ឋាននៅខេត្តកំពង់ឆ្នាំង (D417)

៩៣. យោងទៅលើរឿងក្តី Lubanga ហេតុផលដែលផ្តល់ឱ្យ យ៉ាងហោចណាស់ត្រូវតែបញ្ជាក់ឱ្យបានច្បាស់នូវអង្គហេតុពាក់ព័ន្ធ ដែលឈានទៅរកការធ្វើសេចក្តីសម្រេច។ ការធ្វើតាមការប្រព្រឹត្តដដែល និងការសំអាងហេតុផលទូទៅ ឬការបដិសេធរួម ចំពោះអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដោយផ្អែកលើហេតុផលទូលំទូលាយ ឬមានលក្ខណៈមិនច្បាស់លាស់ គឺមិនគ្រប់គ្រាន់ដើម្បីបំពេញលក្ខខណ្ឌតម្រូវនៃការផ្តល់ហេតុផលឱ្យបានគ្រប់គ្រាន់ចំពោះសេចក្តីសម្រេចឡើយ។ សេចក្តីសម្រេចដែលមានសំអាងហេតុត្រឹមត្រូវ យ៉ាងហោចណាស់ បានយោងទៅលើអង្គហេតុនានា ដែលបានបញ្ជាក់នៅក្នុងពាក្យសុំនីមួយៗ និងបានពិភាក្សានូវអង្គហេតុទាំងនេះ អនុលោមតាមវិធានផ្ទៃក្នុង[៣០]។

៩៤. គោលការណ៍ជាមូលដ្ឋាននៃយុត្តិធម៌តម្រូវថា ជនរងគ្រោះគួរត្រូវបានទទួលព័ត៌មានអំពីហេតុផលដែលបទឧក្រិដ្ឋដែលពួកគាត់បានជួបប្រទះ និងព្យសនកម្មដែលពួកគាត់បានទទួលរងនោះ ត្រូវបានបដិសេធដោយតុលាការថា ជាការបដិសេធដែលមិនអាចទទួលយកបានទេ។ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានស្នើឱ្យអង្គបុរេជំនុំជម្រះ ច្រានចោលដីកាសម្រេចរបស់ ស.ច.ស ទាក់ទិនទៅនឹងអ្នកដាក់ពាក្យសុំ D22/1901, D22/3180, D22/3183, D22/2057, D22/2154, D22/438, D22/3179, D22/3182, D22/816, D22/3177, D22/2157, D22/3181, D22/817, D22/2155, D22/2153, D22/404, D22/2156, D22/1136, D22/1969, D22/3175, D22/3176, D22/3178, D22/2158, D22/1092, និងD22/2758 ដោយផ្អែកលើមូលហេតុថា ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ត្រូវតែសម្រេចដោយដីកាដែលមានសំអាងហេតុ។

---

ដែលត្រូវបានកែប្រែសុំឱ្យមានការកោសលុបតាមវិធាន ៨១" ICC-01/04-01/06-779 ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៦ កថាខណ្ឌ ៣០។

លក្ខន្តិកៈ និងវិធាននៃនីតិវិធី និងភស្តុតាង បានបញ្ជាក់នៅត្រង់ចំណុចជាច្រើនអំពីសារៈសំខាន់នៃការផ្តល់ហេតុផលឱ្យបានគ្រប់គ្រាន់ ឧទាហរណ៍ នៅក្នុងបរិបទនៃបញ្ហាទាក់ទិននឹងភស្តុតាង វិធាន ៦៤(២) នៃវិធាននៃនីតិវិធី និងភស្តុតាង ដែលតម្រូវឱ្យអង្គជំនុំជម្រះ "ផ្តល់នូវហេតុផលចំពោះរាល់សេចក្តីសម្រេចទាំងអស់ដែលអង្គជំនុំជម្រះបានចេញ"។

[៣០] នៅក្នុងយុត្តិសាស្ត្ររបស់តុលាការ ICC សេចក្តីសម្រេចនីមួយៗទៅលើភាពអាចទទួលយកបាននៃអ្នកដាក់ពាក្យសុំ ត្រូវបានពិភាក្សាយ៉ាងលម្អិត ដោយមានការពន្យល់ដោយមានសំអាងហេតុសម្រាប់អ្នកដាក់ពាក្យសុំនីមួយៗ ក្នុងន័យថាតើបានៈ ជាជនរងគ្រោះត្រូវបានផ្តល់ជូន ឬមិនផ្តល់ជូន រួមទាំងហេតុផលយ៉ាងច្បាស់លាស់ចំពោះសេចក្តីសម្រេចនីមួយៗ។

យើងសូមស្នើថែមទៀតថា អ.ប.ជ គួរដាក់បញ្ចូលក្នុងការសម្រេចពីភាពអាចទទួលយកបាននៃដើមបណ្ដឹងរដ្ឋប្បវេណី D22/3824 នូវការពិចារណាលើចម្លើយបន្ថែមដែលមាននៅក្នុងឧបសម្ព័ន្ធ ខ។

## គ. មូលដ្ឋានទីមី នៃបណ្ដឹងឧទ្ធរណ៍

*ការិយាល័យសហចៅក្រមស៊ើបអង្កេតមានការភ័ន្តច្រឡំលើអង្គហេតុ និងអង្គច្បាប់ ហើយបានរំលោភបំពានទៅលើវិធាន៥៥(២) នៃវិធានផ្ទៃក្នុង ដោយកំហិតវិសាលភាពនៃកិច្ចស៊ើបសួរមកនៅត្រឹមតែកថាខណ្ឌ៣៧ ដល់កថាខណ្ឌ៧២ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម និង/ឬ ដោយតម្រូវថា ភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ត្រូវបង្ហាញពីទំនាក់ទំនងជាមួយនឹង "វិសាលភាពនៃកិច្ចស៊ើបសួរ" ពីព្រោះការិយាល័យនេះយល់វិធាននេះមិនបានត្រឹមត្រូវ។*

### ១. សហចៅក្រមស៊ើបអង្កេតបានកំហិតវិសាលភាពនៃកិច្ចស៊ើបសួរដោយមិនត្រឹមត្រូវ

៥៥. ដោយបដិសេធពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី សហចៅក្រមស៊ើបអង្កេត ("ស.ច.ស") បានកំហិតវិសាលភាពនៃកិច្ចស៊ើបសួរដោយមិនត្រឹមត្រូវ មកនៅត្រឹមតែអង្គហេតុដែលបានរៀបរាប់នៅក្នុងកថាខណ្ឌ៣៧ ដល់កថាខណ្ឌ៧២ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងអង្គហេតុដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម។

៥៦. នៅក្នុងកថាខណ្ឌ១២២ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ការិយាល័យសហព្រះរាជអាជ្ញាបានសម្រេច "បើកការស៊ើបសួរមួយ... ទៅលើអង្គហេតុទាំងឡាយដែលបានបញ្ជាក់នៅក្នុងកថាខណ្ឌ៣៧ ដល់កថាខណ្ឌ៧២"។ ប៉ុន្តែ នៅថ្ងៃទី០៨ ខែសីហា ឆ្នាំ២០០៨ រយៈពេលច្រើនជាងមួយឆ្នាំបន្ទាប់ពីបានទទួលដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទាំងមូល ស.ច.ស បានស្នើសុំការបញ្ជាក់បំភ្លឺពី ក.ស.ព "ទាក់ទងនឹងវិសាលភាពនៃកិច្ចស៊ើបសួរ"[៣១]។ ស.ច.ស បានស្នើឱ្យ ក.ស.ព ៖

[៣១] ដីកាបញ្ជូនរឿងឱ្យទៅពិនិត្យរបស់ ក.ស.ច.ស ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០០៨ ឯកសារលេខ D98។

"ធ្វើការបញ្ជាក់ថាតើការស៊ើបសួរ គួរតែរឹតត្បិតចំពោះតែអង្គហេតុដែលមានបញ្ជាក់នៅក្នុងកថាខណ្ឌ៣៧ ដល់កថាខណ្ឌ៧២ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងកថាខណ្ឌ៥ ដល់កថាខណ្ឌ២០ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមតែប៉ុណ្ណោះ ឬត្រូវតែពង្រីកទៅដល់គ្រប់អង្គហេតុទាំងអស់ ទោះបីជាអង្គហេតុនោះ មានលើកឡើង ឬមិនមានលើកឡើងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមក៏ដោយ នៅពេលណាដែលអង្គហេតុទាំងអស់នោះ អាចជួយដល់ការស៊ើបអង្កេតក្នុងការបង្ហាញថា ស្ថានភាពអង្គហេតុទាំងឡាយដែលមានបញ្ជាក់នៅក្នុងកថាខណ្ឌទាំងឡាយខាងលើ គឺជាបទឧក្រិដ្ឋដែលស្ថិតនៅក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬអាចជួយដល់ការស៊ើបអង្កេតអំពីការទទួលខុសត្រូវរបស់បុគ្គលណាមួយទៅលើឧក្រិដ្ឋកម្មទាំងនោះ"[៣២]។

៥៧. នៅថ្ងៃទី១៣ ខែសីហា ឆ្នាំ២០០៨ ក.ស.ព បានដាក់ចម្លើយតបរបស់ខ្លួនថា៖

"សហព្រះរាជអាជ្ញា សូមធ្វើការបញ្ជាក់ថា កិច្ចស៊ើបសួរដែលបានស្នើសុំ គឺមិនកម្រិតត្រឹមតែអង្គហេតុទាំងឡាយដូចបានកំណត់ជាក់លាក់នៅក្នុង កថាខណ្ឌ៣៧ ដល់កថាខណ្ឌ៧២ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងក្នុងកថាខណ្ឌ៥ ដល់កថាខណ្ឌ២០ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមប៉ុណ្ណោះទេ ក៏ប៉ុន្តែវាលាតសន្ធឹងដល់គ្រប់អង្គហេតុទាំងអស់ដែលបានលើកឡើងនៅក្នុងដីកាសន្និដ្ឋានទាំងពីរនេះទៀតផង *ឱ្យតែ*អង្គហេតុទាំងនេះជាជំនួយនៅក្នុងកិច្ចស៊ើបសួរ៖

ក. ធាតុផ្សំយុត្តាធិការនានាដែលចាំបាច់ដើម្បីកំណត់ថាតើ ស្ថានភាពនៃអង្គហេតុនានាដូចមានចែងជាក់លាក់ នៅក្នុងកថាខណ្ឌ៣៧ ដល់កថាខណ្ឌ៧២ និងកថាខណ្ឌ៥ ដល់កថាខណ្ឌ២០ រួមបង្កើតបានទៅជាបទឧក្រិដ្ឋផ្សេងៗដែលស្ថិតនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក ដែរឬទេ? ឬ

---

[៣២] *ដូចខាងលើ។*

ខ. ទម្រង់នៃការទទួលខុសត្រូវ របស់ជនសង្ស័យទាំងឡាយដែលមានឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ"[៣៣]។

៥៨. ការកំហិតវិសាលភាពនៃកិច្ចស៊ើបសួររបស់ ស.ច.ស មកនៅត្រឹមតែអង្គហេតុដែលបានរៀបរាប់នៅក្នុងកថាខណ្ឌ៣៧ ដល់កថាខណ្ឌ៧២ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ គឺជាកំហុសអង្គហេតុ និងអង្គច្បាប់យ៉ាងច្បាស់មួយ ពីព្រោះថា តាមរយៈចម្លើយតបយ៉ាងច្បាស់របស់ខ្លួន ក.ស.ព បានបញ្ជាក់ទៅដល់ ក.ស.ច.ស ថា វិសាលភាពនៃកិច្ចស៊ើបសួរ លាតសន្ធឹងដល់រាល់អង្គហេតុទាំងឡាយណា ដែលបានកំណត់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម លាតសន្ធឹងដល់រាល់កិច្ចស៊ើបសួរទាំងឡាយណា ដែលជួយដល់ការបង្កើតនូវធាតុផ្សំយុត្តាធិការនៃបទឧក្រិដ្ឋណាមួយ និងលាតសន្ធឹងដល់រាល់កិច្ចស៊ើបសួរទាំងឡាយណា ដែលជួយដល់ការបង្ហាញពីទម្រង់នៃការទទួលខុសត្រូវរបស់បុគ្គល។

៥៩. បន្ថែមលើនេះ មិនមានមូលដ្ឋានណាមួយនៅក្នុងវិធានផ្ទៃក្នុង ឬច្បាប់កម្ពុជា ដែលចែងពីការរឹតត្បិតវិសាលភាពនៃកិច្ចស៊ើបសួរ ឱ្យមកនៅត្រឹមតែអង្គហេតុដែលជាផ្នែកមួយនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរនោះទេ[៣៤]។ អនុលោមតាមមាត្រា១២៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា និងវិធាន៥៥(២) នៃវិធានផ្ទៃក្នុង ស.ច.ស "...ត្រូវស៊ើបអង្កេតតែទៅលើអង្គហេតុទាំងឡាយណា ដែលមានរៀបរាប់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរតែប៉ុណ្ណោះ..."។ បទប្បញ្ញត្តិនេះសំដៅទៅលើ *អង្គហេតុទាំងឡាយណាជារួម* ដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។

---

[៣៣] សេចក្តីឆ្លើយតបរបស់សហព្រះរាជអាជ្ញា ទៅកាន់សំណើរបស់សហចៅក្រមស៊ើបអង្កេតសុំការបញ្ជាក់បំភ្លឺពីវិសាលភាពនៃកិច្ចស៊ើបសួរ ដែលបានស្នើឡើងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០០៨ ឯកសារលេខ D98/I កថាខណ្ឌ២។

[៣៤] សេចក្តីព្រាងនៃវិធានផ្ទៃក្នុង មានឥទ្ធិពលស្រដៀងគ្នាទៅនឹងមាត្រាពាក់ព័ន្ធ មាត្រា៤៤, មាត្រា១២៤ និងមាត្រា១២៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា។

៦០. នៅក្នុងសាលដីកាសម្រេចជាឯកច្ឆ័ន្ទមួយរបស់ខ្លួន ចុះថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០១០ អ.ប.ជ បាន សម្រេចគាំទ្រថា "សហព្រះរាជអាជ្ញា គឺជាភាគីដែលទទួលខុសត្រូវក្នុងការកំណត់វិសាលភាពនៃ កិច្ចស៊ើបសួរ"[៣៥]។

## ២. ស.ច.ស មានកំហុសដែលបានតម្រូវថា ត្រូវមានទំនាក់ទំនងរវាងព្យសនកម្មដែលកើតឡើង ជាមួយនឹងការអនុវត្តមិនត្រឹមត្រូវរបស់ខ្លួនចំពោះ "វិសាលភាពនៃកិច្ចស៊ើបសួរ"

៦១. នៅក្នុងសាលដីការបស់ខ្លួន ដែលសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចបដិសេធ ចំពោះពាក្យសុំលេខ D22/288 អ.ប.ជ បានសម្រេចបន្ថែមថា អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើម បណ្តឹងរដ្ឋប្បវេណី *អាច*ទទួលយកបាន បើទោះជាទីតាំងឧក្រិដ្ឋកម្ម ដែលខ្លួនបានទទួលរងការឈឺ ចាប់នោះ មិនមានរៀបរាប់នៅក្នុងសេចក្តីប្រកាសព័ត៌មានរបស់ ក.ស.ច.ស នៅថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០០៩ ដែលស្ថិតនៅក្នុង "វិសាលភាពនៃកិច្ចស៊ើបសួរ" ឬមិនមាននៅក្នុងកថាខណ្ឌ៣៧ ដល់កថាខណ្ឌ៧២នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬជាអង្គហេតុដែលបានចែងនៅក្នុង ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម[36]ក៏ដោយ។ នៅក្នុងករណីនេះ អ.ប.ជ បានទទួល ស្គាល់យ៉ាងមានប្រសិទ្ធភាពថា អង្គហេតុដែលស្ថិតនៅក្រោមកិច្ចស៊ើបសួរ ដូចបានកំណត់ដោយ ក.ស.ព មានលក្ខណៈទូលំទូលាយច្រើនជាងអង្គហេតុនានា ដែលប្រកាសដោយ ស.ច.ស។

៦២. ចៅក្រមចំនួនបីរូបនៃអង្គបុរេជំនុំជម្រះ ដែលជាសំឡេងភាគច្រើន បានយល់ស្របថា ម្ចាស់ បណ្តឹងឧទ្ធរណ៍ "ពិតជាបានលើកឡើងចំចំណុចសមហេតុផលនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យ

---

[៣៥] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ប្រឆាំងនឹងដីកាសម្រេចបដិសេធសំណើសុំ ស្តាប់ចម្លើយបុគ្គលដែលមានរាយឈ្មោះនៅក្នុងសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរស្តីពីការរៀបការដោយបង្ខំ និងការ បាត់ខ្លួនដោយបង្ខំ ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១០ ឯកសារលេខ D310/1/3 កថាខណ្ឌ៣៨។

[36] អ.ប.ជ "សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើការប្រកាសថា ពាក្យសុំតាំងខ្លួនជាដើមបណ្តឹង រដ្ឋប្បវេណី D22/288 មិនអាចទទួលយកបាន" ចុះថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០១០ ឯកសារលេខ D364/1/3។

ស៊ើបសួរ ពោលគឺត្រង់កថាខណ្ឌ៨៨(ឃ)"[៣៧]។ អ.ប.ជ ខ្លួនឯងផ្ទាល់បានពិចារណាទៅលើកថាខណ្ឌ៨៨(ង)[៣៨] នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដើម្បីសម្រេចថាតើទំនាក់ទំនងណាមួយអាចត្រូវបានបង្កើតឡើងរវាង "ព្យសនកម្មដែលខ្លួនទទួលរង គឺជាផលវិបាកដោយផ្ទាល់នៃបទល្មើស យ៉ាងហោចណាស់មួយក្នុងចំណោមបទល្មើសទាំងឡាយ ដែលបានចោទប្រកាន់ទៅលើជនត្រូវចោទ"[៣៩]។ ជាពិសេស សេចក្តីសម្រេចនេះបានអះអាងថា "បទឧក្រិដ្ឋដែលបានចោទប្រកាន់ឡើង" រួមមានទាំងបទឧក្រិដ្ឋទាំងឡាយណា ដែលបានរៀបរាប់នៅក្នុងកថាខណ្ឌ៣៧ ដល់កថាខណ្ឌ៧២ និងបទឧក្រិដ្ឋទាំងឡាយណាដែលត្រូវបានចោទប្រកាន់ទៅលើជនត្រូវចោទ នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ នៅក្រោមផ្នែក "ការដឹងឮ និងការចូលរួម"[៤០]។

៦៣. មតិយោបល់ ដែលជាសំឡេងភាគតិច របស់ចៅក្រម Downing និងចៅក្រម ប្រាក់ គឹមសាន ក៏បានគាំទ្រថា "ការពន្យល់ពីសំអាងហេតុរបស់មតិភាគច្រើន ពីការដកឋានៈដើមបណ្តឹងរដ្ឋប្បវេណីរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ ត្រូវបានបញ្ជាក់យ៉ាងពេញលេញ ហើយបានផ្តល់តម្លៃដល់ម្ចាស់បណ្តឹងឧទ្ធរណ៍ និងយល់បញ្ហាទាំងឡាយដែលស្ថិតនៅក្រោមការពិចារណានេះបានកាត់តែច្រើន"[៤១]។

៦៤. ផ្នែក "ការចូលរួម និងការដឹងឮ" នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ពណ៌នាអំពីអង្គហេតុនានា ដែលបង្កើតជាមូលដ្ឋានសម្រាប់ការសម្រេចលើទម្រង់នៃការទទួលខុសត្រូវ

---

[៣៧] អ.ប.ជ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើការប្រកាសថា ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី D22/288 មិនអាចទទួលយកបាន ចុះថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០១០ ឯកសារលេខ D364/1/3 កថាខណ្ឌ៣ នៃផ្នែកមតិយោបល់របស់ចៅក្រម ន័យ ថុល, ចៅក្រម Catherine Marchi-Uhel និងចៅក្រម ហួត វុទ្ធី។

[៣៨] *ដូចលេខជើងទំព័រខាងលើ* កថាខណ្ឌ៥។

[៣៩] *ដូចលេខជើងទំព័រខាងលើ* កថាខណ្ឌ២។

[៤០] កថាខណ្ឌ៨១ និងផ្នែករងចំណុច (ក)-(ឆ) ករណី នួន ជា, កថាខណ្ឌ៨៨ និងផ្នែករងចំណុច (ក)-(ឆ) ករណី អៀង សារី, កថាខណ្ឌ៩៧ និងផ្នែករងចំណុច (ក)-(ឆ), កថាខណ្ឌ១០៣ ចំណុច (ក)-(គ) ករណី អៀង ធីរិទ្ធ និងកថាខណ្ឌ១១៣ ជាមួយនឹងផ្នែករងចំណុច (ក)-(ខ) ករណី កាំង ហ្គេកអ៊ាវ។

[៤១] *ដូចលេខជើងទំព័រខាងលើ* កថាខណ្ឌ១៦។

របស់ជនត្រូវចោទម្នាក់ៗ ដោយរួមទាំងអំពើជាក់លាក់ ដែលជនត្រូវចោទម្នាក់ៗបានប្រព្រឹត្ត ទាក់ទងនឹងឧក្រិដ្ឋកម្មដែលបានរៀបរាប់យ៉ាងជាក់លាក់ នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដោយអះអាងថា ផ្នែកនេះបង្ហាញពី "ភ័ស្តុតាងនៃបទឧក្រិដ្ឋ ដែលបានរៀបរាប់នៅក្នុងកថាខណ្ឌ ៣៧ ដល់កថាខណ្ឌ៧២ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ"[៤២]។ ឧទាហរណ៍ ចំពោះករណី អៀង សារី កថាខណ្ឌ៨៨ និងកថាខណ្ឌ៨៨(ង) នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ រៀបរាប់ថា៖

> *"អៀង សារី ក្នុងឋានៈជាសមាជិកគណៈអចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជា ឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការបរទេស គាត់បានជំរុញ ញុះញង់ ជួយសម្រួល លើកទឹកចិត្ត និង/ឬ បណ្តែតបណ្តោយឱ្យមានការប្រព្រឹត្តិឧក្រិដ្ឋកម្មទាំងឡាយ ដូចមានរៀបរាប់ក្នុងកថាខណ្ឌ ៣៧-៧២។ ភ័ស្តុតាងបញ្ជាក់ពីការចូលរួមក្នុងឧក្រិដ្ឋកម្មរបស់ អៀង សារី ត្រូវបានរៀបរាប់ពិស្តារដូចខាងក្រោមនេះ៖*
>
> *[...]ង. អៀង សារី បានដឹងនិងបានជួយសម្រួលពលកម្មដោយបង្ខំទ្រង់ទ្រាយធំ ការឃុំខ្លួនមនុស្សដោយខុសច្បាប់ ការបង្កើតលក្ខខណ្ឌអមនុស្ស-ធម៌ អំពើទារុណកម្ម និងការប្រហារជីវិតក្រៅច្បាប់ទ្រង់ទ្រាយធំទៅលើបុគ្គលិកក្រសួងការបរទេស អតីតបុគ្គលិករាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា និងមន្ត្រីការទូតទាំងឡាយ នៅតាមមន្ទីរឃុំឃាំងនានា ដូចជាមន្ទីរ ម-១ របស់ក្រសួង នៅច្រាំងចំរេះ និងបឹងត្របែក..."*[៤៣]។

៦៥. ច្រាំងចំរេះ និងបឹងត្របែក មិនមែនជាទីតាំងឧក្រិដ្ឋកម្ម ដែលមានរៀបរាប់នៅក្នុងកថាខណ្ឌ៣៧ ដល់កថាខណ្ឌ៧២ ទេ។ ហេតុដូច្នេះ ការយោងរបស់ អ.ប.ជ ទៅកាន់កថាខណ្ឌ៨៨ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងទម្ងន់ដែល អ.ប.ជ ផ្តល់ទៅឱ្យកថាខណ្ឌនេះ បង្ហាញឱ្យឃើញថា ភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី មិនត្រូវបានរឹតត្បិតមកនៅត្រឹមតែចំពោះទីតាំងឧក្រិដ្ឋកម្ម និងអំពើជាក់លាក់ ដូចបានរៀបរាប់នៅក្នុងកថាខណ្ឌ៣៧ ដល់

---

[៤២] កថាខណ្ឌ៨១ និងផ្នែករងចំណុច (ក)-(ឆ) ករណី នួន ជា, កថាខណ្ឌ៨៨ និងផ្នែករងចំណុច (ក)-(ឆ) ករណី អៀង សារី, កថាខណ្ឌ៩៧ និងផ្នែករងចំណុច (ក)-(ឆ), កថាខណ្ឌ១០៣ ចំណុច (ក)-(គ) ករណី អៀង ធីរិទ្ធ និងកថាខណ្ឌ១១៣ ជាមួយនឹងផ្នែករងចំណុច (ក)-(ខ) ករណី កាំង ហ្គេកអ៊ាវ។

[៤៣] កថាខណ្ឌ៨៨ ចំណុច (ង) នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។ លេខជើងទំព័រត្រូវបានលុបចេញ។

កថាខណ្ឌ៧២ នោះទេ ប៉ុន្តែ នេះក៏ជាការរួមបញ្ចូលនូវអង្គហេតុ ដែលមាននៅក្នុងកថាខណ្ឌផ្សេងទៀត ក្រៅពីកថាខណ្ឌ៧២ ផងដែរ ដែលបានរៀបរាប់ពី "ភ័ស្តុតាងនៃការចូលរួមនៅក្នុងឧក្រិដ្ឋកម្ម ដូចបានពណ៌នានៅក្នុងកថាខណ្ឌ៣៧-៧២"[៤៤]។

៦៦. ឥទ្ធិពលនៃសាលដីការបស់ អ.ប.ជ មួយនេះ គឺជាការសម្រេចគាំទ្រពីតុលាការឧទ្ធរណ៍ ដែលថា (i) វិសាលភាពនៃកិច្ចស៊ើបសួរ មានលក្ខណៈទូលំទូលាយជាងទីតាំង និងអំពើ ដែលបានរៀបរាប់នៅក្នុងសេចក្ដីប្រកាសព័ត៌មានរបស់ ក.ស.ច.ស និងនៅក្នុងកថាខណ្ឌ៣៧ ដល់កថាខណ្ឌ៧២ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងអង្គហេតុនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម **និង/ឬ** (ii) ភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី មិនផ្អែកទៅលើទំនាក់ទំនងណាមួយ ទៅនឹង "វិសាលភាពនៃកិច្ចស៊ើបសួរ" ដូចដែល ក.ស.ច.ស យល់ឃើញអំពីវិសាលភាពនោះទេ។ សហាមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី សូមសន្និដ្ឋានថា ស.ច.ស បានកំហិត "វិសាលភាពនៃកិច្ចស៊ើបសួរ" ដោយមិនត្រឹមត្រូវ ឱ្យមកនៅត្រឹមតែទីតាំងឧក្រិដ្ឋកម្ម និងអំពើទាំងឡាយណាប្រឆាំងទៅនឹងក្រុមនានា ដែលមានរៀបរាប់ពីចន្លោះកថាខណ្ឌ៣៧ និងកថាខណ្ឌ៧២ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។ ស.ច.ស បកស្រាយវិធាន៥៥(២) មិនបានត្រឹមត្រូវ ហើយមានកំហុសនៅក្នុងការអនុវត្តរបស់ខ្លួន ចំពោះវិសាលភាពនៃកិច្ចស៊ើបសួរ ដែល ក.ស.ព បានបញ្ជូនទៅកាន់ ក.ស.ច.ស។

---

[៤៤] ឧទាហរណ៍មួយទៀត គឺនៅត្រង់កថាខណ្ឌ១០៣ ចំណុច (គ)(v) ទាក់ទងនឹងករណី អៀង ធីរិទ្ធ ដោយរៀបរាប់ថា "*អៀង ធីរិទ្ធ បានចូលរួមរៀបចំផែនការ បានណែនាំ បានសម្របសម្រួល និងបានបញ្ជាឱ្យមានការបោសសម្អាតជាទូទៅ ដែលបណ្ដាលឱ្យមានការចាប់ខ្លួន និងឃុំឃាំងដោយខុសច្បាប់ អំពើឃោរឃៅអមនុស្សធម៌ និង/ឬ ពលកម្មដោយបង្ខំ... ទៅលើបុគ្គលិករបស់ក្រសួងសង្គមកិច្ច... ការបញ្ជូនបុគ្គលិកក្រសួងទៅការដ្ឋានពលកម្មលត់ដំ ជាពិសេស... ការដ្ឋានផ្លូវជាតិលេខ ៤ នៅពេជ្រនិល*"។ ការដ្ឋានផ្លូវជាតិលេខ ៤ នៅពេជ្រនិល មិនត្រូវបានរៀបរាប់ថាជាការដ្ឋានមួយស្ថិតនៅក្រោមការស៊ើបអង្កេត នៅក្នុងកថាខណ្ឌ ៣៧-៧២ នោះទេ។ ប៉ុន្តែ អៀង ធីរិទ្ធ ត្រូវបានចោទប្រកាន់ថាបានបញ្ជូនបុគ្គលិកឱ្យទៅធ្វើការនៅទីនោះ។ អ្នកដាក់ពាក្យសុំណាមួយ ដែលមកពីក្រសួងសង្គមកិច្ច ដែលត្រូវបានបង្ខំឱ្យធ្វើការនៅពេជ្រនិល អាចត្រូវបានប្រកាសថាទទួលយកបាន ប្រសិនបើពួកគេបានបង្ហាញយ៉ាងជោគជ័យពីទំនាក់ទំនងដោយផ្ទាល់មួយរវាងព្យសនកម្ម ដែលពួកគេបានទទួលរង ជាមួយនឹងអង្គហេតុនេះ ដែលស្ថិតនៅក្នុងវិសាលភាពនៃកិច្ចស៊ើបសួរដែលត្រូវបានបញ្ជាក់បំភ្លឺដោយ ក.ស.ព។

៦៧. ការសម្រេចទាំងនេះ បង្កើតឱ្យមានយុត្តិសាស្ត្រសំខាន់ៗ ដែល អ.ប.ជ គួរតែសម្រេចគាំទ្រនៅក្នុងសំណុំរឿងនេះ។ មេធាវីដើមបណ្តឹងរដ្ឋប្បវេណីសូមស្នើឱ្យ អ.ប.ជ ច្រានចោលនូវដីកាសម្រេចរបស់ ស.ច.ស ដែលបានប្រកាសថា អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាំងនេះ មិនអាចទទួលយកបាន ដោយហេតុថា ពួកគេមិនបង្ហាញឱ្យឃើញពីទំនាក់ទំនងរវាងព្យសនកម្មដែលបានកើតឡើង ជាមួយនឹងទីតាំងដែលស្ថិតនៅក្រោម "វិសាលភាពកិច្ចស៊ើបសួរ"។

៦៨. ជាបន្តទៀតនេះ បណ្តឹងឧទ្ធរណ៍នេះងាកទៅធ្វើការបង្ហាញថា ស.ច.ស មានការភ័ន្តច្រឡំ នៅពេលកំណត់ថា ពាក្យសុំ D22/2758 (អ្នកដាក់ពាក្យសុំជនជាតិខ្មែរមួយរូបក្នុងខេត្តកំពង់ឆ្នាំង) មិនអាចទទួលយកបាន ដោយសារតែ ក.ស.ច.ស អនុវត្តវិសាលភាពនៃកិច្ចស៊ើបសួរ ដែល ក.ស.ព បានបញ្ជូនទៅឱ្យ មិនបានត្រឹមត្រូវ។

## ៣. ស.ច.ស មានការភ័ន្តច្រឡំ នៅពេលកំណត់ថាមិនអាចទទួលយកអ្នកដាក់ពាក្យសុំ ដោយសារការអនុវត្តវិសាលភាពនៃកិច្ចស៊ើបសួរដោយមិនត្រឹមត្រូវ

៦៩. ដោយសារ បើពិនិត្យទៅលើហេតុផលថា "ព្យសនកម្មមិនមានទំនាក់ទំនងនឹងអង្គហេតុស្ថិតក្រោមការស៊ើបសួរ" យើងមានការលំបាកក្នុងការកំណត់ថាតើបញ្ហានោះគឺជាការបង្ហាញពីព្យសនកម្ម ឬក៏ទំនាក់ទំនងនៃព្យសនកម្ម (ដែលបានបង្ហាញ) ជាមួយនឹង "អង្គហេតុស្ថិតក្រោមការស៊ើបអង្កេត" នោះ ផ្នែកខាងក្រោមនៃបណ្តឹងឧទ្ធរណ៍ទាក់ទងនឹងពាក្យសុំ D22/2758 នឹងលើកឡើងពីបញ្ហាទាក់ទងនឹងអង្គហេតុដែលលើកឡើងដោយអ្នកដាក់ពាក្យសុំ ហើយស្ថិតនៅក្រោមវិសាលភាពនៃកិច្ចស៊ើបសួររបស់ ក.ស.ព ព្រមទាំងការប៉ះពាល់ពាល់នៃអង្គហេតុទាំងនេះ លើអ្នកដាក់ពាក្យសុំ ៖ ពោលគឺអត្ថិភាពនៃព្យសនកម្មផ្ទាល់ខ្លួនផ្ទាល់ និងជាលក្ខណៈបុគ្គល។

៧០. អ្នកដាក់ពាក្យសុំ D22/2758 លើកឡើងពីអង្គហេតុ ស្ថិតក្រោមការស៊ើបអង្កេតក្នុងទម្រង់ព័ត៌មានជនរងគ្រោះដើម និងចម្លើយបន្ថែមរបស់ខ្លួន ចុះថ្ងៃទី៤ ខែឧសភា ឆ្នាំ២០០៩។ ឪពុកម្តាយរបស់គាត់ត្រូវបានចោទប្រកាន់ថាជា "សេអ៊ីអា ក្នុងរបប លន់ នល់" ហើយត្រូវបានបញ្ជូនទៅកន្លែង កប់សាកសព [redacted] ក្នុងខេត្តកំពង់ឆ្នាំង ប្រហែលជានៅខែកក្កដា ឆ្នាំ១៩៧៥ ហើយក្រោយមកក៏ត្រូវ

បានសម្លាប់[45] នៅទីនោះ។ ឪពុកម្តាយរបស់អ្នកដាក់ពាក្យសុំ មិនមែនជាភ្នាក់ងារសេអ៊ីអាទេ ប៉ុន្តែត្រូវបានគេចោទថាជាភ្នាក់ងារ សេអ៊ីអា ពីព្រោះ មុនឆ្នាំ១៩៧៥ ឪពុកម្តាយគាត់គឺជាអ្នកមានជាងកសិករផ្សេងៗទៀតក្នុងតំបន់នោះ[46]។ អាស្រ័យហេតុនេះ ឪពុកម្តាយរបស់គាត់ត្រូវបានគេចាត់ទុកជាអ្នកធ្វើការឱ្យរបប [47]លន់ នល់។ ទោះបីជាឪពុកម្តាយរបស់គាត់មិនមែនជាភ្នាក់ងារ សេអ៊ីអាក៏ដោយ ឬមិនមែនជាមន្ត្រីអ្វីក្នុងរបប លន់ នល់ក៏ដោយ ក៏ពួកខ្មែរក្រហមចាត់ទុកឪពុកម្តាយរបស់អ្នកដាក់ពាក្យសុំជាភ្នាក់ងារ សេអ៊ីអា ហើយសម្លាប់ដោយសារបញ្ហានេះ។

៧១. កថាខណ្ឌ ១២(ក) នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ លើកឡើងថា បក្សកុម្មុយនីស្តកម្ពុជា "បានស្រាវជ្រាវរកយ៉ាងសកម្មអតីតមន្ត្រីរបបសាធារណរដ្ឋខ្មែរ"[48]។ ដីកាដំណោះស្រាយរបស់ ក.ស.ច.ស ធ្វើការបញ្ជាក់បន្ថែមពីការកំណត់គោលដៅលើមន្ត្រីរបបសាធារណរដ្ឋខ្មែរ ក្នុងអំឡុងពេលទាំងអស់នៃការគ្រប់គ្រងរបស់ពួកខ្មែរក្រហម[49]។ ឪពុកម្តាយរបស់អ្នកដាក់ពាក្យបានរងការធ្វើទុក្ខបុកម្នេញ និងត្រូវបានសម្លាប់ ដោយពួកខ្មែរក្រហមយល់ឃើញថាមានទំនាក់ទំនងជាមួយនឹងរបប លន់ នល់ ដែលនេះពិតជាអង្គហេតុច្បាស់លាស់ស្ថិតក្រោមការស៊ើបសួរ ដូចត្រូវបានបញ្ជាក់បន្ថែមពីដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាដំណោះស្រាយរបស់ ក.ស.ច.ស។ ព្យសនកម្ម ដែលអ្នកដាក់ពាក្យសុំទទួលរង នៅពេលដែលឪពុកម្តាយរបស់ខ្លួនត្រូវបានគេសម្លាប់ គឺជាព្យសនកម្មផ្ទាល់ និងជាលក្ខណៈបុគ្គលយ៉ាងច្បាស់លាស់។

៧២. ឪពុកម្តាយរបស់ដាក់ពាក្យសុំ ត្រូវបានពួកខ្មែរក្រហមកំណត់ថា ជា"ពួកនាយទុន" និង "ពួកសក្តិភូមិ" និងបានរងការធ្វើទុក្ខបុកម្នេញប្រឆាំង ដោយសារតែពួកគាត់មានទ្រព្យសម្បត្តិ និងកម្រិតជីវភាពរស់នៅខ្ពស់។ វិសាលភាពនៃកិច្ចស៊ើបសួរ ដែល ក.ស.ព បានបញ្ជូនទៅឱ្យ ក.ស.ច.ស មាន

---

[45] សម្ភាសជាមួយលោកស្រី [redacted] ដោយមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី៥ ខែឧសភា ឆ្នាំ២០០៩ ឯកសារ D22/2758a ។

[46] ដូចខាងលើ។

[47] ដូចខាងលើ។

[48] ក.ស.ព "ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ" ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ ឯកសារ D3 កថាខណ្ឌ១២ក។

[49] ក.ស.ច.ស "ដីកាដំណោះស្រាយ" ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០ ឯកសារលេខ D427 កថាខណ្ឌ ២០៥ កថាខណ្ឌ ២០៨ កថាខណ្ឌ ២០៩។

00634022



រៀបរាប់ពីការធ្វើទុក្ខបុកម្នេញរបស់ពួកខ្មែរក្រហម លើ "ពួកនាយទុន" និង "ពួកសក្តិភូមិ"។ កថាខណ្ឌ ១២(ខ)នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដែលបានបញ្ជូនឱ្យស៊ើបសួរ លើកឡើងថា ៖

*បក្សកុម្មុយនិស្តកម្ពុជា មានគោលនយោបាយដ៏ឧក្រិដ្ឋ និងជាក់លាក់មួយក្នុងការលុបបំបាត់ចោល "ពួកសក្តិភូមិ" "ពួកនាយទុន" និង "ពួកគហបតី"។ បក្សបានធ្វើការប្រកាសថា ដោយសារតែប្រភពនៃវណ្ណៈរបស់ខ្លួន ពួកសក្តិភូមិ និងពួកនាយទុនមិនអាចធ្វើការលត់ដំបានទេ ហើយបានធ្វើការអះអាងថា ខ្មាំងស៊ីរូងផ្ទៃក្នុងនឹងមិនអាចបញ្ឈប់បានទេ ដរាបណា វណ្ណៈប្រតិកិរិយាទាំងនេះ នៅមិនទាន់លុបបំបាត់ទាំងស្រុងនោះ[50] ។*

៧៣. ដីកាដំណោះស្រាយរបស់ ស.ច.ស ពន្យល់ថា "គោលបំណងមួយក្នុងចំណោមគោលបំណងផ្សេងទៀតនៃគោលនោយបាយនេះគឺបង្កើតឡើងនូវសង្គមមួយ ដែលគ្មានសាសនា និងគ្មានវណ្ណៈដោយគ្មានការបែងចែកវណ្ណៈ លុបបំបាត់ចោលភាពខុសគ្នាទាំងអស់[51]ផ្នែកជាតិពន្ធុ ជនជាតិ សាសនា វណ្ណៈ និងវប្បធម៌"។

៧៤. ពួកខ្មែរក្រហមបានធ្វើទុក្ខបុកម្នេញលើអ្នកដាក់ពាក្យសុំ និងគ្រួសាររបស់គាត់ ដោយចោទប្រកាន់ថា ឪពុកម្តាយរបស់គាត់គឺជា"ពួកនាយទុន" និង "ពួកសក្តិភូមិ" និងជា សេ អ៊ី អា របស់លន់ នល់។ បន្ទាប់ពីឪពុកម្តាយរបស់អ្នកដាក់ពាក្យសុំត្រូវបានចាប់ខ្លួន និងយកទៅសម្លាប់ភ្លាម ប្រធានភូមិបាននាំសមាជិកគ្រួសារ១០នាក់ផ្សេងទៀតក្នុងគ្រួសារអ្នកដាក់ពាក្យសុំទៅសម្លាប់ដោយចោទប្រកាន់ថាមានទំនាក់ទំនាក់ទំនងជាមួយនឹងឪពុកម្តាយរបស់អ្នកដាក់ពាក្យសុំ[52]។ អ្នកដាក់ពាក្យសុំបានទទួលរងព្យសនកម្មផ្ទាល់ និងជាលក្ខណៈបុគ្គលពីការស្លាប់សមាជិកគ្រួសាររបស់ខ្លួន រួមទាំងម្តាយមីង និងឪពុកមារបស់ខ្លួនផង[53]។

---

[50] ក.ស.ព "ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ" ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ ឯកសារ D3 កថាខណ្ឌ ១២(ខ)។

[51] ក.ស.ច.ស "ដីកាដំណោះស្រាយ" ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០ ឯកសារលេខ D427 កថាខណ្ឌ ២០៧។

[52] បទសម្ភាសន៍ជាមួយ [redacted] ចុះថ្ងៃ៤ ខែឧសភា ឆ្នាំ២០០៩ ឯកសារលេខ D22/2758a។

[53] ដូចខាងលើ។

៧៥. ដីកាសម្រេចខេត្តកំពង់ឆ្នាំងលើកឡើងក្នុងកថាខណ្ឌ ១៤(ក)(i)ថា ក្នុងករណីសមាជិកគ្រួសារធំ "ការសន្មតទុកជាមុននឹងត្រូវចាត់ទុកជាកត្តាមួយយ៉ាងសំខាន់ ក្នុងករណីដែលជនរងគ្រោះផ្ទាល់បានស្លាប់ ឬបាត់ខ្លួនបណ្តាលមកពីផលវិបាកផ្ទាល់នៃអង្គហេតុនានា ដែលស្ថិតក្រោមកិច្ចស៊ើបសួរ"។ ដូចនេះ ព្យសនកម្មដោយបានសន្មតជាមុន ដែលបានកើតឡើងចំពោះអ្នកដាក់ពាក្យសុំបណ្តាលមកពីការស្លាប់សមាជិកគ្រួសារធំ ត្រូវតែចាត់ទុកជាកត្តាកំណត់ដ៏សំខាន់។

៧៦. អ្នកដាក់ពាក្យសុំខ្លួនឯងបានទទួលរងព្យសនកម្មផ្ទាល់ និងជាលក្ខណៈបុគ្គល ដោយសារតែគាត់ជាអ្នករងគ្រោះផ្ទាល់ពីការធ្វើទុក្ខបុកម្នេញដែលគ្រួសាររបស់គាត់បានឆ្លងកាត់។ បន្ទាប់ពីពួកខ្មែរក្រហមបានសម្លាប់ឪពុកម្តាយរបស់គាត់ និងសមាជិកគ្រួសារចំនួន១០នាក់មក អ្នកដាក់ពាក្យសុំអាចរួចផុតពីការស្លាប់ ពីព្រោះគាត់បានឱ្យកម្មាភិបាលខ្មែរក្រហមនូវវត្ថុមានតម្លៃ ដូចជា មាស និងប្រាក់[54]។ ទោះបីអ្នកដាក់ពាក្យសុំបានរួចពីការស្លាប់ក្តី ក៏គាត់ត្រូវបានចាប់ដាក់ក្នុងមន្ទីរឃុំឃាំងភ្លាមៗ និងស្ថិតក្រោមការត្រួតពិនិត្យយ៉ាងតឹងតែងនៅជិត[redacted] ខេត្តកំពង់ឆ្នាំង[55]។ លោកស្រីបានជាប់មន្ទីរឃុំឃាំងប្រហែល៤ ឆ្នាំ និងត្រូវបង្ខំឱ្យធ្វើការ ដូចជា ជីកប្រឡាយជាដើម[56]។ គាត់ត្រូវបានបង្ខំឱ្យធ្វើការងារច្រើនជាងអ្នកទោសផ្សេងៗមួយទ្វេជាពីរ ដោយសារតាមការយល់ឃើញរបស់ពួកគេ ឪពុកម្តាយរបស់គាត់មានទំនាក់ទំនងជាមួយនឹងនាយទុន និង លន់ នល់[57] ។

៧៧. អ្នកដាក់ពាក្យសុំបានឃើញអ្នកទោសផ្សេងៗទៀតក្នុងមន្ទីរឃុំឃាំងជាមួយគ្នា ដែលត្រូវបានគេនាំទៅសម្លាប់នៅ[redacted] ដោយសារតែមិនអាចបំពេញការងារតាមការកំណត់ ។ ដោយឃើញដូចនេះ អ្នកដាក់ពាក្យសុំដឹងថា គាត់ក៏អាចនឹងត្រូវគេយកទៅសម្លាប់ដែរ ប្រសិនបើគាត់មិនអាចបំពេញការងារតាមការកំណត់ទេនោះ[58]។ អ្នកដាក់ពាក្យសុំបានទទួលរងការឈឺចាប់រាងកាយ និងការប៉ះទង្គិចផ្លូវចិត្តយ៉ាងធ្ងន់ធ្ងរ ដោយសារការធ្វើការងារដោយបង្ខំ និងការប្រឈមនឹងការសម្លាប់ក្រោមកណ្តាប់ដៃរបស់ពួកខ្មែរក្រហម។ ដោយសារអ្នកដាក់ពាក្យសុំត្រូវបានជាប់ឃុំឃាំង និងរងការបង្ខំឱ្យ

---

[54] ដូចខាងលើ។

[55] សេចក្តីសង្ខេបនៃព័ត៌មានបន្ថែម[redacted] ឯកសារលេខ D22/2758b។

[56] បទសម្ភាសន៍ជាមួយ លោកស្រី[redacted] ថ្ងៃទី៤ ខែឧសភា ឆ្នាំ២០០៩ ឯកសារលេខ D22/2758a ។

[57] ដូចខាងលើ។

[58] ដូចខាងលើ។

ធ្វើការធ្ងន់ជាងអ្នកដទៃ និងដោយផ្ទាល់ ដោយសារការចោទប្រកាន់ឪពុកម្ដាយរបស់គាត់ថាជាពួកនាយទុន និងអតីតមន្ត្រីជាន់ខ្ពស់ក្នុងរបប លន់ នល់ ព្យសនកម្មដែលគាត់បានទទួលរង មានទំនាក់ទំនងនឹងអង្គហេតុស្ថិតក្រោមការស៊ើបសួរ។

៧៨. ស.ច.ស មានការភ័ន្តច្រឡំលើអង្គហេតុ និងអង្គច្បាប់ នៅពេលកំណត់ថា ព្យសនកម្មដែលអ្នកដាក់ពាក្យសុំទទួលរងពុំមានទំនាក់ទំនងជាមួយនឹងអង្គហេតុស្ថិតក្រោមការស៊ើបសួរ។ អ្នកដាក់ពាក្យសុំបានទទួលព្យសនកម្មផ្ទាល់ពីការស្លាប់ឪពុកម្ដាយ និងសមាជិកគ្រួសារផ្សេងៗទៀត និងជាងនេះទៀតពីការជាប់ឃុំឃាំង និងការងារដោយបង្ខំ។ ការចាប់ខ្លួន និងការសម្លាប់ឪពុកម្ដាយរបស់អ្នកដាក់ពាក្យសុំគឺជាផលវិបាកផ្ទាល់នៃគោលនយោបាយខ្មែរក្រហមក្នុងការរើសអើង និងការធ្វើទុក្ខបុកម្នេញ "ពួកនាយទុន" និង "ពួកសក្តិភូមិ" និង "អតីតមន្ត្រីជាន់ខ្ពស់ក្នុងរបប លន់ នល់"។ ដូចនេះ ព្យសនកម្មដែលអ្នកដាក់ពាក្យសុំបានទទួលរង ដោយសារការស្លាប់ឪពុកម្ដាយរបស់ខ្លួននេះ មានទំនាក់ទំនងជាមួយនឹងអង្គហេតុស្ថិតក្រោមការស៊ើបសួរ។ សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីស្នើសុំឲ្យ អ.ប.ជ ច្រានចោលសេចក្ដីសម្រេចមិនអាចទទួលយកពាក្យនេះ ដោយផ្អែកលើអង្គហេតុខាងលើ ហើយអង្គហេតុទាំងនេះស្ថិតក្រោមកិច្ចស៊ើបសួរ ដែល ក.ស.ព បានបញ្ជូនទៅ ក.ស.ច.ស ដើម្បីស៊ើបសួរ។

**ឃ. មូលដ្ឋានទី៤ នៃបណ្ដឹងឧទ្ធរណ៍**

***ស.ច.ស មានការភ័ន្តច្រឡំលើអង្គច្បាប់ដោយការបកស្រាយមិនត្រឹមត្រូវលើពាក្យ ថា"ព្យសនកម្ម" និង "ផលវិបាកផ្ទាល់" ស្របតាមវិធាន ២៣(២)(ក)នៃវិធានផ្ទៃក្នុង (វិសោធនកម្មលើកទី៤ និងវិសោធនកម្មមុនៗ និងវិធាន ២៣ស្ទួន (១)(ខ) (វិសោធនកម្មលើកទី៥)***

***១. ការកំណត់អត្ថន័យព្យសនកម្ម/ការខូចខាត ថាជាផលវិបាកផ្ទាល់ពីឧក្រិដ្ឋកម្មក្នុងយុត្តាធិការ ឬ វិសាលភាពនៃកិច្ចស៊ើបសួររបស់ អ.វ.ត.ក***

៧៩. ស.ច.ស មានការភ័ន្តច្រឡំលើអង្គហេតុនៅពេលខ្លួនអះអាងថាគ្មានការបង្ហាញឲ្យឃើញព្យសនកម្មណាមួយ *ឬ* មានការបង្ហាញឲ្យឃើញព្យសនកម្ម ប៉ុន្តែវាអាចពុំមែនជាព្យសនកម្ម ដែលទាក់ទងទៅនឹងអង្គហេតុក្រោមកិច្ចស៊ើបសួរ។ លើសពីនេះ ស.ច.ស មានការភ័ន្តច្រឡំលើអង្គច្បាប់នៅពេលខ្លួនសម្រេចថាអ្វីខ្លះស្ថិតក្នុង "វិសាលភាពនៃកិច្ចស៊ើបសួរ" ដោយហេតុថា គ្មានភាពច្បាស់លាស់*ទាល់តែសោះ* ក្នុងសេចក្ដីសម្រេចរបស់ខ្លួនពាក់ព័ន្ធទៅនឹងថាតើការសម្រេចថា "ព្យស

នកម្មពុំជាប់ទាក់ទងនឹងអង្គហេតុក្រោមកិច្ចស៊ើបសួរ" នោះគឺជាមូលដ្ឋានក្នុងការកំណត់ថាគ្មានព្យសនកម្មណាមួយដែលត្រូវបានគេបញ្ជាក់ឱ្យឃើញ ដែលអាចទាក់ទងទៅនឹងអង្គហេតុក្រោមកិច្ចស៊ើបសួរ ឬដោយសារតែគ្មានព្យសនកម្មណាមួយដែលត្រូវបានគេបញ្ជាក់ឱ្យឃើញ (ឧទាហរណ៍ ក្នុងករណីដែលអ្នកពាក្យសុំបានលើកឡើងអំពីអង្គហេតុក្រោមកិច្ចស៊ើបសួរ)។

៨០. ដោយសារ ដីកាសម្រេចនេះលើកឡើងថា "ព្យសនកម្មមិនមានទំនាក់ទំនងជាមួយនឹងអង្គហេតុស្ថិតក្រោមកិច្ចស៊ើបសួរ **(ខាងក្រៅវិសាលភាពភូមិសាស្ត្រ/ការធ្វើទុក្ខបុកម្នេញលើប្រជាជនវៀតណាម)** (ការបញ្ជាក់បន្ថែម) គេអាចយល់បានថា សេចក្តីសន្និដ្ឋានដែលធ្វើឡើងដោយ ស.ច.ស គឺមិនមែនថា ព្យសនកម្មនោះ *មិនមែន* ឬ *មិនអាច* បង្ហាញនោះទេ ប៉ុន្តែសេចក្តីសន្និដ្ឋាននោះ គឺថា អង្គហេតុដែលអ្នកដាក់ពាក្យសុំបានលើកឡើង មិនស្ថិតក្នុងវិសាលភាព "ភូមិសាស្ត្រ"នៃកិច្ចស៊ើបសួររបស់ ក.ស.ច.សទេ។

៨១. សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីកត់សម្គាល់លើដីការបស់ ស.ច.ស លើកទីមួយ សម្រេចបដិសេធដើមបណ្តឹងរដ្ឋប្បវេណីជាជនជាតិវៀតណាមទាក់ទងនឹងអ្នកដាក់ពាក្យសុំរបស់ជនជាតិភាគតិចវៀតណាមទាំង១៦នាក់ពីខេត្តកំពង់ឆ្នាំងថា ស.ច.ស បានកត់សម្គាល់ថា "អ្នកដាក់ពាក្យសុំទាំងអស់បានផ្តល់ភស្តុតាងគ្រប់គ្រាន់សម្រាប់ពិចារណាលើភាពអាចទទួលយកបាន ដោយសារពួកគេបានទទួលរងព្យសនកម្មផ្ទាល់ និងជាលក្ខណៈបុគ្គល"[59]។

៨២. ទោះជាយ៉ាងនេះក្តី ដោយសារកង្វះភាពច្បាស់លាស់ក្នុងការរៀបរាប់ពី "ហេតុផល" ក្នុងដីកាសម្រេចខេត្តកំពង់ឆ្នាំង សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីសន្និដ្ឋានថា ស.ច.ស មានការភ័ន្តច្រឡំលើអង្គហេតុ ប្រសិនអ្នកដាក់ពាក្យសុំត្រូវបានបដិសេធ ដោយធ្វើការសន្និដ្ឋានថា ព្យសនកម្មផ្ទាល់ និងជាលក្ខណៈបុគ្គល មិនអាចត្រូវបានបង្ហាញ។ គោលនយោបាយនៃបក្សកុម្មុយនីស្តកម្ពុជាដែលមានគោលបំណងលុបបំបាត់ជនជាតិភាគតិចវៀតណាមក្នុងប្រទេសកម្ពុជា

---

[59] ក.ស.ច.ស, "ដីកាសម្រេចលើភាពអាចទទួលបាននៃសំណើសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលពាក់ព័ន្ធនឹងសំណើសុំ D250/3 ថ្ងៃទី១៣ ខែមករា ឆ្នាំ២០១០ ឯកសារ D250/3/2 កថាខណ្ឌ១៦។ ដីកាសម្រេចលើភាពអាចទទួលបាននៃសំណើសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលពាក់ព័ន្ធសំណើសុំ D250/3" ថ្ងៃទី១៣ ខែមករា ឆ្នាំ២០១០ ឯកសារ D250/3/2 កថាខណ្ឌ ១៩, ថ្ងៃទី១៣ ខែមករា ឆ្នាំ២០១០, កថាខណ្ឌ ១៦។

ត្រូវបានផ្សព្វផ្សាយយ៉ាងទូលំទូលាយថា គោលនយោបាយទាំងនេះត្រូវបានដឹងឮក្នុងចំណោមសមាជិកទាំងអស់នៃកូនក្តីរបស់យើង។ គ្រាន់តែដឹងពីគោលនយោបាយ ដែលអនុវត្តទូទាំងរដ្ឋដើម្បីកម្ទេច*ទាំងអស់* នូវក្រុមជនជាតិភាគតិចវៀតណាមដែលកូនក្តីរបស់យើងជាអ្នកដាក់ពាក្យសុំជាសមាជិក ធ្វើឱ្យពួកគេមានការ "ភ័យខ្លាចយ៉ាងខ្លាំង"។ "ការភ័យខ្លាចយ៉ាងខ្លាំង" បង្កជាព្យសនកម្មព្យសនកម្មផ្ទាល់ និងជាលក្ខណៈបុគ្គលជាក់ស្តែងដល់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលជាជនជាតិវៀតណាម សម្រាប់កូនក្តីរបស់យើង "ការភ័យខ្លាចយ៉ាងខ្លាំង" កើតមានដោយសារការដឹងឮ ជំនឿ និងយល់ដោយទូលំទូលាយថា ក្នុងពេលណាមួយ ពួកគេ ឬមនុស្សជាទីស្រឡាញ់របស់ខ្លួន អាចនឹងត្រូវលុបបំបាត់ ឬត្រូវបានចាត់ចូលទៅក្នុងក្រុមដែលត្រូវលុបបំបាត់។

៨៣. សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីសូមលើកឡើងអំពីការពិពណ៌នាទាក់ទងនឹងឧក្រិដ្ឋកម្ម និងព្យសនកម្ម ដែលត្រូវបានបង្ហាញថាមាន សម្រាប់អ្នកដាក់ពាក្យសុំម្នាក់ៗដែលគេបានបដិសេធពុំទទួលយកក្នុងបណ្តឹងឧទ្ធរណ៍នេះ ហើយអ្នកដាក់ពាក្យសុំទាំងអស់បានលើកឡើងនូវអង្គហេតុដែលថា ពួកគាត់ត្រូវបាននិរទេសដោយបង្ខំ និងបានជិះទូកពីខេត្តកំពង់ឆ្នាំងទៅកាន់ប្រទេសវៀតណាម ដោយបានឆ្លងកាត់ និង/ឬឈប់ដោយខានមិនបាននៅផ្សារអ្នកលឿង ដែលមានទីតាំងនៅតាមដងទន្លេសាប ជាប់ព្រំប្រទល់ខេត្តព្រៃវែង និងខេត្តកណ្តាល។ គួរកត់សម្គាល់ថា អ្នកដាក់ពាក្យសុំ ដែលមានលេខសម្គាល់ D22/2136 និង D22/2135 ដែលគេទាំងពីររូបបានត្រូវបានទទួលស្គាល់ជាដើមបណ្តឹងរដ្ឋប្បវេណី ដោយសារតែការអះអាងអំពី "ការប្រព្រឹត្តិចំពោះប្រជាជនវៀតណាម/ព្យសនកម្មក្នុងឋានៈខ្លួនជាជនរងគ្រោះផ្ទាល់" បានបញ្ជាក់ពីអង្គហេតុនេះក្នុងទម្រង់ព័ត៌មានជនរងគ្រោះរបស់ខ្លួន។ យើងបានដាក់បញ្ចូលជាឯកសារយោងនូវសេចក្តី សន្និដ្ឋានអង្គច្បាប់មួយចំនួនដែលមានក្នុងកថាខណ្ឌ៦៤ ដល់កថាខណ្ឌ៨៨ នៃបណ្តឹងឧទ្ធរណ៍ខេត្តកែប[60] ដែលក្នុងនោះរួមមាន៖

---

[60] ដាក់ជូននៅថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១០ ដោយសហមេធាវីលោក ហុង គឹមសួន លោក នី ចាន់នី និងលោកស្រី Silke STUDZINSKY។ នៅពេលសរសេរឯកសារ លេខឯកសារសម្រាប់បណ្តឹងឧទ្ធរណ៍ខេត្តកែបមិនទាន់មាននៅឡើយទេ។ បណ្តឹងឧទ្ធរណ៍របស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីប្រឆាំងនឹងដីកាសម្រេចស្តីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលមានអាសយដ្ឋាននៅខេត្តកំពង់ឆ្នាំង (D417)

- មូលដ្ឋានរងទី១៖ "ការកំណត់និយមន័យព្យសនកម្ម/ការខូចខាត ថាជាផលវិបាក ផ្ទាល់នៃឧក្រិដ្ឋកម្មក្រោមយុត្តាធិការ ឬវិសាលភាពនៃកិច្ចស៊ើបសួររបស់ អ.វ.ត.ក"។
- មូលដ្ឋានរងទី២៖ "ជនរងគ្រោះដែលបានទទួលរងព្យសនកម្ម/ការខូចខាត ពីការបានឃើញផ្ទាល់ភ្នែកនូវឧក្រិដ្ឋកម្មក្រោមយុត្តាធិការ ឬវិសាលភាពនៃកិច្ចស៊ើបសួររបស់ អ.វ.ត.ក"។
- មូលដ្ឋានរងទី៣៖ "អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីបានទទួលរងព្យសនកម្ម ដោយសារការដឹងឮអំពីឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តប្រឆាំងនឹងមនុស្សជាទីស្រឡាញ់" និង
- មូលដ្ឋានរងទី៤៖ "គ្មានឋានានុក្រមនៃឧក្រិដ្ឋកម្មដើម្បីកំណត់ទំហំព្យសនកម្ម ដែលជនរងគ្រោះបានទទួលរង"។

៨៤. សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីសន្និដ្ឋានថា ព្យសនកម្មផ្ទាល់ និងជាលក្ខណៈបុគ្គលដែលបានកើតឡើងលើបុគ្គលម្នាក់ៗ មានទំនាក់ទំនងផ្ទាល់នឹងអង្គហេតុ ដែល ក.ស.ច.ស បានទទួល ដើម្បីស៊ើបសួរ និងតាមពិត បានបើកការស៊ើបសួរមែន ជាពិសេសទាក់ទងនឹងការប្រព្រឹត្តចំពោះប្រជាជនវៀតណាមក្នុងខេត្តព្រៃវែង[61]។

៨៥. ដោយសារអ្នកដាក់ពាក្យសុំដែលគេបដិសេធភាគច្រើនលើកឡើងពីឧក្រិដ្ឋកម្មប្រឆាំងនឹងជនជាតិភាគតិចវៀតណាម នៅពេលនេះបណ្តឹងឧទ្ធរណ៍ពិនិត្យលើការសន្និដ្ឋានដែលបានបញ្ជាក់ថា វិសាលភាពនៃកិច្ចស៊ើបសួរ ដែល ក.ស.ព បានបកស្រាយត្រឹមត្រូវ និងបានបញ្ជាក់លើកមុន មានបញ្ចូលការធ្វើទុក្ខបុកម្នេញលើប្រជាជនវៀតណាមនៅទូទាំងប្រទេសកម្ពុជា។

## ច. មូលដ្ឋានទីប្រាំ នៃបណ្តឹងឧទ្ធរណ៍

[61] ក.ស.ច.ស "កណត់ហេតុនៃការស្តាប់ចម្លើយ ដើមបណ្តឹងរដ្ឋប្បវេណី" ថ្ងៃទី៤ ខែមករា ឆ្នាំ២០១០ ឯកសារលេខ D296/6 និង ក.ស.ច.ស "កណត់ហេតុនៃការស្តាប់ចម្លើយ ដើមបណ្តឹងរដ្ឋប្បវេណី" ថ្ងៃទី១១ ខែមករា ឆ្នាំ២០១០ ឯកសារលេខ D296/5។

00634028



*សហចៅក្រមស៊ើបអង្កេតបានទទួលអង្គហេតុពេញលេញនូវអង្គហេតុទាក់ទងនឹងការធ្វើទុក្ខបុកម្នេញ និង ប្រល័យពូជសាសន៍លើប្រជាជនភាគតិចវៀតណាម រួមទាំងការស៊ើបសួរ ដែលធ្វើឡើងដោយ ក.ស.ច.ស ជាមួយនឹងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីក្នុងខេត្តកំពង់ឆ្នាំង និងការនិរទេសប្រជាជន វៀតណាម តាមទូកឆ្លងកាត់ខេត្តព្រៃវែង។*

**១. ស.ច.ស បានទទួលតែអង្គហេតុ ដែលបញ្ជាក់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ការិយាល័យសហព្រះរាជអាជ្ញា (វិសាលភាពនៃកិច្ចស៊ើបសួរដែលត្រូវបានអនុវត្តយ៉ាងត្រឹមត្រូវ) ដែលជួយដល់ការកំណត់ធាតុផ្សំយុត្តាធិការ និងទម្រង់នៃការទទួលខុសត្រូវឧក្រិដ្ឋកម្មរបស់ជនជាប់ចោទទាក់ទិននឹងឧក្រិដ្ឋកម្មប្រឆាំងនឹងជនជាតិភាគតិចវៀតណាម**

៨៦. សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ធ្វើការយោង និងបញ្ជាក់ម្ដងហើយម្ដងទៀតនូវសេចក្ដីសន្និដ្ឋាន ដែលបានធ្វើឡើងត្រង់កថាខណ្ឌ ៥១-៥៦ ពាក់ព័ន្ធទៅនឹងការភ័ន្តច្រឡំរបស់ ស.ច.ស ចំពោះវិសាលភាពនៃកិច្ចស៊ើបសួរ ដែល ក.ស.ព បានបញ្ជូនទៅ ក.ស.ច.ស។

៨៧. ដីកាបញ្ជូនសំណុំរឿងទៅពិនិត្យរបស់ ក.ស.ព ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០០៨ កំណត់ពីវិសាលភាពនៃកិច្ចស៊ើបសួរ ដោយដាក់បញ្ចូលនូវកិច្ចស៊ើបសួរទាំងឡាយណាដែលជួយដល់ការកំណត់ធាតុផ្សំយុត្តាធិការ ចាំបាច់សម្រាប់កំណត់ឧក្រិដ្ឋកម្ម ក្រោមយុត្តាធិការរបស់ អ.វ.ត.ក និងទម្រង់នៃការទទួលខុសត្រូវឧក្រិដ្ឋកម្ម ដែលបានចោទប្រកាន់ប្រឆាំងនឹងជនត្រូវចោទ[62]។

៨៨. ក្រៅពីការធ្វើទុក្ខបុកម្នេញលើប្រជាជនវៀតណាម និងគោលនយោបាយប្រល័យពូជសាសន៍ក្នុងការលុបបំបាត់ក្រុមជនជាតិវៀតណាមក្នុងខេត្តព្រៃវែង ខេត្តស្វាយរៀង និងក្នុងអំឡុងពេលវាយឆ្មក់ចូលទៅក្នុងប្រទេសវៀតណាម ការធ្វើទុក្ខបុកម្នេញ និងការសម្លាប់យ៉ាងរាលដាល និងទ្រង់ទ្រាយធំ លើជនជាតិភាគតិចវៀតណាម *ជាក្រុម* គឺជាអង្គហេតុ ដែល ក.ស.ច.ស បានទទួល ដើម្បីស៊ើបអង្កេត

[62] ក.ស.ព "ការឆ្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងសំណើរបស់សហចៅក្រមស៊ើបអង្កេត ដើម្បីបញ្ជាក់ពីវិសាលភាពនៃកិច្ចស៊ើបសួរ ដែលបានស្នើឡើង នៅក្នុងដីការសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនឱ្យរឿងឱ្យស៊ើបសួរបន្ថែម" ថ្ងៃទី១៣ ខែសីហា ឆ្នាំ២០០៨ ឯកសារ D98 ក្នុងការឆ្លើយតបទៅនឹង ក.ស.ច.ស "ដីកាបញ្ជូនសំណុំរឿងមូលទៅពិនិត្យ" ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៨ ឯកសារ D98។

ជាអង្គហេតុដែលត្រូវការិយាល័យសហព្រះរាជអាជ្ញាលើកយោងសម្រាប់ធ្វើការស៊ើបសួរនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដែលស្នើនូវបទចោទចំពោះចុងចោទ[63]។

៨៩. កថាខណ្ឌ ១២(ច) បញ្ជាក់ថា បក្សកុម្មុយនីស្តកម្ពុជា "បន្តធ្វើនយោបាយរើសអើងប្រឆាំង និងសម្លាប់ជនជាតិភាគតិចវៀតណាម។ ពីដំបូង បក្សកុម្មុយនីស្តកម្ពុជាបានអនុម័តនូវគោលនយោបាយមួយក្នុងការបោសសំអាតជនទាំងឡាយណា ដែលត្រូវបានចាត់ទុកថាជាជនជាតិវៀតណាម ឬអ្នកដែលមានទំនាក់ទំនងជាមួយប្រទេសវៀតណាម។ យ៉ាងណាមិញ ទំនាក់ទំនងជាមួយបក្សកុម្មុនីស្តកម្ពុជាជាមួយប្រទេសវៀតណាម បានចុះដុនដាបជាលំដាប់ ហើយមានទស្សនៈដែលចេះតែកើនឡើងថាប្រទេសវៀតណាម គឺជាខ្មាំង។ ទស្សនៈនេះ ស៊ីគ្នាទៅនឹងជំនឿ ដែលថា គិញវៀតណាម កំពុងព្យាយាមរំលំបក្សកុម្មុយនីស្តកម្ពុជា។ មកដល់ពាក់កណ្តាល និងចុងឆ្នាំ១៩៧៧ គោលនយោបាយនេះ បានវិវត្តទៅជាគោលនយោបាយមួយ ដែលលុបបំបាត់ប្រជាជនទាំងអស់ ដែលមានទំនាក់ទំនងជាមួយប្រទេសវៀតណាម"។

៩០. យើងបញ្ជាក់ថា វិសាលភាពនៃកិច្ចស៊ើបសួរ ដែល ក.ស.ព បានបញ្ជូនទៅ ក.ស.ច.ស មានបញ្ចូលនូវអង្គហេតុលើសពីការលើកឡើងក្នុងកថាខណ្ឌ ៣៧-៧២ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងរួមមានបញ្ហាទាក់ទងនឹង"ការដឹងឮ និងការចូលរួម" ក្នុងឧក្រិដ្ឋកម្មរបស់ជនជាប់ចោទ ដែលបង្កើតឱ្យមានការចោទប្រកាន់ស្នើឡើងដោយ ក.ស.ព។ ទង្វើឧក្រិដ្ឋកម្មទាំងនេះ ដែលបានកំណត់យកសមាជិកក្រុមជនជាតិភាគតិចវៀតណាមជាគោលដៅ រួមមាន ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការរំលោភបំពានយ៉ាងធ្ងន់ធ្ងរចំពោះអនុសញ្ញាក្រុងហ្សឺណែវ ឆ្នាំ១៩៤៩[64]។ អង្គហេតុដែលទាក់ទងនឹងការចោទប្រកាន់ របស់ ក.ស.ព ប្រឆាំងនឹង *ជនត្រូវចោទទាំងអស់* និងមានវិសាលភាព*សមស្រប* សម្រាប់កិច្ចស៊ើបសួរ ត្រូវបានលើកយោងនៅកថាខណ្ឌនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរដូចខាងក្រោម ៖

---

[63] ដីការសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ ក.ស.ព ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ ឯកសារ D3 កថាខណ្ឌ ១២ច។

[64] ក.ស.ព "ដីការសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ" ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ ឯកសារ D3 កថាខណ្ឌ ៨១(ឃ), ៨១(ច), ៨១(ឆ), ៨៧ និង១០២(i)។

00634030



ក. *កថាខណ្ឌ ៨១(ឃ) ៖ "នួន ជា ធ្វើផែនការ ដឹកនាំ សម្របសម្រួល និងចេញបញ្ជាឱ្យមានការសម្លាប់ខុសច្បាប់ក្រុមមនុស្សផ្សេងៗ ក្នុងចំណោមប្រជាជនកម្ពុជាប្រជាធិបតេយ្យ ដូចជា ... (ខ) ពួកដែលត្រូវបានចោទថាជាភ្នាក់ងារសេអ៊ីអា, កាហ្សេបេ និងភ្នាក់ងារវៀតណាម និងខ្មាំងដទៃទៀត ហៅថា "គិញ" និង "ពួកក្បត់" ..."។*

ខ. *កថាខណ្ឌ៨១(ឆ) ៖ "នួន ជា បានធ្វើផែនការ ក្តោបក្តាប់ និងតាមដានអំពើឃោរឃៅ ប្រព្រឹត្ត ដោយកងកម្លាំងកម្ពុជាប្រជាធិបតេយ្យ ទៅលើប្រជាជនវៀតណាម នៅព្រំដែនកម្ពុជាប្រជាធិបតេយ្យ-វៀតណាម ពីពាក់កណ្តាលឆ្នាំ១៩៧៧"។*

គ. *ទាក់ទងនឹងការចូលរួមក្នុងឧក្រិដ្ឋកម្មរបស់ ខៀវ សំផន កថាខណ្ឌ ៩៧ បង្ហាញភស្តុតាងពីតួនាទីរបស់គាត់ជាកម្មាភិបាលជាន់ខ្ពស់ និងជាប្រធានមន្ទីរ៨៧០ ។ គាត់ "បានចេញបញ្ជា និងផ្តល់ការណែនាំទាំងឡាយស្តីពីការអនុវត្តគោលនយោបាយ និងមនោគមវិជ្ជាបដិវត្តន៍ កសាងដល់អង្គភាពរដ្ឋបាល និងភូមិសាស្ត្រផ្សេងៗ របបកម្ពុជាប្រជាធិបតេយ្យ ... ជាពិសេស មន្ទីរ ៨៧០ នេះ ជាស្ថាប័នសំខាន់ ដែលញុះញង់ឱ្យមានការស្អប់ខ្ពើមពួកវៀតណាម ... មន្ទីរ ៨៧០ បានចេញសេចក្តីណែនាំខាងនយោបាយ និងយោធាទៅឱ្យបក្សកុម្មុយនីស្តកម្ពុជា កងទ័ព គ្រប់មន្ទីរនិងក្រសួង និង "ប្រជាជនកម្ពុជាទាំងមូល" ... ពីរថ្ងៃក្រោយមក សេចក្តីណែនាំទាំងនេះ ត្រូវបានពង្រឹងដោយសេចក្តីប្រកាសទីពីរ ដែលគាំទ្រប្រព្រឹត្តកម្មយង់ឃ្នង និងសម្លាប់ដោយចេតនា ជនជាតិស៊ីវិលវៀតណាម ឈ្លើយសឹកវៀតណាម និងខ្មែរកាត់វៀតណាមផ្សេងៗទៀត"។*

ឃ. *កថាខណ្ឌ ១០២ (i) ៖ "ក្នុងឋានៈជារដ្ឋមន្ត្រីសង្គមកិច្ច អៀង ធីរិទ្ធ បានជំរុញ ញុះញង់ ជួយសម្រួល លើកទឹកចិត្ត និង /ឬបណ្តែតបណ្តោយឱ្យមានការប្រព្រឹត្តឧក្រិដ្ឋកម្មនានា ... ការនិយាយ និងធ្វើជាប្រធានអង្គប្រជុំការងារ ដែលបានពន្យល់ពីគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ដែលពាក់ព័ន្ធនឹងខ្មាំង ដូចជាពួកវៀតណាម (យួន) ពួកសេអ៊ីអា និងសមាសភាពគ្មានវិន័យ"។*

៩១. អង្គហេតុទាំងនេះ ដែលត្រូវបានបកស្រាយយ៉ាងត្រឹមត្រូវស្របតាមការបញ្ជាក់របស់ ក.ស.ព ចំពោះវិសាលភាពនៃកិច្ចស៊ើបសួរ គឺជាអង្គហេតុតែប៉ុណ្ណោះ ដែល ក.ស.ច.ស បានទទួលពី ក.ស.ព ដើម្បីធ្វើការស៊ើបអង្កេត[65]។

៩២. ជាងនេះទៀត ដីកាដំណោះស្រាយរបស់ ស.ច.ស បានចោទប្រកាន់បញ្ជូន*ជនជាប់ចោទទាំងអស់* ទៅជំនុំជម្រះពីបទធ្វើទុក្ខបុកម្នេញ (លើប្រជាជនវៀតណាម ដោយសារមូលហេតុជាតិសាសន៍) និងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ប្រឆាំងនឹងជនជាតិភាគតិចវៀតណាម[66]។ ដីកាដំណោះស្រាយរបស់ ក.ស.ច.ស ធ្វើការបញ្ជាក់បន្ថែមទៀតថា "ការសម្លាប់ប្រជាជនស៊ីវិលវៀតណាមមិនមែនកើតឡើងត្រឹមតែខេត្តព្រៃវែង និងខេត្តស្វាយរៀងប៉ុណ្ណោះទេ ដែលនេះបង្ហាញឲ្យឃើញថាជាការរៀបចំឡើងនៅក្នុងក្របខ័ណ្ឌនៃគោលនយោបាយជាតិ"[67]។

៩៣. ជាបន្តទៀតនេះ បណ្តឹងឧទ្ធរណ៍នេះដាក់ទៅបង្ហាញថា អ្នកដាក់ពាក្យសុំទាំង ២៤ ជាជនជាតិភាគតិចវៀតណាម ដែល ស.ច.ស មិនទទួលយក តាមពិតបានទទួលរងព្យសនកម្មដែលមានទំនាក់ទំនងផ្ទាល់ជាមួយនឹង "អង្គហេតុស្ថិតក្រោមកិច្ចស៊ើបសួរ"។ ផ្អែកជាបន្តនៃបណ្តឹងឧទ្ធរណ៍នេះបង្ហាញថា "អង្គហេតុស្ថិតក្រោមកិច្ចស៊ើបសួរ" រួមមានអង្គហេតុដែលកូនក្តីរបស់យើងក្នុងខេត្តកំពង់ឆ្នាំងបានរៀបរាប់។ អ្នកដាក់ពាក្យសុំទាំងអស់ត្រូវបាននិរទេសពីប្រទេសកម្ពុជាដោយបង្ខំ និងបានជិះទូកតាមដងទន្លេសាប រួចឆ្លងកាត់ ឬឈប់នៅផ្សារអ្នកលឿងក្នុងខេត្តព្រៃវែង។ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីពីររូប (ដែលមានលេខសម្គាល់ D22/2135 និង D22/2136) ត្រូវបានទទួលស្គាល់ ដោយផ្អែកលើមូលហេតុនេះគត់ និងដោយសារតែពួកគាត់បានលើកអង្គហេតុនេះក្នុងទម្រង់ព័ត៌មានជនរងគ្រោះរបស់ខ្លួន។

---

[65] ក.ស.ព "ចម្លើយតបរបស់សហព្រះរាជអាជ្ញា ចំពោះសហចៅក្រមស៊ើបអង្កេត ដែលស្នើឡើងឲ្យបញ្ជាក់អំពីវិសាលភាពនៃកិច្ចស៊ើបសួរ ដែលបានលើកឡើងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទ១៣ ខែសីហា ឆ្នាំ២០០៨, ឯកសារ D98/I ក្នុងការឆ្លើយតបចំពោះ "ដីកាបញ្ជូនសំណុំរឿងមូលទៅពិនិត្យ" ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០០៨ ឯកសារ D98 ។

[66] ក.ស.ច.ស "ដីកាដំណោះស្រាយ" ថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១០ ឯកសារលេខ D427។

[67] ដូចខាងលើ កថាខណ្ឌ ៨០២។

## ២. ស.ច.ស បានទទួលអង្គហេតុ ដែលមានរៀបរាប់ពីការប្រព្រឹត្តិមកលើប្រជាជនវៀតណាមក្នុងខេត្តកំពង់ឆ្នាំង ហើយការស៊ើបសួរក្នុងតំបន់នេះធ្វើឡើងដោយ ក.ស.ច.ស គឺស្ថិតក្នុងវិសាលភាពនៃកិច្ចស៊ើបសួរ ដែល ក.ស.ព បានបញ្ជូនទៅ ក.ស.ច.ស

៩៤. នៅក្នុង "ដីកាសម្រេចលើសំណើទាំងពីររបស់សហព្រះរាជអាជ្ញាសុំឱ្យបំពេញកិច្ចស៊ើបសួរទាក់ទងនឹងខ្មែរក្រោម និងការសម្លាប់រង្គាលនៅ[redacted] និងសំណើរបស់មេធាវីដើមបណ្តឹងរដ្ឋបវេណីសុំការស៊ើបអង្កេតបន្ថែមទាក់ទងនឹងការសម្លាប់ខ្មែរក្រោម និងជនជាតិវៀតណាម" (ដីកាសម្រេចរួម) ស.ច.ស បានផ្តល់ហេតុផលថា វិសាលភាពនៃកិច្ចស៊ើបសួររបស់ ក.ស.ច.ស កំណត់ត្រឹមតែអង្គហេតុដែលបានលើកឡើងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ ក.ស.ព ឬដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់ ក.ស.ព ស្របតាមវិធាន ៥៣ និង ៥៥(២)[68]នៃវិធានផ្ទៃក្នុងប៉ុណ្ណោះទេ។

៩៥. នៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០០៩ ចៅក្រមស៊ើបអង្កេតរបស់ ក.ស.ច.ស បានធ្វើបទសម្ភាសន៍ជាមួយនឹងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីជាជនជាតិភាគតិចវៀតណាមចំនួនពីរនាក់មកពីខេត្តកំពង់ឆ្នាំង[69]។ បទសម្ភាសន៍របស់ ក.ស.ច.ស ជាមួយនឹងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី[70]នេះបានផ្តោតការយកចិត្តទុកដាក់លើបញ្ហាទាក់ទងនឹងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលបានធ្វើឡើងប្រឆាំងនឹងក្រុម

---

[68] ក.ស.ច.ស "ដីកាសម្រេចរួម អំពីដីការសម្រេចលើសំណើទាំងពីររបស់សហព្រះរាជអាជ្ញា សុំឱ្យបំពេញកិច្ចស៊ើបសួរទាក់ទងនឹងខ្មែរក្រោម និងការសម្លាប់រង្គាលនៅ[redacted]និងសំណើរបស់មេធាវីដើមបណ្តឹងរដ្ឋបវេណីសុំការស៊ើបអង្កេតបន្ថែមទាក់ទងនឹងការសម្លាប់ ខ្មែរក្រោមនិងជនជាតិវៀតណាម" ថ្ងៃទី១៣ ខែមករា ឆ្នាំ២០១០ ឯកសារលេខ D250/3/3 កថាខណ្ឌ ៩។

[69] ក.ស.ច.ស "កំណត់ហេតុនៃការស្តាប់ចម្លើយ ដើម្បបណ្តឹងរដ្ឋប្បវេណី" ថ្ងៃទី៤ ខែមករា ឆ្នាំ២០១០ ឯកសារលេខ D296/6 និង ក.ស.ច.ស "កំណត់ហេតុនៃការស្តាប់ចម្លើយ ដើម្បបណ្តឹងរដ្ឋប្បវេណី" ថ្ងៃទី១១ ខែមករា ឆ្នាំ២០១០ ឯកសារលេខ D296/5។

[70] យោង ក្នុងបណ្តឹងឧទ្ធរណ៍ដំបូងពីភាពអាចទទួលយកប្រជាជនវៀតណាម សម្រាប់ VN01 និង VN10។ បទសម្ភាស ត្រូវបានធ្វើឡើងជាមួយនឹងកូនក្តីទាំងនេះ នៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០០៩ ចំនួនពីរបីថ្ងៃមុនពេល ជនជាប់ចោទត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋកម្ម។

00634033



ជនជាតិភាគតិចវៀតណាមក្នុងខេត្តកំពង់ឆ្នាំង។ សំណួរដែលបានរៀបចំឡើងសម្រាប់បទសម្ភាសន៍ផ្តោតទៅលើការបង្ហាញពីអង្គហេតុដែលបង្ហាញពីធាតុផ្សំអំពីការធ្វើទុក្ខបុកម្នេញ និងយុត្តាធិការនៃឧក្រិដ្ឋកម្ម ដោយផ្តោតទៅលើ ការកំណត់អត្តសញ្ញាណ ការកំណត់ក្រុមគោលដៅ ការបែងចែក និងការរើសអើងប្រឆាំងនឹងប្រជាជនវៀតណាមពីសំណាក់ពួកខ្មែរក្រហមក្នុងខេត្តកំពង់ឆ្នាំង។ បទសម្ភាសន៍ទាំងនេះក៏បានយកចិត្តទុកដាក់លើព្រឹត្តិការណ៍ដែលនាំដល់ការនិរទេសប្រជាជនវៀតណាមក្នុងទ្រង់ទ្រាយធំដោយបង្ខំពីខេត្តកំពង់ឆ្នាំងចេញពីប្រទេសកម្ពុជា ដោយការបញ្ជូនតាមទូកតាមបណ្តោយដងទន្លេសាបទៅកាន់ប្រទេសវៀតណាម។

៩៦. រាល់សំណួរ និងចម្លើយទាំងអស់ត្រូវបានកត់ត្រាចូលក្នុង "កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី" ជាផ្លូវការ និងបានដាក់ក្នុងសំណុំរឿង[71]។ នៅថ្ងៃទី១៦ និង១៧ ខែធ្នូ ឆ្នាំ២០០៩ គឺជារយៈពេលតែប៉ុន្មានថ្ងៃប៉ុណ្ណោះបន្ទាប់ពី ក.ស.ច.ស បានស្តាប់ចម្លើយកូនក្តីរបស់យើងក្នុងខេត្តកំពង់ឆ្នាំង ស.ច.ស បានចោទប្រកាន់ជនជាប់ក្នុងសំណុំរឿង ០០២ ពីបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ប្រឆាំងនឹងជនជាតិភាគតិចវៀតណាម[72]។

៩៧. កិច្ចស៊ើបសួររបស់ ក.ស.ច.ស ត្រូវបានធ្វើឡើងយ៉ាងពិតប្រាកដ ស្របតាមអង្គហេតុក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ ក.ស.ព ត្រង់ផ្នែក ១២(ច) ដែលចែងថា ៖

"បក្សកុម្មុយនីស្តកម្ពុជា បន្តធ្វើនយោបាយរើសអើងប្រឆាំង និងសម្លាប់ជនជាតិភាគតិចវៀតណាម។ ពីដំបូង បក្សកុម្មុយនីស្តកម្ពុជា បានអនុវត្តនូវគោលនយោបាយមួយក្នុងការបោសសំអាតជនទាំងនោះ ដែលត្រូវបានចាត់ទុកថាជនជាតិវៀតណាម ឬអ្នក ដែលមានទំនាក់ទំនងជាមួយប្រទេសវៀតណាម"។

៩៨. តាមពិត កិច្ចស៊ើបសួររបស់ ក.ស.ច.ស បានធ្វើឡើងហួសពីវិសាលភាពនៃឧក្រិដ្ឋកម្ម ដែលបានរៀបរាប់ពីកថាខណ្ឌ ៣៧ ដល់៧២នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។ ជាក់ស្តែង ប្រសិនបើ ស.ច.ស យល់ឃើញថា កិច្ចស៊ើបសួរទាំងនេះរកឃើញ "អង្គហេតុថ្មី" ពួកគេគួរបញ្ជូនអង្គហេតុទាំងនេះទៅ ក.ស.ព ស្របតាមវិធាន ៥៥(៣) ឱ្យបានលឿនបំផុតតាមដែលអាចធ្វើបាន ដើម្បីឱ្យ

---

[71] ក.ស.ច.ស "កំណត់ហេតុនៃការស្តាប់ចម្លើយ ដើម្បបណ្តឹងរដ្ឋប្បវេណី" ថ្ងៃទី៥ ខែមករា ឆ្នាំ២០១០ ឯកសារលេខ D296/6 និង ក.ស.ច.ស "កំណត់ហេតុនៃការស្តាប់ចម្លើយ ដើម្បបណ្តឹងរដ្ឋប្បវេណី" ថ្ងៃទី១១ ខែមករា ឆ្នាំ២០១០ ឯកសារលេខ D296/5។

[72] ឧទាហរណ៍ មើល "កំណត់ហេតុនៃការស្តាប់ចម្លើយជនជាប់ចោទ (នួន ជា)" ថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០០៩ ឯកសារលេខ D275កថាខណ្ឌ ១៣។

ក.ស.ព ចាត់វិធានការលើ "អង្គហេតុថ្មីៗទាំងនេះ"។ ដោយសារតែ ក.ស.ច.ស មិនបានផ្តល់ព័ត៌មានដល់ ក.ស.ព អំពីអង្គហេតុថ្មីៗ ដែលបានរកឃើញក្នុងខេត្តកំពង់ឆ្នាំងក្នុងអំឡុងពេលនៃកិច្ចស៊ើបសួររបស់ខ្លួន ស.ច.ស បានចាត់ទុកអង្គហេតុទាំងនេះថាពិតជា "អង្គហេតុថ្មីៗ ដោយកំហិតត្រឹមតែស្ថានទម្ងន់ទោសទាក់ទងនឹងសេចក្តីសន្និដ្ឋានដែលមានស្រាប់ប៉ុណ្ណោះ" ស្របតាមវិធាន ៥៥(៣)[73] នៃវិធានផ្ទៃក្នុង។

៩៩. នៅក្នុង ដីការបស់ ស.ច.ស លើកទីមួយសម្រេចបដិសេធដើមបណ្តឹងរដ្ឋប្បវេណីជាជនជាតិវៀតណាម (ដោយបដិសេធប្រជាជនវៀតណាមចំនួន ១៦ នាក់ក្នុងខេត្តកំពង់ឆ្នាំង) ស.ច.ស បានបញ្ជាក់ថា ពួកគេធ្វើការស៊ើបសួរ "ទៅតាមការកំណត់ពីគោលការណ៍ជាសារវន្ត ដែលតាមរយៈគោលការណ៍នេះ ពួកគេមិនអាចធ្វើការស៊ើបសួរហួសពីអង្គហេតុ ដែលពួកគេបានទទួលពីសហព្រះរាជអាជ្ញា"[74]។ តាមការសន្និដ្ឋានរបស់យើង ស.ច.ស តែងតែទទួលអង្គហេតុពី ក.ស.ព ដើម្បីស៊ើបសួរក្នុងខេត្តកំពង់ឆ្នាំង ដោយសារថា អង្គហេតុថ្មី ដែល ស.ច.ស បានរកឃើញពីការស៊ើបសួរក្នុងខេត្តកំពង់ឆ្នាំង ជួយដល់ការបង្ហាញធាតុផ្សំផ្នែកយុត្តាធិការ និងទម្រង់ត្រឹមត្រូវនៃការទទួលខុសត្រូវរបស់ជនត្រូវចោទ ស្របតាមវិសាលភាពនៃកិច្ចស៊ើបសួរដែល ក.ស.ពបានកំណត់ក្នុងដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០០៨ ដោយធ្វើការបញ្ជាក់ពីអ្វី ដែល ក.ស.ច.ស *បានទទួល* ដើម្បីស៊ើបសួរ[75]។

---

[73] ក.ស.ព បានបញ្ជាក់បន្ថែមថា ការិយាល័យរបស់ខ្លួន មិនបានស្នើដោយឡែកដល់ ក.ស.ច.ស ឱ្យធ្វើសម្ភាសន៍លើអង្គហេតុក្នុងខេត្តកំពង់ឆ្នាំង ដោយធ្វើការបញ្ជាក់ជាពិសេសថា កិច្ចស៊ើបសួររបស់ ក.ស.ច.ស គឺជាការស៊ើបសួរលើ "អង្គហេតុដាក់ទម្ងន់ ដែលមានចែងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ" (ក្រោមវិធាន ៥៥(៣)នៃវិធានផ្ទៃក្នុង"។

[74] ក.ស.ច.ស "ដីកាសម្រេចទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី" ថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១០ ឯកសារលេខ D274/3 កថាខណ្ឌ ៩។

[75] ក.ស.ច.ស "ចម្លើយរបស់សហព្រះរាជអាជ្ញា ចំពោះសហចៅក្រមស៊ើបអង្កេត ដែលស្នើសុំឱ្យបញ្ជាក់អំពីវិសាលភាពនៃកិច្ចស៊ើបសួរ ដែលបានស្នើឡើង នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញា", ថ្ងៃទី១៣ ខែសីហា ឆ្នាំ២០០៨ ឯកសារលេខ D98/I, ក្នុងការឆ្លើយតប "ដីកាបញ្ជូនរឿងជូនទៅពិនិត្យ" របស់ ក.ស.ច.ស ថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៨ ឯកសារលេខ D98។

១០០. ជាងនេះទៀត នៅក្នុងអនុស្សរណៈផ្ទៃក្នុងដែលបានផ្ញើជូនសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីចុះថ្ងៃទី **៤ ខែមិថុនា ឆ្នាំ២០១០**[76] ស.ច.ស បានបញ្ជាក់ថា "គេត្រូវតែរំលឹកឡើងវិញថា ការស្តាប់ចម្លើយដោយអ្នកស៊ើបអង្កេតនោះ នឹងមិនមានផលប៉ះពាល់ឱ្យមានការពង្រីកកិច្ចស៊ើបសួររបស់សហចៅក្រមស៊ើបអង្កេត និងមិនប៉ះពាល់ដល់ការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីណាមួយទេ"។

១០១. តាមពិត យើងធ្វើការសន្និដ្ឋានថា កិច្ចស៊ើបសួររបស់ ក.ស.ច.ស ក្នុងខេត្តកំពង់ឆ្នាំងមិននាំឱ្យ "ប៉ះពាល់ដល់វិសាលភាពនៃកិច្ចស៊ើបសួរទេ" ដោយ*កិច្ចស៊ើបសួរនេះត្រូវបានធ្វើឡើង<u>ក្រោម</u>វិសាលភាពនៃកិច្ចស៊ើបសួរ ដែល ក.ស.ព បានបញ្ជូនទៅ ក.ស.ច.ស*។

១០២. ដូចនេះ ស.ច.ស ពុំមានមូលដ្ឋានណាមួយ ដើម្បីប្រកាសថា ព្យសនកម្ម ដែលកូនក្តីរបស់យើងបានទទួលរង "មិនមានទំនាក់ទំនងជាមួយនឹងអង្គហេតុស្ថិតក្រោមកិច្ចស៊ើបសួរ" ឬថា ស.ច.ស "បានទទួលអង្គហេតុដែលទាក់ទងនឹងការប្រព្រឹត្តិលើប្រជាជនវៀតណាមក្នុងខេត្តព្រៃវែង និងខេត្តស្វាយរៀង [តែប៉ុណ្ណោះ] និងក្នុងអំឡុងពេលនៃការវាយចូលក្នុងប្រទេសវៀតណាម"[77]។

១០៣. ជាងនេះទៀត ស.ច.ស ពុំមានមូលដ្ឋានណាមួយ ដើម្បីធ្វើការសន្និដ្ឋានថា អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលបានទទួលរងការឈឺចាប់ពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាម ការធ្វើទុក្ខបុកម្នេញ ឬឧក្រិដ្ឋកម្មផ្សេងទៀត ដែលមានទិសដៅលើ*ក្រុម*ជនជាតិវៀតណាម គួរត្រូវបានបដិសេធ ដោយសារតែការប្រកាសថា ការធ្វើទុក្ខបុកម្នេញលើជនជាតិវៀតណាមនោះស្ថិត"នៅក្រៅវិសាលភាពភូមិសាស្ត្រ[នៃកិច្ចស៊ើបសួរ]" ឡើយ ជាពិសេស នៅពេលប្រជាជនវៀតណាមទាំងអស់ត្រូវបានបញ្ជូនឆ្លងកាត់ផ្សារអ្នកលឿង ដែលស្ថិតនៅតាមដងទន្លេសាបក្នុងខេត្តព្រៃវែង និងនៅពេលអ្នកដាក់ពាក្យសុំ ដែលមានលេខ

---

[76] អនុស្សរណៈផ្ទៃក្នុងរបស់ ក.ស.ច.ស មានចំណងជើងថា "សំណើរបស់លោក-លោកស្រី ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១០ ទាក់ទិននឹងការទទួលយលព្រមលើពាក្យសុំតាំងខ្លួន ជាដើមបណ្តឹងរដ្ឋប្បវេណី" ឯកសារលេខ D250/3/2/4។

[77] តាមការធ្វើសេចក្តីសន្និដ្ឋានរបស់ស.ច.ស ក្នុង "ដីកាសម្រេចលើភាពអាចទទួលបាននៃសំណើសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលពាក់ព័ន្ធសំណើសុំ D250/3" ថ្ងៃទី១៣ ខែមករា ឆ្នាំ២០១០ ឯកសារ D250/3/2 កថាខណ្ឌ ១៩។

សម្គាល់ D22/2135 និងD22/2136 ត្រូវបានទទួលស្គាល់ ដោយសារតែការលើកឡើងពីអង្គហេតុនេះ។

១០៤. អាស្រ័យហេតុនេះ អ.ប.ជ គួរច្រានចោលដីកាសម្រេចបដិសេធពាក្យសុំ ដែលធ្វើឡើងដោយ ស.ច.ស និងផ្តល់ឱ្យអ្នកដាក់ពាក្យសុំទាំងអស់ដូចខាងក្រោមនូវឋានៈជាដើមបណ្តឹងរដ្ឋប្បវេណី ពីព្រោះពួកគេបានទទួលរងព្យសនកម្មដែលមានទំនាក់ទំនងផ្ទាល់ជាមួយនឹងអង្គហេតុស្ថិតក្រោមកិច្ចស៊ើបសួរ ៖ : D22/1901, D22/3180, D22/3183, D22/2057, D22/2154, D22/438, D22/3179, D22/3182, D22/816, D22/3177, D22/2157, D22/3181, D22/817, D22/2155, D22/2153, D22/404, D22/2156, D22/1136, D22/1969, D22/3175, D22/3176, D22/3178, D22/2158 និង D22/1092។

### ៣. ការបញ្ចូលអង្គហេតុរបស់ ក.ស.ព ទាក់ទងនឹងការធ្វើទុក្ខបុកម្នេញ និងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ក្នុងខេត្តកំពង់ឆ្នាំងទៅក្នុងដីកាសន្និដ្ឋានស្ថាពរ បង្ហាញយ៉ាងច្បាស់ថា ក.ស.ព មានបំណងបញ្ជាក់ថា វិសាលភាពនៃកិច្ចស៊ើបសួរមានបញ្ចូលអង្គហេតុក្នុងខេត្តកំពង់ឆ្នាំង ដែលមានទំនាក់ទំនងនឹងបទចោទប្រឆាំងនឹងជនជាប់ចោទ (រួមទាំងបទចោទពីការនិរទេសដោយបង្ខំចេញពីប្រទេសកម្ពុជាផង)

១០៥. ដីកាសន្និដ្ឋានស្ថាពររបស់ ក.ស.ព ដែលមានរៀបរាប់អង្គហេតុទាក់ទងនឹង "គោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ដើម្បីធ្វើឱ្យសាបសូន្យនៃអ្នកតាំងទីលំនៅជនជាតិវៀតណាមទាំងអស់ដែលរស់នៅក្នុងប្រទេសកម្ពុជា" ដែលនាំដល់ការសម្លាប់បំផុតពូជស្ទើរតែទាំងស្រុងនៃក្រុមជនជាតិភាគតិចនេះក្នុងប្រទេសកម្ពុជា"[78] បង្ហាញថា វិសាលភាពនៃកិច្ចស៊ើបសួរ តែងតែមានទំហំធំជាងនូវអ្វីៗ ដែល ក.ស.ច.ស យល់ឃើញ។

១០៦. ទាំងដីកាសន្និដ្ឋានស្ថាពររបស់ ក.ស.ព ទាំងដីកាដំណោះស្រាយ[79]របស់ ក.ស.ច.ស មានរៀបរាប់ពីអង្គហេតុដែលអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងខេត្តកំពង់ឆ្នាំងបានលើក

---

[78] ក.ស.ព "សេចក្តីសន្និដ្ឋានស្ថាពររបស់សហសព្រះរាជអាជ្ញា អនុលោមតាមវិធាន ៦៦" កថាខណ្ឌ ៧៨៧-៧៨៩។ មើលផងដែរត្រង់ផ្នែក "ឧក្រិដ្ឋកម្មប្រឆាំងនឹងប្រជាជនវៀតណាម" កថាខណ្ឌ ៧៧៩។

[79] ក.ស.ព "សេចក្តីសន្និដ្ឋានស្ថាពររបស់សហសព្រះរាជអាជ្ញា អនុលោមតាមវិធាន ៦៦" កថាខណ្ឌ ៧៨៧-៧៨៩។ មើលផងដែរត្រង់ផ្នែក "ឧក្រិដ្ឋកម្មប្រឆាំងនឹងប្រជាជនវៀតណាម" កថាខណ្ឌ ៧៧៩។

ឡើងទាក់ទងនឹងការធ្វើទុក្ខបុកម្នេញ និងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍លើប្រជាជនវៀតណាមនៅក្នុងតំបន់នេះ។ ជាពិសេស ដីកាសន្និដ្ឋានស្ថាពររបស់ ក.ស.ព មានការពិពណ៌នារួមរបស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាំង៤៥នាក់ក្នុងខេត្តកំពង់ឆ្នាំង ដែលក្នុងនេះអ្នកដាក់ពាក្យសុំចំនួន ៤០នាក់ ត្រូវបានបដិសេធដោយ ស.ច.ស[80]។ អង្គហេតុ ដែលបានលើកឡើងក្នុងដីកាសន្និដ្ឋានស្ថាពររបស់ ក.ស.ច.ស រួមមាន *អង្គហេតុ ដែលកិច្ចស៊ើបសួររបស់ ក.ស.ច.ស បានរកឃើញក្នុងតំបន់នេះ*[81] ដែលមានខ្លឹមសារដូចខាងក្រោម ៖

"ក្នុងខេត្តកំពង់ឆ្នាំង នៅប្រហែលជាខែមេសា ឆ្នាំ១៩៧៥ អាជ្ញាធរយោធារបស់បក្សកុម្មុយនីស្តបានធ្វើបំលាស់ទីជាតិពន្ធុវៀតណាម ដែលរស់នៅក្នុងទីក្រុង និងនៅតាមភូមិនានា នៅជុំវិញ[redacted]ទៅទីតាំងទីលំនៅថ្មីនៅតាមឃុំនានា នៅក្នុង[redacted] ដែលរួមមាន ៖ [redacted][82] [redacted]

បន្ទាប់មក ចាប់ពីខែមិថុនា ដល់ខែកញ្ញា ឆ្នាំ១៩៧៥ មានក្រុមជាតិពន្ធុវៀតណាមជាច្រើនពាន់នាក់ ដែលពីដំបូងត្រូវបានចម្លៀសឲ្យទៅកាន់ឃុំនានាក្នុង[redacted] ត្រូវបានបញ្ជូនទៅកាន់ប្រទេសវៀតណាម។ ការជម្លៀសដំបូង ដែលមានជនជាតិវៀតណាមចំនួន ៤០០ គ្រួសារ បានកើតឡើង នៅម្តុំពាក់កណ្តាលខែកក្កដា ឆ្នាំ១៨៧៥។ ការបញ្ជូនទៅស្រុកកំណើតវិញជាបន្តបន្ទាប់មកទៀត បានកើតឡើង បន្ទាប់ពីការចរចារវាងបក្សកុម្មុយនីស្តកម្ពុជា និងអាជ្ញាធរសាធារណរដ្ឋសង្គមនិយមវៀតណាម ដែលមានការប្តូរក្រុមជាតិពន្ធុវៀតណាមជាមួយនឹងអំបិល និងអង្ករ។ ក្នុងកាលៈទេសៈមួយចំនួន មន្ត្រីផ្លូវការវៀតណាមបានផ្តល់

---

[80] នៅថ្ងៃទី១៣ ខែមករា ឆ្នាំ២០១០ ស.ច.ស បានប្រកាសមិនទទួលយកអ្នកដាក់ពាក្យសុំ ដែលជាជនជាតិវៀតណាមទាំង ១៦ នាក់ ក្នុង "ដីកាសម្រេចលើភាពអាចទទួលយកបាននៃសំណើតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលពាក់ព័ន្ធនឹងសំណើ 250/3" ឯកសារ D250/3/2 ។ នៅថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១០ ស.ច.ស បានប្រកាសមិនទទួលស្គាល់អ្នកដាក់ពាក្យសុំ ២៥នាក់ផ្សេងទៀត ដែលជនជាតិវៀតណាម ក្នុងដីកាសម្រេចខេត្តកំពង់ឆ្នាំង។

[81] ក.ស.ព "ដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៦៦" កថាខណ្ឌ ៧៨៧-៧៨៩។ សូមមើលផងដែរនូវផ្នែកស្តីពី "ឧក្រិដ្ឋកម្មប្រឆាំងនឹងប្រជាជនវៀតណាម" កថាខណ្ឌ ៧៨៧។

[82] ក.ស.ព "ដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៦៦" កថាខណ្ឌ ៧៨៧-៧៨៩។ សូមមើលផងដែរនូវផ្នែកស្តីពី "ឧក្រិដ្ឋកម្មប្រឆាំងនឹងប្រជាជនវៀតណាម" កថាខណ្ឌ ៧៨៧។

00634038



អង្ករចំនួន ២០ គីឡូក្រាម និងអំបិលចំនួន ២០គីឡូក្រាមជូនទៅបក្សកុម្មុយនីស្ត សម្រាប់ជនជាតិពន្ធុវៀតណាមម្នាក់ៗ ដែលបានចាកចេញពីប្រទេសកម្ពុជា។ នៅ[redacted]ការតស៊ូរបស់ជនជាតិវៀតណាមមួយចំនួន មិនចង់ឲ្យគេបញ្ជូនវិលត្រឡប់ទៅកាន់ប្រទេសវៀតណាមវិញ បានចេញជាលទ្ធផលជាការសម្លាប់ក្នុងចំនួនជាច្រើននៃក្រុមជាតិពន្ធុវៀតណាមពី២០០-៣០០គ្រួសារ[83]។

មានជនជាតិវៀតណាមតិចតួចបំផុត នៅសល់ក្នុងខេត្តកំពង់ឆ្នាំង ដែលភាគច្រើនគឺជាប្រជាជន ដែលបានរៀបការចម្រុះគ្នារវាងខ្មែរ និងវៀតណាម។ អ្នកដែលនៅសល់ក្នុងខេត្តកំពង់ឆ្នាំងក្នុងឆ្នាំ១៩៧៦ ត្រូវបានដាក់ឲ្យស្ថិតក្រោម ត្រូវបានដាក់ឲ្យស្ថិតក្រោមគោលនយោបាយអាពាហ៍ពិពាហ៍ចម្រុះ ដែលជាគំរោងធ្វើឡើងដើម្បី "លុបបំបាត់ឬសគុលវៀតណាមចេញពីប្រជាជនកម្ពុជា។ នៅក្រោមគោលនយោបាយនេះ សហព័ទ្ធខ្មែរ នៅក្នុងពាពិពាហ៍ចម្រុះនេះ ត្រូវបានគេបញ្ជាឲ្យសម្លាប់ប្តី ឬប្រពន្ធរបស់ខ្លួន ដែលជាជនជាតិវៀតណាម និងកូន ដែលចាប់កំណើតពីអាពាហ៍ពិពាហ៍នេះ ឬប្រឈមមុខនឹងការស្លាប់នៃសមាជិកគ្រួសារទាំងមូលរបស់ខ្លួន[84]"។

១០៧. អង្គហេតុទាំងនេះបង្ហាញពីការប៉ុនប៉ងរបស់ពួកខ្មែរក្រហមក្នុងការលុបបំបាត់ជនជាតិភាគតិចវៀតណាមពីខេត្តកំពង់ឆ្នាំង តាមរយៈ៖

ក. ការជម្លៀសដោយបង្ខំចំពោះជនជាតិភាគតិចវៀតណាម ពីក្រុង និងភូមិផ្សេងៗនៅជុំវិញ[redacted] និងការប្រមូលផ្តុំប្រជាជនទាំងនេះនៅតាមឃុំផ្សេងៗ ក្នុ[redacted]

ខ. ការនិរទេសដោយបង្ខំចំពោះប្រជាជនវៀតណាមទាំងអស់ រួមទាំងកូនក្តីរបស់យើង ទៅប្រទេសវៀតណាម ពីខែមិថុនា ដល់ខែកញ្ញា ឆ្នាំ១៩៧៥ និង

គ. ការអនុវត្តគោលនយោបាយអាពាហ៍ពិពាហ៍ចម្រុះ នៅឆ្នាំ១៩៧៦ ចំពោះអ្នកដែលស្ថិតក្នុងប្រទេសកម្ពុជា ដែលក្រោមនយោបាយនេះ សហព័ទ្ធនៅក្នុងអាពាហ៍ពិពាហ៍ចម្រុះនេះ ត្រូវ

---

[83] ដូចខាងលើ កថាខណ្ឌ ៧៨៨។ សូមបញ្ជាក់ថា ការយកមនុស្សទៅដូរអង្ករ និងអំបិលនេះជាញឹកញាប់ធ្វើឡើងនៅក្នុងផ្សារអ្នកលឿងក្នុងខេត្តព្រៃវែង ក្នុងពេលប្រជាជនវៀតណាមកំពុងធ្វើដំណើរចេញពីប្រទេសកម្ពុជាទៅកាន់កាន់ប្រទេសវៀតណាម។

[84] ដូចខាងលើ កថាខណ្ឌ ៧៨៩។

បានគេបញ្ជាឱ្យសម្លាប់ប្តី ឬប្រពន្ធ ដែលជាជនជាតិវៀតណាម ហើយក្នុងករណីខ្លះ សម្លាប់ទាំងកូនដែលបានចាប់កំណើតពីអាពាហ៍ពិពាហ៍នេះផង។

១០៨. ផ្នែកសំខាន់អំពីករណីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ក្នុងខេត្តកំពង់ឆ្នាំងគឺថា អង្គហេតុនៃការជម្លៀសដោយបង្ខំចំពោះជនជាតិភាគតិចវៀតណាមពីខេត្តកំពង់ឆ្នាំងទៅកាន់ប្រទេសវៀតណាម ក្នុងអំឡុងពេលពាក់កណ្តាលឆ្នាំ១៩៧៥ ឆ្លុះបញ្ចាំងឱ្យឃើញថា មានចេតនាក្នុងការលុបបំបាត់ក្រុមនេះ ព្រមទាំងសកម្មភាពជាក់ស្តែង ដែលបានធ្វើឡើងក្នុងការអនុវត្តគោលនយោបាយប្រល័យពូជសាសន៍ ចាប់ពីដើមឆ្នាំ១៩៧៥។ អង្គហេតុទាំងនេះ គឺជាការបំពេញបន្ថែមទៅនឹងករណី ក.ស.ព នៃការជម្លៀសដោយបង្ខំចំពោះក្រុមជាតិជាតិភាគតិចវៀតណាមពីតំបន់បូព៌ា ដែលយកចិត្តទុកដាក់ជាសំខាន់លើព្រឹត្តិការណ៍នៅពាក់កណ្តាលឆ្នាំ១៩៧៨។ អង្គហេតុទាំងនេះមានលក្ខណៈស្របនឹងអង្គហេតុដែលស្ថិតក្រោមកិច្ចស៊ើបសួររបស់ ក.ស.ច.ស ទាក់ទងនឹងការនិរទេសប្រជាជនវៀតណាមចេញពីប្រទេសកម្ពុជា ដែលក្នុងករណីនេះធ្វើឡើងតាមដងទន្លេសាប ក្នុងខេត្តព្រៃវែង។

១០៩. ជាសំខាន់នោះគឺថា អង្គហេតុទាំងនេះបង្កើតបានជាមូលដ្ឋានមួយក្នុងការបញ្ជាក់ថា គោលបំណងក្នុងការបំផ្លាញក្រុមជនជាតិភាគតិចវៀតណាម មានអត្ថិភាពតាំងពីពេលដំបូងនៃ របបខ្មែរក្រហម មិនមែនទើបតែកើតឡើងនៅពេលមានកំណើននៃជម្លោះជាមួយប្រទេសវៀតណាមនោះទេ។ ដូច្នេះ ចំណុចសំខាន់នៃករណីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ប្រឆាំងនឹងជនជាតិភាគតិចវៀតណាម គឺថា ឧក្រិដ្ឋកម្មនេះ ដែលធ្វើឡើងសំដៅទៅ "ក្រុមជនជាតិភាគតិច" ដែលត្រូវទទួលបានការការពារ មិនមានកើតមានតែនៅទីកន្លែងឧក្រិដ្ឋកម្មជាក់លាក់ណាមួយទេ ឬតែនៅភូមិសាស្ត្រណាមួយឡើយ។ ទោះបីមានការកំណត់ទីកន្លែងឧក្រិដ្ឋកម្មតាមភូមិសាស្ត្រជាក់លាក់ក៏ដោយ ក៏គេគួរកត់សម្គាល់ឃើញថា អ្នកដាក់ពាក្យសុំ ដែលមានលេខសម្គាល់ D22/2135 និង D22/2136 ត្រូវបានទទួលស្គាល់ ដោយសារពួកគាត់បានលើកឡើងថាបានឆ្លងកាត់ផ្សារអ្នកលឿងក្នុងខេត្តព្រៃវែង ដែលជាទីតាំងស្ថិតក្រោមវិសាលភាពភូមិសាស្ត្រនៃកិច្ចស៊ើបសួរ។

១១០. ដូចនេះ ការបញ្ចូលអង្គហេតុក្នុងខេត្តកំពង់ឆ្នាំងទៅក្នុងដីកាសន្និដ្ឋានស្ថាពរគឺជាការបញ្ជាក់យ៉ាងច្បាស់ថា កិច្ចស៊ើបសួររបស់ ក.ស.ច.ស ក្នុងទីតាំងនេះ ដែលជាជំនួយដល់ការបង្ហាញធាតុផ្សំផ្នែកយុត្តាធិការ បានរកឃើញអង្គហេតុស្ថិតក្នុងវិសាលភាពនៃកិច្ចស៊ើបសួរ ដែល ក.ស.ព *បានបញ្ជូនទៅ* ក.ស.ច.ស និង *មានបំណងឲ្យ* ក.ស.ច.ស បើកកិច្ចស៊ើបសួរ។

១១១. ការអនុវត្តមិនត្រឹមត្រូវរបស់ ស.ច.ស ចំពោះវិសាលភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរក្នុងការសម្រេចពីភាពអាចទទួលយកពាក្យសុំបាន គឺជាការភ័ន្តច្រឡំលើអង្គហេតុ និងអង្គច្បាប់។ ស.ច.ស បានច្រានចោល មានការយល់ខុស និង/ឬមានការភ័ន្តច្រឡំលើវិសាលភាពនៃកិច្ចស៊ើបសួរ ក្នុងការច្រានចោលអង្គហេតុ ដែល ក.ស.ព បានបញ្ជូនឱ្យខ្លួន។ ប្រសិនបើមានការអនុវត្តត្រឹមត្រូវនៃវិសាលភាពនៃកិច្ចស៊ើបសួរ ដែល ក.ស.ព បានបញ្ជូនទៅឱ្យ ក.ស.ច.ស នោះ កូនក្តីរបស់យើងដែលជនជាតិភាគតិចវៀតណាម *ទាំងអស់* គួរត្រូវបានទទួលយកជាដើមបណ្តឹងរដ្ឋប្បវេណី ពីព្រោះឃើញថាមានទំនាក់ទំនងពិសេសរវាងព្យសនកម្មដែលបានចោទ និងអង្គហេតុស្ថិតក្រោមកិច្ចស៊ើបសួរ នៅក្នុងអង្គហេតុដែលបានលើកឡើងក្នុងពាក្យសុំរបស់កូនក្តីយើង។ សូមបញ្ជាក់ថា កូនក្តីរបស់យើង ដែលជាជនជាតិវៀតណាមទាំងអស់ត្រូវបាននិរទេសដោយបង្ខំ ដោយការជិះទូកតាមបណ្តោយដងទន្លេសាប ឆ្លងកាត់ផ្សារអ្នកលឿងក្នុងខេត្តព្រៃវែង។

១១២. សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីសូមស្នើឱ្យចៅក្រមនៃ អ.ប.ជ ទទួលយកអ្នកដាក់ពាក្យសុំជនជាតិភាគតិចវៀតណាមទាំងអស់ដែលរងការបដិសេធដោយសារថា ព្យសនកម្មដែលពួកគេទទួលរងពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងការធ្វើទុក្ខបុកម្នេញ ដែលបានធ្វើឡើងប្រឆាំងនឹងពួកគេ មានទំនាក់ទំនងផ្ទាល់ជាមួយនឹងអង្គហេតុស្ថិតក្រោមកិច្ចស៊ើបសួរ ហើយតាមពិត *គឺជា* ភស្តុតាង ដែលបានលើកឡើងក្នុងកិច្ចស៊ើបសួររបស់ ក.ស.ច.ស និងត្រូវបានប្រើដោយ ស.ច.ស ដើម្បីគាំទ្រដល់ការចោទប្រកាន់ប្រឆាំងនឹងជនជាប់ចោទទាំង៤ រូបក្នុងសំណុំរឿង០០២។

១១៣. ជាបន្តទៀត បណ្តឹងឧទ្ធរណ៍នេះពិនិត្យលើការបញ្ជាក់ថា បទសម្ភាសន៍ដែល ក.ស.ច.ស បានធ្វើឡើងក្នុងខេត្តកំពង់ឆ្នាំងត្រូវបានប្រើប្រាស់ដើម្បីគាំទ្រដល់ការចោទប្រកាន់បទប្រល័យពូជសាសន៍

និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលស.ចៅ.ស បានចោទប្រកាន់បញ្ជូនទៅជំនុំជម្រះជនជាប់ចោទទាំង៤ ក្នុងដីកាដំណោះស្រាយរបស់ ស.ចៅ.ស។

**៤. អង្គហេតុដែលកូនក្តីជាជនជាតិភាគតិចវៀតណាម ក្នុងខេត្តកំពង់ឆ្នាំងបានលើកឡើង និងទទួលបានពីកិច្ចស៊ើបសួររបស់ ក.ស.ចៅ.ស មានទំនាក់ទំនងផ្ទាល់ជាមួយនឹងឧក្រិដ្ឋកម្ម ដែលដីកាដំណោះស្រាយរបស់ ស.ចៅ.ស បានចោទប្រកាន់បញ្ជូនជនជាប់ចោទទាំង ៤នាក់ ទៅជំនុំជម្រះ**

១១៤. ដីកាដំណោះស្រាយរបស់ ស.ចៅ.ស ចោទប្រកាន់ អៀង សារី អៀង ធីរិទ្ធ ខៀវ សំផន និងនួន ជា ទៅជំនុំជម្រះពីបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ជនជាតិភាគតិចវៀតណាម ព្រមទាំងការធ្វើទុក្ខបុកម្នេញ [លើជនជាតិភាគតិចវៀតណាម] ដោយមូលហេតុជាតិសាសន៍ និងការធ្វើនិរទេសប្រជាជនវៀតណាម ដែលការធ្វើទុក្ខបុកម្នេញ និងការធ្វើនិរទេសនេះស្ថិតក្រោមបទចោទនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ[85]។

១១៥. នៅក្នុងមូលដ្ឋានទី១នៃបណ្តឹងឧទ្ធរណ៍នេះ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានសន្និដ្ឋានថា ស.ចៅ.ស បានអនុវត្តវិសោធនកម្មទី៥នៃវិធានផ្ទៃក្នុងដោយមានការភ័ន្តច្រឡំនៅពេលសម្រេចលើការទទួលយកដើមបណ្តឹងរដ្ឋប្បវេណី ដែលនេះធ្វើឱ្យមានការព្រួយបារម្ភអំពីភាពយុត្តិធម៌នៃដំណើរការនីតិវិធី។ នៅក្នុងមូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍នេះ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីមានអំណះអំណាងថា បើទោះជាអនុវត្តវិសោធនកម្មទី៥នៃវិធានផ្ទៃក្នុងនេះក៏ដោយ ក៏កូនក្តីរបស់យើងគួរតែត្រូវបានទទួលយក។

១១៦. វិធាន ២៣*ស្ទួន* (១)នៃវិធានផ្ទៃក្នុង ចែងថា ៖

"ដើម្បីឱ្យពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីអាចទទួលយកបាន អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីត្រូវ ៖ ខ-បង្ហាញ *ជាលទ្ធផលដោយផ្ទាល់ពីបទឧក្រិដ្ឋ យ៉ាងហោចណាស់មួយនៃបទឧក្រិដ្ឋជាច្រើន ដែលត្រូវបានចោទប្រកាន់លើជនត្រូវចោទ* ថាខ្លួនពិតជាបានទទួលរងនូវព្យសនកម្មខាងរូបរាងកាយ ខាងសម្ភារៈ ឬ ផ្លូវចិត្ត ដែលអាចជាមូលដ្ឋានសម្រាប់ការទាមទារសំណងផ្លូវចិត្ត និង

[85] ក.ស.ចៅ.ស "ដីកាដំណោះស្រាយ" ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០ ឯកសារលេខ D427 ជពូក ៥ ("សេចក្តីសម្រេចបញ្ជូន") កថាខណ្ឌ ១៦១៣។

សមូហភាព"។

១១៧. អ្នកដាក់ពាក្យសុំជាជនជាតិភាគតិចវៀតណាមគ្រប់ៗរូបពីខេត្តកំពង់ឆ្នាំង ដែលបានដាក់ពាក្យសុំចូលរួមនៅ អ.វ.ត.ក បានទទួលរងការធ្វើនិរទេសដោយបង្ខំចេញពីប្រទេសកម្ពុជា ដែលជាទង្វើមួយប្រព្រឹត្តឡើងតាមគោលនយោបាយប្រល័យពូជសាសន៍ ដើម្បីលុបបំបាត់ក្រុមជនជាតិភាគតិចវៀតណាមពីប្រទេសកម្ពុជា។ នាពេលបច្ចុប្បន្ន អង្គហេតុទាំងនេះ *មាននៅក្នុង* កថាខណ្ឌ ៧៨៧ ដល់កថាខណ្ឌ៧៨៩ ក្នុងដីកាសន្និដ្ឋានស្ថាពររបស់ ក.ស.ព និងអង្គហេតុក្នុងដីកាដំណោះស្រាយរបស់ ស.ច.ស ដើម្បីគាំទ្រដល់បទចោទប្រឆាំងនឹងជនត្រូវចោទ អំពីការធ្វើទុក្ខបុកម្នេញប្រជាជនវៀតណាម ការនិរទេសប្រជាជនវៀតណាម ដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងប្រល័យពូជសាសន៍លើជនជាតិភាគតិចវៀតណាម។

១១៨. វិធាន ២៣*ស្ទួន* (១)នៃវិធានផ្ទៃក្នុង (វិសោធនកម្មទី ៥) បញ្ជាក់យ៉ាងច្បាស់ថា ព្យសនកម្មត្រូវតែមានទំនាក់ទំនងដោយផ្ទាល់ជាមួយនឹងឧក្រិដ្ឋកម្ម*ដែលបានចោទប្រកាន់* ប្រឆាំងនឹងជនត្រូវចោទ។ ក្នុងករណីនេះ ជនត្រូវចោទ*ត្រូវបានចោទប្រកាន់បញ្ជូនរឿងទៅជំនុំជម្រះ* ពីបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ប្រឆាំងនឹងជនជាតិភាគតិចវៀតណាម ក្នុងដីកាដំណោះស្រាយរបស់ ស.ច.ស ដែលបញ្ជាក់ថាមាន "ភស្តុតាងគ្រប់គ្រាន់" ថា នួន ជា អៀង សារី ខៀវ សំផន និងអៀង ធីរិទ្ធបានប្រព្រឹត្ត (តាមរយៈសហឧក្រិដ្ឋកម្មរួម) បានធ្វើផែនការ ញុះញង់ បញ្ជា ឬជួយជំរុញ ឬទទួលខុសត្រូវ ដោយសារតែការទទួលខុសត្រូវថ្នាក់លើ ចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ប្រល័យពូជសាសន៍ ការបំពារបំពានយ៉ាងធ្ងន់ធ្ងរយ៉ាងទៅលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ និងការរំលោភបំពានក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦[86]។

១១៩. "ភស្តុតាង" ដែលបានលើកមកយោង រួមមានអង្គហេតុ ដែលបានលើកឡើងក្នុងកិច្ចស៊ើបសួររបស់ កស.ច.ស ក្នុងខេត្តកំពង់ឆ្នាំង តាមរយៈបទសម្ភាសន៍ជាមួយនឹងអ្នកដាក់ពាក្យសុំតាំងខ្លួនដើមបណ្តឹងរដ្ឋប្បវេណី អំពីការនិរទេសក្នុងទ្រង់ទ្រាយធំដោយបង្ខំចំពោះសមាជិកក្រុមដែលជាជនជាតិភាគតិចវៀតណាមទៅកាន់ប្រទេសវៀតណាម។ ការនិរទេសប្រជាជនវៀតណាម ដែល

---

[86] ក.ស.ច.ស "ដីកាដំណោះស្រាយ" ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០ ឯកសារលេខ D427 កថាខណ្ឌ ១៦១៣ ("សេចក្តីសម្រេចបញ្ជូប")។

00634043



ជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ បានលើកឡើងយ៉ាងច្បាស់ក្នុងសេចក្តីប្រកាសព័ត៌មានរបស់ ក.ស.ច.ស ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១០ ដោយបញ្ជាក់ពីការចោទប្រកាន់បញ្ជូន នួន ជា ខៀវ សំផន អៀង សារី និងអៀង ធីរិទ្ធ ទៅជំនុំជម្រះ[87]។ ការធ្វើនិរទេសប្រជាជនវៀតណាមត្រូវបានបញ្ជាក់ក្នុងដីកាដំណោះស្រាយ ដោយធ្វើការដកស្រង់ពី "កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី" ដែលពីដំបូងត្រូវបានទទួលយកជាដើមបណ្តឹងរដ្ឋប្បវេណី និងក្រោយមកទៀតត្រូវបានបដិសេធនៅក្នុងដីការបស់ ស.ច.ស លើកទីមួយសម្រេចបដិសេធដើមបណ្តឹងរដ្ឋប្បវេណីជាជនជាតិវៀតណាម បន្ទាប់ពីបានទទួលព័ត៌មានពាក់ព័ន្ធអំពីការនិរទេសដោយបង្ខំទៅកាន់ប្រទេសវៀតណាម តាមដងទន្លេសាប។ កំណត់ហេតុនៃការស្តាប់ចម្លើយផ្លូវការជាមួយនឹងកូនក្តីរបស់យើងបានដាក់ជា "ឯកសារគាំទ្រ" ក្នុងឧបសម្ព័ន្ធ ខ ស្របតាមវិធាន ៧៧*ស្ទួន*(២)នៃវិធានផ្ទៃក្នុង។

១២០. ជនជាប់ចោទទាំងបួនរូប នឹងត្រូវយកមកកាត់សេចក្តី ពីបទ*ឧក្រិដ្ឋកម្ម* ប្រល័យពូជសាសន៍ប្រឆាំងនឹងជនជាតិភាគតិចវៀតណាម។ ក្នុងសេចក្តីសន្និដ្ឋានរបស់យើង ជនរងគ្រោះជាជាតិវៀតណាម*ទាំងអស់* ក្នុងខេត្តកំពង់ឆ្នាំង គួរទទួលយក នៅពេលអនុវត្តលក្ខណៈវិនិច្ឆ័យដែលមានចែងក្នុងវិសោធនកម្មណាមួយក៏ដោយនៃវិធានផ្ទៃក្នុង រួមទាំងវិសោធនកម្មទី៥ផង។ ផ្នែកបន្តទៀតនៃបណ្តឹងឧទ្ធរណ៍នេះ នឹងយកចិត្តទុកដាក់ក្នុងការបង្ហាញថា ភស្តុតាង និងអង្គហេតុ ដែលអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីជាជនជាតិភាគតិចវៀតណាម ក្នុងខេត្តកំពង់ឆ្នាំងបានលើកឡើង ដែល*ពិតជា* ជួយគាំទ្រដល់បទចោទនានា ដូចបានលើកឡើងក្នុងដីកាសន្និដ្ឋានស្ថាពររបស់ ក.ស.ព និងដីកាដំណោះស្រាយរបស់ ស.ច.ស។

### ៥. "ដីកាដំណោះស្រាយ" របស់ ស.ច.ស មានបញ្ជាក់ពីអង្គហេតុអំពីការប្រព្រឹត្តិចំពោះប្រជាជនវៀតណាមក្នុងខេត្តកំពង់ឆ្នាំង ដែលបានដកស្រង់ចេញពីការស៊ើបសួរ ដោយ ក.ស.ច.ស ក្នុងខេត្តកំពង់ឆ្នាំង

[87] ក.ស.ច.ស "សេចក្តីប្រកាសព័ត៌មាន" (អំពីដីកាដំណោះស្រាយ) ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១០ ត្រង់ http://www.eccc.gov.kh/english/cabinet/press/169/ECCC_OCIJ_PR_16_Sep_2010(En).pdf

00634044



១២១. បើទោះបី ស.ច.ស សម្រេចថា “ព្យសនកម្មពុំមានទំនាក់ទំនងជាមួយនឹងអង្គហេតុ ដែលស្ថិតក្រោមការស៊ើបអង្កេត” និងធ្វើការបញ្ជាក់បន្ថែមទៀតថា ការធ្វើទុក្ខបុកម្នេញលើប្រជាជនវៀតណាមក្នុងខេត្តកំពង់ឆ្នាំងនេះ មិនស្ថិតក្នុង “វិសាលភាពភូមិសាស្ត្រនៃកិច្ចស៊ើបសួរ”[88] ក៏ដោយ ក៏តាមពិត ការិយាល័យនេះ *បាន* ធ្វើការស៊ើបសួរក្នុងខេត្តកំពង់ឆ្នាំង និង*បានប្រើប្រាស់* ប្រើប្រាស់ព័ត៌មាន ដែលទទួលបានពីបទសម្ភាសន៍ ដើម្បីកំណត់ពីអង្គហេតុអំពី “ការប្រព្រឹត្តិប្រឆាំងនឹងប្រជាជនវៀតណាម” ក្នុងដីកាដំណោះស្រាយ[89]។ ជាងនេះទៀត ដីកាដំណោះស្រាយនេះដកស្រង់អង្គហេតុដែលអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងខេត្តកំពង់ឆ្នាំង បានលើកឡើង ទោះជាបន្ទាប់ពី ស.ច.ស បានបដិសេធការទាមទារសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់បុគ្គលទាំងពីរនាក់ក្នុងដីការបស់ ស.ច.ស លើកទីមួយសម្រេចបដិសេធដើមបណ្តឹងរដ្ឋប្បវេណីជាជនជាតិវៀតណាម បន្ទាប់ពីការិយាល័យនេះបានសម្ភាសពួកគេទាំងពីរនេះ (សូមមើល “កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី” ត្រង់ <u>**ឧបសម្ព័ន្ធ គ**</u>)។

១២២. *ដោយប្រើប្រាស់ព័ត៌មានដែលទទួលបានពីបទសម្ភាសន៍ជាមួយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងខេត្តកំពង់ឆ្នាំង* ដីកាដំណោះស្រាយបញ្ជាក់ពី “ការផ្លាស់ទីលំនៅប្រជាជនវៀតណាមពីប្រទេសកម្ពុជា ទៅប្រទេសវៀតណាម” ដូចខាងក្រោម ៖

> “ដើមឡើយ បក្សកុម្មុយនីស្តកម្ពុជាបានផ្តោតលើការបណ្តេញចេញប្រជាជនវៀតណាមពីទឹកដីកម្ពុជា។ គោលនយោបាយនេះ ចាប់ផ្តើមអនុវត្តតាំងពីឆ្នាំ១៩៧៣ ហើយត្រូវបានបន្តអនុវត្ត នៅក្នុងឆ្នាំ១៩៧៥ និងឆ្នាំ១៩៧៦ ... ក្នុងខេត្តព្រៃវែង និងខេត្តស្វាយរៀង ព្រមទាំងនៅទូទាំងប្រទេសកម្ពុជា។ ប្រជាជនវៀតណាមត្រូវបានបញ្ជូនដោយថ្មើរជើង ដោយរទេះភ្លើង និងដោយទូកទៅកាន់ប្រទេសវៀតណាម។ សាក្សីមួយចំនួននិយាយថា ពួកគេត្រូវបានបង្ខំឲ្យទៅប្រទេសវៀតណាមវិញ ហើយសាក្សីខ្លះទៀតបានលើកឡើងថា ប្រជាជនវៀតណាមអាចជ្រើសរើសយល់ព្រមទទួលយកសំណើឲ្យទៅត្រលប់ទៅកាន់វៀតណាម។ សាក្សីខ្លះទៀតសង្ស័យថា នេះជាអន្ទាក់ ហើយតាមពិត ប្រជាជនទាំងនោះត្រូវបានគេយកទៅសម្លាប់។ សហព័ទ្ធ និងគ្រួសារជាជន

[88] ដីកាសម្រេចខេត្តកំពង់ឆ្នាំង ឧបសម្ព័ន្ធ ៣ (“អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីមិនត្រូវបានទទួលយក”)។

[89] ក.ស.ច.ស “ដីកាដំណោះស្រាយ” ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០ ឯកសារលេខ D427 កថាខណ្ឌ ៧៨៤។

ជាតិកម្ពុជា មិនអនុញ្ញាតឱ្យទៅប្រទេសវៀតណាមវិញឡើយ ហេតុនេះហើយ ជនជាតិវៀតណាម ដែលស្ថិតក្នុងស្ថានភាពទាំងនេះ ត្រូវបានជ្រើសរើសស្នាក់នៅប្រទេសកម្ពុជា”[90]។

១២៣. ស្ថិតនៅត្រង់ចំណុចថា “ការសម្លាប់ប្រជាជនស៊ីវិលវៀតណាម ក្រៅពីខេត្តព្រៃវែង និងខេត្តស្វាយរៀង” ដីកាដំណោះស្រាយ បញ្ជាក់ថា ៖

> “ការសម្លាប់ប្រជាជនវៀតណាម មិនមែនកើតឡើងត្រឹមតែនៅខេត្តព្រៃវែង និងខេត្តស្វាយរៀង ប៉ុណ្ណោះទេ ដែលនេះបង្ហាញឱ្យឃើញថា ជាការរៀបចំឡើងនៅក្នុងក្របខ័ណ្ឌនៃគោលនយោបាយជាតិ”។

ដីកាដំណោះស្រាយនេះក៏បានលើកឡើងពី “ការប្រព្រឹត្តិរបស់ប្រជាជនកម្ពុជា ដែលមានសហព័ទ្ធជាវៀតណាម និងកូន ដែលមានសហព័ទ្ធម្នាក់ជាជនជាតិវៀតណាម” ដោយបានយោងទៅបទសម្ភាសន៍ជាមួយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងខេត្តកំពង់ឆ្នាំង។

១២៤. ការបដិសេធយ៉ាងច្បាស់ក្រឡែតរបស់ ស.ច.ស តាមរយៈការសន្និដ្ឋានថា ជនជាតិភាគតិចវៀតណាម ដែលបានទទួលរងការធ្វើទុក្ខបុកម្នេញ និងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ក្នុងខេត្តកំពង់ឆ្នាំង មិនបានលើកឡើងពី “អង្គហេតុដែលស្ថិតក្រោមការស៊ើបអង្កេត” គឺជាការបដិសេធដែលមិនអាចទទួលយកបាននោះទេ។ ការិយាល័យ ស.ច.ស បានស៊ើបអង្កេត លើអង្គហេតុក្នុងខេត្តកំពង់ឆ្នាំង និងប្រើប្រាស់អង្គហេតុទាំងនេះក្នុងដីកាដំណោះស្រាយរបស់ខ្លួនរួចហើយ។ ការបដិសេធក្រោយមកទៀតមិនទទួលយកថា អង្គហេតុទាំងនេះស្ថិតក្រោមកិច្ចស៊ើបអង្កេត សូម្បីតែបន្ទាប់ពី ស.ច.ស ខ្លួនឯងបានយល់ដឹងយ៉ាងច្បាស់លាស់ពីការបញ្ចូលអង្គហេតុទាំងនេះយ៉ាងពេញលេញក្នុងដីកាសន្និដ្ឋានស្ថាពររបស់ ក.ស.ព និងបន្ទាប់ពីខ្លួនបានប្រើប្រាស់អង្គហេតុនេះក្នុងដីកាដំណោះស្រាយរបស់ខ្លួន ពិតជាបង្ហាញនូវគោលជំហរដដែល ដូចដែល ស.ច.ស បានធ្វើឡើងក្នុងដីការបស់ខ្លួន លើកទីមួយសម្រេចបដិសេធដើមបណ្តឹងរដ្ឋប្បវេណីជាជនជាតិវៀតណាម ពោលគឺ ស.ច.ស បន្តបដិសេធរាល់អ្នកដាក់ពាក្យសុំជាជនជាតិវៀតណាម មិនឱ្យទទួលបានសិទ្ធិធ្វើជាដើមបណ្តឹងរដ្ឋប្បវេណី អនុលោមតាមវិធានផ្ទៃក្នុង។

---

[90] ក.ស.ច.ស “ដីកាដំណោះស្រាយ” ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០ ឯកសារលេខ ទំព័រ១៨៦ ដល់២០៩ កថាខណ្ឌ ៧៩១ ដល់ ៨៤១។

002/19-09-2007-អ.វ.ត.ក/ក.ស.ច.ស(អបជ)

១២៩. សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីតំណាងអ្នកដាក់ពាក្យសុំជនជាតិភាគតិចវៀតណាម ស្នើឱ្យអង្គបុរេជំនុំជម្រះ ច្រានចោលការសម្រេចមិនទទួលយកពាក្យសុំរបស់ ស.ច.ស និងផ្តល់ឋានៈជាដើមបណ្តឹងរដ្ឋប្បវេណីដល់អ្នកពាក្យសុំដែលជាជនជាតិវៀតណាមក្នុងខេត្តកំពង់ឆ្នាំង។ គួរកត់សម្គាល់ថា ការស៊ើបសួររបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតបានរកឃើញអង្គហេតុ ដែលថា ការនិរទេសដោយបង្ខំតាមទូកតាមដងទន្លេសាបទៅកាន់ប្រទេសវៀតណាម ត្រូវធ្វើឡើងដោយឆ្លងកាត់ខេត្តព្រៃវែង ដោយខានមិនបាន និងថា អ្នកដាក់ពាក្យសុំ ដែលមានលេខសម្គាល់ D22/2135 និង D22/2136 ត្រូវបានទទួលស្គាល់ជាដើមបណ្តឹងរដ្ឋប្បវេណី ដោយសារតែពួកគាត់បានលើកឡើងពីអង្គហេតុនេះមួយប៉ុណ្ណោះ។

## VII. សំណើសុំការពិចារណា

***សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីស្នើឱ្យចៅក្រមនៃអង្គបុរេជំនុំជម្រះធ្វើការពិចារណាសារជាថ្មី ដោយផ្អែកលើមូលដ្ឋានអង្គហេតុ និងអង្គច្បាប់ ដូចមានបង្ហាញក្នុងបណ្ដឹងឧទ្ធរណ៍នេះ អំពីឋានៈនៃអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីពីខេត្តកំពង់ឆ្នាំង ទាំង១៥រូប ដែលរងការបដិសេធ***

១២៦. ដោយមានអង្គហេតុ និងអង្គច្បាប់ ដែលបានលើកមកបញ្ជាក់ក្នុងបណ្ដឹងឧទ្ធរណ៍នេះ សហមេធាវីតំណាងអ្នកដាក់ពាក្យសុំជនជាតិភាគតិចវៀតណាម ស្នើសុំឱ្យអង្គបុរេជំនុំជម្រះធ្វើការពិចារណាឡើងវិញលើការសម្រេចលើកមុនរបស់ខ្លួនក្នុង "សេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរួមរបស់សហចៅក្រមស៊ើបអង្កេត លេខ D250/3/3 ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១០ និងដីកាសម្រេចលេខ D250/3/2 ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១០ ស្ដីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី" (សេចក្ដីសម្រេចទទួលយកពាក្យសុំរបស់អង្គបុរេជំនុំជម្រះ) ដែលនៅក្នុងសេចក្ដីសម្រេចនេះ អ.ប.ជ បានដម្កល់ការបដិសេធរបស់ ស.ច.ស ចំពោះអ្នកដាក់ពាក្យសុំជាជនជាតិភាគតិចវៀតណាម ដែលមានអាសយដ្ឋាននៅខេត្តកំពង់ឆ្នាំង។

១២៧. មូលដ្ឋានច្បាប់សម្រាប់ការពិចារណាសាជាថ្មីលើសេចក្ដីសម្រេចលើកមុនរបស់ចៅក្រម អ.ប.ជ នឹងត្រូវលើកយកមកវិភាគក្នុងផ្នែកបន្តនៃបណ្ដឹងឧទ្ធរណ៍នេះ ប៉ុន្តែជាបឋម ធ្វើការពិនិត្យលើប្រវត្តិ និងមូលដ្ឋាននៃដំណើរការនីតិវិធីរហូតដល់ពេលបច្ចុប្បន្នទាក់ទងនឹងការទទួលយកអ្នកដាក់ពាក្យសុំជនជាតិភាគតិចវៀតណាមពីខេត្តកំពង់ឆ្នាំង។

## ១. សាវតានៃដំណើរការនីតិវិធី

១២៨. **នៅថ្ងៃទី១៣ ខែមករា ឆ្នាំ២០១០** សហចៅក្រមស៊ើបអង្កេត បានចេញដីកាសម្រេចពីរ គឺ ដីកាសម្រេច (D250/3/3)[91] បដិសេធសំណើមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដែលស្នើឱ្យធ្វើការស៊ើបសួរបន្ថែមលើឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ប្រឆាំងនឹងជនជាតិវៀតណាម និង ខ្មែរក្រោម (សេចក្តីសម្រេចបដិសេធលើសំណើសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីស៊ើបសួរបន្ថែម) និងដីកាសម្រេច D250/3/2)[92] ដែលមិនទទួលយកពាក្យរបស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលមានអាសយដ្ឋាននៅខេត្តកំពង់ឆ្នាំង (**ដីការបស់ ស.ច.ស លើកទីមួយសម្រេចបដិសេធដើមបណ្តឹងរដ្ឋប្បវេណីជាជនជាតិវៀតណាម**)។ ដោយមានការភ័ន្តច្រឡំ ស.ច.ស បានភ្ជាប់សេចក្តីសម្រេចដំបូងដែលបដិសេធលើការស៊ើបសួរបន្ថែម និងដីកាសម្រេចលើកទីពីរ អំពីការទទួលយកពាក្យសុំ។ ស.ច.ស គ្មានមូលដ្ឋានផ្លូវច្បាប់ណាមួយសម្រាប់ឱ្យខ្លួនធ្វើដូចនេះឡើយ។

១២៩. **នៅថ្ងៃទី២៨ ខែមករា ឆ្នាំ២០១០** ក្នុងរយៈពេលប្រហែល ២សប្តាហ៍បន្ទាប់ពីធ្វើសេចក្តីសម្រេចលើកទីមួយ និងលើកទីពីររបស់ ស.ច.ស (សេចក្តីសម្រេចលើកទីពីរបដិសេធអ្នកដាក់ពាក្យសុំដែលជាជនជាតិភាគតិចវៀតណាមទាំង ១៦នាក់ និងអ្នកដាក់ពាក្យសុំជាជនជាតិខ្មែរក្រោមមួយចំនួនទៀត) ក.ស.ច.ស បានពន្យារកាលបរិច្ឆេទចុងក្រោយក្នុងការដាក់ព័ត៌មានបន្ថែមដើម្បីគាំទ្រដល់ពាក្យសុំរបស់ខ្លួន។ ជាចុងក្រោយ កាលបរិច្ឆេទចុងក្រោយនេះពន្យាររហូតដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១០[93]។ *គ្មាននរណាម្នាក់ក្នុងចំណោមអ្នកដាក់ពាក្យសុំដែលត្រូវបានបដិសេធដោយដីការបស់ ស.ច.ស ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១០ មានឱកាសដើម្បីដាក់ឯកសារបន្ថែម*

---

[91] ក.ស.ច.ស "ដីការួម និងសំណើទាំងពីររបស់សហព្រះរាជអាជ្ញាសុំឱ្យបំពេញកិច្ចស៊ើបសួរ ទាក់ទងនឹងខ្មែរក្រោម និងការសម្លាប់រង្គាលនៅក្នុងបាកាន (ខេត្តពោធិ៍សាត់) និងសំណើរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណីសុំការស៊ើបអង្កេតបន្ថែមទាក់ទងនឹងការសម្លាប់ខ្មែរក្រោម និងជនជាតិវៀតណាម ថ្ងៃទី១៣ ខែមករា ឆ្នាំ២០១០ ឯកសារលេខ D250/3/3។

[92] ក.ស.ច.ស "ដីកាសម្រេចអំពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ទាក់ទងនឹងសំណើលេខ D250/3"

[93] សារណារបស់ ក.ស.ច.ស ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១០ ឯកសារលេខ D337។ សូមមើលឯកសារលេខ D337/6។ បណ្តឹងឧទ្ធរណ៍របស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីប្រឆាំងនឹងដីកាសម្រេចស្តីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលមានអាសយដ្ឋាននៅខេត្តកំពង់ឆ្នាំង (D417)

*ក្នុងការគាំទ្រការទាមទាររបស់គេទេ។* នេះគឺជាភាពខ្វះចន្លោះផ្នែកនីតិវិធីដ៏ធ្ងន់ធ្ងរ ដែលមិនអាចទទួលយកបាន និងគួរសោកស្តាយ របស់តុលាការក្នុងការសម្រេចពីភាពអាចទទួលយកបាន។

១៣០. **នៅថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១០** សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានដាក់បណ្តឹងឧទ្ធរណ៍មួយប្រឆាំងសេចក្តីសម្រេចរបស់ ស.ច.ស បដិសេធសំណើឱ្យធ្វើការស៊ើបសួរបន្ថែម (D274/4/1)[94] និងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់ ស.ច.ស លើកទីមួយសម្រេចបដិសេធដើមបណ្តឹងរដ្ឋវេណីជាជនជាតិវៀតណាម (D250/3/2/1/1) (**ដីការបស់ ស.ច.ស លើកទីមួយសម្រេចបដិសេធដើមបណ្តឹងរដ្ឋប្បវេណីជាជនជាតិវៀតណាម**)[95]។

១៣១. **នៅថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១០** អ.ប.ជ បានចេញសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរួមរបស់សហចៅក្រមស៊ើបអង្កេត D250/3/3 និង D250/3/2 ដោយតម្កល់សេចក្តីសម្រេចមិនទទួលយកពាក្យបណ្តឹងរបស់ ស.ច.ស ទាក់ទងនឹងអ្នកដាក់ពាក្យសុំជនជាតិភាគតិចវៀតណាមទាំងអស់ (**សេចក្តីសម្រេចរបស់ អ.ប.ជ ទាក់ទងនឹងអ្នកដាក់ពាក្យសុំជនជាតិវៀតណាម**)។

១៣២. នៅថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១០ អនុលោមតាមគំនិតដោយឡែករបស់ចៅក្រមប្រាក់ គឹមសាន និង ចៅក្រម Rowan DOWNING ទាក់ទងនឹងអ្នកដាក់ពាក្យទាំង៤ នាក់ ដែលបានទទួល "ឋានៈដើមបណ្តឹងរដ្ឋប្បវេណីបណ្តោះអាសន្ន[96]" ពាក្យសុំរបស់ D22/125/3, D22/171/4,

---

[94] សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី "បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរួម អំពីដីការសម្រេចលើសំណើទាំងពីររបស់សហព្រះរាជអាជ្ញា សុំឱ្យបំពេញកិច្ចស៊ើបសួរទាក់ទងនឹងខ្មែរក្រោម និងសំណើរបស់មេធាវីដើមបណ្តឹងរដ្ឋបវេណីសុំការស៊ើបអង្កេតបន្ថែមទាក់ទងនឹងប្រល័យពូជសាសន ខ្មែរក្រោមនិងជនជាតិវៀតណាម" ថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១០ ឯកសារលេខ D274/4/1។

[95] សហមេធាវីតំណាងរដ្ឋប្បវេណីតំណាងដើមបណ្តឹងរដ្ឋប្បវេណី "បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាអំពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ទាក់ទងនឹងសំណើ ឯកសារលេខ D250/3 ថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១០ ឯកសារលេខ D250/3/2/1/1។

[96] គំនិតដោយឡែករបស់ចៅក្រម Rowan Downing និងចៅក្រម ប្រាក់ គឹមសាន បញ្ជាក់ថា ៖ (ក) លិខិតពីក្រឡាបញ្ជីរបស់ ស.ច.ស "បានបញ្ជាក់ពីសេចក្តីសម្រេចមួយទទួលយកកូនក្តីរបស់យើង (VN01, VN02, VN04 និង VN10) ជាដើមបណ្តឹងរដ្ឋប្បវេណី" (ខ) បានទទួលយកពីលើកមុនដើមបណ្តឹងរដ្ឋប្បវេណី ដែលជាកូនក្តីរបស់យើងថា "គួររក្សាឋានៈរបស់គេជាដើមបណ្តឹងរដ្ឋប្បវេណី ដោយទុកឱ្យអង្គជំនុំជម្រះសាលាដំបូង" ធ្វើការកំណត់បន្ថែមទៀត ទាក់ទងនឹងសិទ្ធិរបស់បណ្តឹងឧទ្ធរណ៍របស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីប្រឆាំងនឹងដីកាសម្រេចស្តីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលមានអាសយដ្ឋាននៅខេត្តកំពង់ឆ្នាំង (D417)

D22/172/2 និង D22/205/2 ត្រូវបានដាក់ដោយសហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី[97] ទៅឱ្យក.ស.ច.ស តាមរយៈអង្គភាពគាំពារជនរងគ្រោះ។ លិខិតនេះគឺស្ថិតនៅ **ឧបសម្ព័ន្ធ ឃ**។

១៣៣. តាមរយៈអនុស្សរណៈផ្ទៃក្នុង ចុះថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០១០[98] សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីបានទទួលព័ត៌មានពី ស.ច.សថា ពាក្យសុំទាំងនេះមិនត្រូវបានពិចារណាសាជាថ្មី ដោយមូលហេតុថា ៖

"មិនមានការកំណត់ថា ដីកាមួយដែលសម្រេចបដិសេធមិនទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីហើយ អាចត្រូវបានប្ដឹងជំទាស់តាមវិធីផ្សេង ក្រៅពីការប្ដឹងឧទ្ធរណ៍ ដែលជាវិធីមួយត្រូវបានប្រើប្រាស់រួចហើយនៅក្នុងរឿងនេះ នោះទេ"។

ស.ច.ស បានធ្វើការសន្និដ្ឋានថា "មិនចាំបាច់មានការសម្រេចម្ដងទៀតពីភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីទាំងនេះ"[99]ឡើយ។

១៣៤. ឥទ្ធិពលនៃដំណើរការនីតិវិធីទាំងនេះគឺថា អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ដែលជាជនជាតិភាគតិចវៀតណាម (ដែលត្រូវបានបដិសេធ)ទាំង១៦ នាក់ដំបូង ត្រូវបានគេដកហូតសិទ្ធិដ៏សំខាន់ក្នុងការចូលរួមក្នុងដំណើរការនីតិវិធី និងឱកាសនានា ដែលត្រូវផ្ដល់ឱ្យអ្នកដាក់ពាក្យតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីផ្សេងៗ។ ឧទាហរណ៍ដែលច្បាស់ក្រឡែតបំផុតនៃបញ្ហានេះគឺថា អ្នកដាក់ពាក្យសុំទាំងនេះត្រូវបានបដិសេធ មុនពេល ស.ច.ស បានសម្រេចផ្ដល់

---

ដើមបណ្ដឹងរដ្ឋប្បវេណីក្នុងការទាមទារសំណង និង (គ)ដើមបណ្ដឹងរដ្ឋប្បវេណីទាំងនេះអាចដាក់សាជាថ្មី "ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ប្រសិនបើពួកគេជឿថា កាលៈទេសៈ និងការទាមទាររបស់ពួកគេ ដែលស្ថិតនៅក្នុងវិសាលភាពនៃកិច្ចស៊ើបសួរ មិនត្រូវបានបញ្ជាក់បានត្រឹមត្រូវពីដំបូងទេ"។ អ.ប.ជ "សេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរួម D250/3 របស់ ស.ច.ស ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១០ និងដីកាសម្រេច D250/3/2 ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១០ ស្ដីពីការទទួលយកពាក្យតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី កថាខណ្ឌ ១៥ ដល់១៧។

[97] លិខិតពីសហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី លោក នី ច័ន្ទឌី និងលោកស្រី Lyma NGUYEN ផ្ញើជូនសហចៅក្រមស៊ើបអង្កេត ដែលមានចំណងជើងថា "សំណើសុំទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី 08-VU-02379 (VN01), (VN02), 08-VU-02116 (VN04) និង 08-VU-02291 (VN10) ចុះថ្ងៃទី២៨ ខែមេសា ឆ្នា២០១០។

[98] អនុស្សរណៈផ្ទៃក្នុងរបស់ ក.ស.ច.ស មានចំណងជើងថា "សំណើរបស់លោក-លោកស្រី ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១០ ទាក់ទិននឹងការទទួលយល់ព្រមលើពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី" ឯកសារលេខ D250/3/2/4។

[99] ដូចខាងលើទំព័រទី២។

ឱកាសបន្ថែមឲ្យអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដទៃផ្សេងៗទៀតដាក់ព័ត៌មានបន្ថែម ដើម្បីគាំទ្រការទាមទាររបស់ខ្លួន រួមទាំងការដាក់អង្គហេតុនានា ដែលបានដាក់ក្នុងវិសាលភាពដ៏ចង្អៀតនៃកិច្ចស៊ើបសួរ (និងមានការភ័ន្តច្រឡំ)របស់ ក.ស.ច.ស។ បញ្ហានេះធ្វើឲ្យអ្នកដាក់ពាក្យសុំទាំង១៦នាក់ ដែលជាកម្មវត្ថុនៃដីការបស់ ស.ច.ស លើកទីមួយសម្រេចបដិសេធដើមបណ្តឹងជាជនជាតិវៀតណាម មិនទទួលបានភាពយុត្តិធម៌។

**២. មូលដ្ឋាន ដែល អ.ប.ជ អាចពិចារណាឡើងវិញលើសេចក្តីសម្រេច ដែលបានធ្វើពីលើកមុន**

១៣៥. យើងកត់សម្គាល់ឃើញថា គោលការណ៍នៃ*អាជ្ញាអស់ជំនុំ* ជាញឹកញាប់នាំឲ្យមានការសម្រេចមិនយុត្តិធម៌ ប្រសិនបើមិនផ្តល់សិទ្ធិប្តឹងឧទ្ធរណ៍ ឬពិនិត្យពិចារណាសាជាថ្មី។ នៅក្នុងកាលៈទេសៈបច្ចុប្បន្ន យើងស្នើឲ្យ អ.ប.ជ ប្រើប្រាស់ឆន្ទានុសិទ្ធិរបស់ខ្លួនធ្វើការពិចារណាសាជាថ្មីនូវសេចក្តីសម្រេចដែលបានធ្វើពីពេលមុន ដោយសារមានអង្គហេតុថ្មី កាលៈទេសៈថ្មី និងទឡ្ហីករណ៍ថ្មី ទាក់ទងនឹងស្ថានភាពដែលមានលក្ខណៈដូចគ្នាបេះបិទទៅនឹងសេចក្តីសម្រេចកាលពីលើកមុន[100]។

១៣៦. ដោយសារបណ្តឹងឧទ្ធរណ៍នេះលើកឡើងពីអង្គហេតុ និងអំណះអំណាងថ្មី ដែលអនុវត្តតាមវិធីសាស្ត្រមួយដូចគ្នាបេះបិទនឹងសេចក្តីសម្រេចលើកមុន យ៉ាងហោចណាស់ វាជាការសមស្រប ឬជាការសំខាន់ដែល អ.ប.ជ ត្រូវពិចារណាសាជាថ្មីនូវសេចក្តីសម្រេច ទាក់ទងនឹងអ្នកដាក់ពាក្យសុំទាំង១៥ ដែលឋានៈរបស់ពួកគេត្រូវបានកំណត់ពីលើកមុន ដោយសារតែព័ត៌មាន និងការធ្វើសេចក្តីសន្និដ្ឋានមិនគ្រប់គ្រាន់ (សូមបញ្ជាក់ថា អ្នកដាក់ពាក្យសុំម្នាក់ក្នុងចំណោមអ្នកដាក់ពាក្យ

---

[100] អ.ប.ជ "សេចក្តីសម្រេចលើពាក្យសុំពិចារណាសាជាថ្មីអំពីសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការថ្លែងប្រាស្រ័យ ជូនអង្គបុរេជំនុំជម្រះដោយខ្លួនឯង" ថ្ងៃទី២៨ ខែសីហា ឆ្នាំ២០០៨ ឯកសារលេខ C22/I/68។ អ.ប.ជ បានពិចារណាថា អង្គហេតុ ទឡ្ហីករណ៍ ឬការផ្លាស់ប្តូរថ្មីនៃកាលៈទេសៈ គឺជាមូលដ្ឋាន ទាក់ទងនឹងការដាក់ពាក្យឲ្យពិចារណាសាជាថ្មី។ យោងតាមយុត្តិសាស្ត្រអន្តរជាតិនៃតុលាការ *ពិសេស* អង្គហេតុថ្មី និងអំណះអំណាងថ្មី គឺជាកាលៈទេសៈ ដែលអាចរក្សាបណ្តឹងឲ្យមានការពិចារណាសាឡើងវិញ។ មើល *រដ្ឋអាជ្ញា តទល់នឹង Thomas Lubanga Dyilo*, ICC-01/04-01/06 សំណើឲ្យអង្គបុរេជំនុំជម្រះធ្វើការពិចារណាសាជាថ្មី ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៦ កថាខណ្ឌ ៨ *រដ្ឋអាជ្ញា តទល់នឹង Milosovic*, IT-02-54-T សេចក្តីសម្រេចស្តីពីបណ្តឹងអាជ្ញាឲ្យធ្វើការពិចារណាសាជាថ្មី ទាក់ទងនឹង ភស្តុតាងនៃសាក្សីដោះបន្ទុក ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០០៥ កថាខណ្ឌ ៧។

សុំទាំង ១៦នាក់ ដែលជាកម្មវត្ថុនៃសេចក្តីសម្រេចនេះ បានទទួលមរណភាពហើយ)[101]។ នៅក្នុងកាលៈទេសៈទាំងនេះ ការខកខានមិនបានពិចារណាសាជាថ្មី អាចបណ្តាលឲ្យមានភាពអយុត្តិធម៌សម្រាប់ដាក់ដាក់ពាក្យសុំទាំងនេះ។

១៣៧. យើងកត់សម្គាល់ឃើញថា នៅក្នុងសេចក្តីសម្រេចទាក់ទងនឹងសំណើឲ្យធ្វើសុំពិចារណាសាជាថ្មីរបស់ដើមបណ្តឹងរដ្ឋប្បវេណី អង្គបុរេជំនុំជម្រះ បានបញ្ជាក់ថា ពាក្យសុំពិចារណាសាជាថ្មី "អាចទទួលយកបាន ប្រសិនបើមានមូលដ្ឋានស្របច្បាប់ដាក់ជូនអង្គបុរេជំនុំជម្រះ ដើម្បីឲ្យធ្វើការពិចារណាលើសេចក្តីសម្រេចរបស់ខ្លួនកាលពីលើកមុន"[102]។ ដោយផ្អែកលើយុត្តិសាស្ត្រតុលាការ *មិនអចិន្ត្រៃយ៍* អន្តរជាតិ គេបានរកឃើញថែមទៀតថា អង្គបុរេជំនុំជម្រះមានអំណាចជាមូលដ្ឋានសម្រាប់ពិចារណាសាជាថ្មីចំពោះសេចក្តីសម្រេច ដែលខ្លួនបានចេញកាលពីលើកមុន ដោយសារមានការប្រែប្រួលកាលៈទេសៈ ឬនៅពេលខ្លួនកត់សម្គាល់ឃើញថា សេចក្តីសម្រេចលើកមុនមានកំហុស ឬបណ្តាលឲ្យមានភាពអយុត្តិធម៌[103]។ អ.ប.ជ នាពេលថ្មីៗនេះប្រកាន់គោលជំហរថា "អង្គបុរេជំនុំជម្រះកំណត់ករណីនីមួយៗ ដោយផ្អែកលើអង្គសេចក្តី និងបញ្ហាដែលបានលើកឡើង"[104]។

១៣៨. វិធីសាស្ត្រនេះមានភាពស៊ីសង្វាក់គ្នានឹងយុត្តិសាស្ត្ររបស់អង្គជំនុំជម្រះតុលាការកំពូលរបស់ ICTY ដែលបានថ្លែងថា "វាត្រូវមានការបញ្ជាក់ថា អង្គជំនុំជម្រះសាលាដំបូងតែងតែពិចារណាសាជាថ្មីនូវសេចក្តីសម្រេច ដែលបានធ្វើពីលើកមុន"[105]។ អង្គជំនុំជម្រះសាលាដំបូង ICTR បាន

---

[101] 09-VU-00685 (D22/287) ក៏ត្រូវបានបដិសេធដោយ ស.ច.ស ក្នុងដីកាសម្រេច នៅថ្ងៃទី១៣ ខែមករា ឆ្នាំ២០១០ បានទទួលមរភាព។ សមាជិកគ្រួសាររបស់អ្នដាក់ពាក្យសុំនេះ បានបញ្ជាក់បន្ថែមថា ពួកគេពុំមានបំណងចង់បន្តពាក្យសុំរបស់អ្នកដាក់ពាក្យសុំនេះទេ។

[102] អ.ប.ជ "សេចក្តីសម្រេចលើពាក្យសុំពិចារណាសាជាថ្មីអំពីសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការថ្លែងប្រាស្រ័យជូនអង្គបុរេជំនុំជម្រះ ដោយខ្លួនឯង" ថ្ងៃទី២៨ ខែសីហា ឆ្នាំ២០០៨ ឯកសារលេខ C22/I/68 កថាខណ្ឌ ២៥។

[103] ដូចខាងលើ។

[104] ដូចខាងលើ កថាខណ្ឌ ១២។

[105] *រដ្ឋអាជ្ញា តទល់នឹង Milosevic*, IT-02-54-AR73 មូលហេតុនៃការបដិសេធទុកចោលបណ្តឹងឧទ្ធរណ៍ពីសេចក្តីសម្រេចជំទាស់នឹងពេលវេលាកំណត់ ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០០២ កថាខណ្ឌ១៧។ មើលផងដែរ *រដ្ឋអាជ្ញា តទល់នឹង Milosevic*, បណ្តឹងឧទ្ធរណ៍របស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីប្រឆាំងនឹងដីកាសម្រេចស្តីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលមានអាសយដ្ឋាននៅខេត្តកំពង់ឆ្នាំង (D417)

00634053



កត់សម្គាល់ឃើញថា "អង្គជំនុំជម្រះមានអំណាចជាមូលដ្ឋាន ដើម្បីពិចារណាសាជាថ្មីសេចក្តីសម្រេចផ្ទាល់ខ្លួន[106]" ហើយតុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូនបានទទួលស្គាល់គោលការណ៍ជាទូទៅថា "នៅពេលតម្រូវការឲ្យមានយុត្តិធម៌ តុលាការអាចកែប្រែ ឬលុបចោលដីកាសម្រេចលើកមុន ឬពិចារណាសាជាថ្មីលើសេចក្តីសម្រេចបន្ទាន់បន្តំ[107]"។

**៣. សំណើសុំពិចារណាសាជាថ្មីលើសាលដីការបស់ អ.ប.ជ ក្នុងឯកសារលេខ D274/4/5 ដើម្បីជាផលប្រយោជន៍យុត្តិធម៌ ដោយផ្អែកទៅលើអង្គហេតុ កាលៈទេសៈ និងសេចក្តីសន្និដ្ឋានថ្មី**

១៣៩. ដោយផ្អែកលើមូលហេតុនៃអង្គហេតុ អង្គច្បាប់ និងនីតិវិធីខាងលើ ប្រសិនបើ អ.ប.ជ សម្រេចថា អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលជាកម្មវត្ថុនៃបណ្តឹងឧទ្ធរណ៍នេះ គួរត្រូវបានទទួលយកនោះ សហមេធាវីសម្រាប់ដាក់ពាក្យសុំទាំងនេះស្នើឲ្យ អ.ប.ជ ពិចារណាសាជាថ្មីឋានៈនៃអ្នកដាក់ពាក្យសុំដែលជនជាតិភាគតិចវៀតណាមទាំង ១៥ នាក់ពីខេត្តកំពង់ឆ្នាំង

---

IT-02-54-T សាលក្រមលើបណ្តឹងអាជ្ញាសុំឲ្យពិចារណាសាជាថ្មី ទាក់ទងនឹងភស្តុតាងសាក្សីដោះបន្ទុក ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០០៥ កថាខណ្ឌ ៦ ដល់៧។ *រដ្ឋអាជ្ញា តទល់នឹង Nikolic*, IT-02-60/1-A សាលក្រមលើញត្តិបន្ទាន់របស់ម្ចាស់បណ្តឹងឧទ្ធរណ៍ បណ្តឹងឧទ្ធរណ៍សុំធ្វើការពិចារណាសាជាថ្មី" ចុះថ្ងៃទី៦ ខែមេសា ឆ្នាំ២០០៥ *រដ្ឋអាជ្ញា តទល់នឹង Blaskic* IT-95-14-A សាលក្រមអំពី "ចម្លើយបឋម និងញត្តិរបស់រដ្ឋអាជ្ញាសម្រាប់ការបំភ្លឺ" ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០០៣ កថាខណ្ឌ ៧។

[106] មើលឧទាហរណ៍ *រដ្ឋអាជ្ញា តទល់នឹង Karemera និងអ្នកផ្សេងទៀត* ICTR-98-44-T សាលក្រមលើញត្តិរបស់ Joseph Nzirorera ស្នើសុំឲ្យពិចារណាសាជាថ្មី ឬបញ្ជាក់លើបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០០៥ កថាខណ្ឌ ៨ *Nahimana និងអ្នកផ្សេងទៀត តទល់នឹង រដ្ឋអាជ្ញា* ICTR-99-52-A សាលក្រមលើសំណើរបស់ Jean-Bosco Barayagwiza ឲ្យពិចារណាសាជាថ្មី ចុះថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០០៥។

[107] *រដ្ឋអាជ្ញា តទល់នឹង Brima និងអ្នកផ្សេងទៀត*, SCLSL-04-16-AR73 គំនិតស្របដោយឡែករបស់ចៅក្រម Robertson ស្តីពីសាលក្រមលើញត្តិបណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តី Brima-Kamara ប្រឆាំងសេចក្តីសម្រេចភាគច្រើនអង្គជំនុំជម្រះសាលាដំបូង II ទាក់ទងនឹងញត្តិបន្ទាន់បំផុត ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៥ កថាខណ្ឌ២៤ និង ៤៩ *រដ្ឋអាជ្ញា តទល់នឹង Normal និងអ្នកផ្សេងទៀត* SCSL-04-14-T សាលក្រមលើញត្តិបន្ទាន់សុំឲ្យពិចារណាសាថ្មីនៃដីកាសម្រេច ស្របតាមដីកាទាក់ទងនឹងការរៀបចំ និងបង្ហាញនៃករណីរបស់មេធាវីការពារ ថ្ងៃទី[៧៦] ខែធ្នូ ឆ្នាំ២០០៥ កថាខណ្ឌ ៩ ដល់កថាខណ្ឌ ១៤។

ដែល ស.ច.ស បានសម្រេចថាមិនអាចទទួលយកបាន (សេចក្ដីសម្រេចដែលត្រូវបានតម្កល់ដោយចៅក្រមភាគច្រើនរបស់ អ.ប.ជ)[108]។

១៤០. មូលដ្ឋាននៃសំណើនេះគឺថា ការទាមទារ ដែលបានលើកឡើងជាសំខាន់លើបញ្ហាអង្គហេតុ និងអង្គច្បាប់ដូចគ្នា ដូចមានបញ្ចូលក្នុងបណ្ដឹងឧទ្ធរណ៍នេះ មិនត្រូវបាន "បញ្ជាក់យ៉ាងត្រឹមត្រូវពីដំបូង"[109]ឡើយ។ ជាពិសេស បណ្ដឹងឧទ្ធរណ៍ដំបូងពីភាពអាចទទួលយកបាននៃជនជាតិវៀតណាម (D250/3/12/1/1) ទាក់ទងនឹងអ្នកដាក់ពាក្យជាជនជាតិភាគតិចវៀតណាម ដែលត្រូវបានបដិសេធទាំង១៦ នាក់ដំបូង បានធ្វើអំណះអំណាងថា "អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីជាជនជាតិវៀតណាមទាំងអស់ ស្ថិតក្នុងវិសាលភាពនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ[110]របស់ ក.ស.ព និងថា "ការស៊ើបសួរ ដែលបានធ្វើឡើងដោយ ក.ស.ច.ស ក្នុងខេត្តកំពង់ឆ្នាំង បានធ្វើឱ្យជនរងគ្រោះដែលជាជនជាតិភាគតិចវៀតណាមស្ថិតក្នុងវិសាលភាពនៃ "អង្គហេតុក្រោមកិច្ចស៊ើបសួរ"[111]។ ទោះបីយ៉ាងណាក៏ដោយ ការសន្និដ្ឋានទាំងអស់នេះត្រូវបានធ្វើឡើង ដោយមិនធ្វើការយោងលើដីកាបញ្ជូនសំណុំរឿងមូលទៅពិនិត្យរបស់ ក.ស.ព ដែលធ្វើការបញ្ជាក់ពីវិសាលភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ និងមិនបានបញ្ជាក់ត្រឹមត្រូវថា បទសម្ភាសន៍របស់ ក.ស.ច.ស ក្នុងខេត្តកំពង់ឆ្នាំង បង្កើតបានជាកិច្ចស៊ើបសួរ ដែលជួយដល់ការ

---

[108] អ្នកដាក់ពាក្យសុំម្នាក់ 09-VU-00685 (D22/287) ដែលត្រូវបានច្រានចោលដោយ ស.ច.ស នៅក្នុងដីកាសម្រេចចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១០ បានទទួលមរណភាព។ សមាជិកគ្រួសារបញ្ជាក់បន្ថែមថា ពួកគេគ្មានបំណងបន្តពាក្យសុំរបស់អ្នកដាក់ពាក្យសុំម្នាក់នេះ។

[109] ចៅក្រម Rowan DOWNING និងចៅក្រម ប្រាក់ គឹមសាន ក្នុង "សេចក្ដីសម្រេចរបស់ អ.ប.ជ លើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីការួមរបស់ ស.ច.ស D250/3 ថ្ងៃទី១៣ ខែមករា ឆ្នាំ២០១០ និងដីកាសម្រេច D250/3/2 ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១០ លើភាពអាចទទួលយកបាននៃសំណើសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី" ក្នុងកថាខណ្ឌ ១៧ បានទទួលស្គាល់ថា "កាលៈទេសៈ និងការទាមទារ ស្ថិតក្នុងវិសាលភាពនៃកិច្ចស៊ើបសួរ មិនត្រូវបានបញ្ជាក់ត្រឹមត្រូវពីដំបូង"។

[110] សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី "បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចពីភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ទាក់ទងនឹងសំណើ 250/3" ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១០ ឯកសារលេខ D250/3/2/1/1 កថាខណ្ឌ ៣ និងកថាខណ្ឌ ៣៥ ដល់កថាខណ្ឌ ៣៨។

[111] ដូចខាងលើ កថាខណ្ឌ ៣ និងកថាខណ្ឌ ៤១ ដល់កថាខណ្ឌ ៤៣។

បង្កើត "ធាតុផ្សំផ្នែកយុត្តាធិការ"[112] ក្នុងអត្ថន័យថា "អង្គហេតុថ្មីដែលកំហិតត្រឹមតែស្ថានទម្ងន់ទោសទាក់ទងនឹងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបច្ចុប្បន្ន" អនុលោមតាមវិធាន ៥៥(៣)នៃវិធានផ្ទៃក្នុង"។ អាស្រ័យហេតុនេះ សហមេធាវីតំណាងអ្នកដាក់ពាក្យសុំទាំងនេះសន្និដ្ឋានថា ការតម្កល់របស់ អ.ជ.ប ទៅលើដីកាបដិសេធរបស់ ស.ច.ស ត្រូវបានធ្វើឡើងដោយផ្អែកលើព័ត៌មានមិនគ្រប់គ្រាន់ ឬសេចក្តីសន្និដ្ឋានដែលមិនត្រូវបានបញ្ជាក់ឱ្យបានត្រឹមត្រូវពីដំបូង។

១៤១. ជារួម អ្នកដាក់ពាក្យសុំទាំង១៦ នាក់ដំបូង រួមទាំងអ្នកដាក់ពាក្យសុំទាំង ២៤ នាក់ ដែលជាកម្មវត្ថុនៃបណ្តឹងឧទ្ធរណ៍ បានបង្កើតជាសាច់រឿងដូចគ្នាបេះបិទ ដែលបង្ហាញពីទម្រង់នៃការធ្វើទុក្ខបុកម្នេញ និងការអនុវត្តគោលនយោបាយប្រល័យពូជសាសន៍របស់ពួកខ្មែរក្រហម ដែលបានរៀបចំឡើង និងអនុវត្តក្នុងខេត្តកំពង់ឆ្នាំង។ អ្នកដាក់ពាក្យសុំទាំង ៤០នាក់បានទទួលរងទង្វើដែលជាឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ (រួមមានការជម្លៀសដោយបង្ខំក្នុងទ្រង់ទ្រាយធំចេញពីប្រទេសកម្ពុជា ការបង្កើតឱ្យមានលក្ខខណ្ឌនៃជីវិតដែលនាំដល់ការបំផ្លាញក្រុមរបស់គេ វិធានការនានាដែលមានបំណងរារាំងមិនឱ្យមានការផ្តល់កំណើតទារក) និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ (រួមទាំងការធ្វើបំលាស់ទីដោយបង្ខំ ការសម្លាប់បំផុតពូជ និងការធ្វើទុក្ខបុកម្នេញលើក្រុមជនជាតិភាគតិចវៀតណាម)។ អង្គហេតុទាំងនេះ ដែលបានរៀបរាប់ដំបូងក្នុង "សំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណីឱ្យធ្វើការស៊ើបសួរបន្ថែមទាក់ទងនឹងទង្វើប្រល័យពូជសាសន៍ខ្មែរក្រោម និងប្រជាជនវៀតណាម[113]" និងនៅពេលនេះបានរៀបរាប់ក្នុងដីកាសម្រេចស្ថាពរ[114] របស់ ក.ស.ព ត្រូវបានដាក់បញ្ចូលជាឯកសារយោង ក្នុងបណ្តឹងឧទ្ធរណ៍នេះ។ ប្រការសំខាន់នោះគឺថា ការនិរទេសដោយបង្ខំទៅកាន់ប្រទេសវៀតណាមនេះមានទំនាក់ទំនងជាមួយនឹង "ការប្រព្រឹត្តិចំពោះប្រជាជនវៀតណាមក្នុងខេត្តព្រៃវែង" ពីព្រោះការនិរទេសតាមទូកទាំងអស់ត្រូវធ្វើឡើងដោយឆ្លងកាត់ ឬឈប់នៅផ្សារអ្នកលឿងក្នុងខេត្តព្រៃវែង ហើយដើម

---

[112] ដូចខាងលើ កថាខណ្ឌ ៣ និងកថាខណ្ឌ ៤១ ដល់កថាខណ្ឌ ៤៣។

[113] សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី "សំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណី សុំឱ្យស៊ើបសួរបន្ថែម ទាក់ទងនឹងទង្វើប្រល័យពូជសាសន៍ខ្មែរកម្ពុជាក្រោម និងប្រជាជនវៀតណាម" កថាខណ្ឌ ៤១ ដល់កថាខណ្ឌ ៦៣។

[114] ក.ស.ព "សេចក្តីសន្និដ្ឋានស្ថាពររបស់សហសព្រះរាជអាជ្ញា អនុលោមតាមវិធាន ៦៦" កថាខណ្ឌ ៧៨៧ ដល់កថាខណ្ឌ ៧៨៩។ មើលផងដែរត្រង់ផ្នែក "ឧក្រិដ្ឋកម្មប្រឆាំងនឹងប្រជាជនវៀតណាម" កថាខណ្ឌ ៧៨៧ ដល់កថាខណ្ឌ ៧៨៩។

បណ្ដឹងរដ្ឋប្បវេណីជនជាតិវៀតណាមពីររូប (D22/2135 និង D22/2136) ត្រូវបានទទួលស្គាល់ ដោយសារតែការឡើងពីការឆ្លងកាត់នេះ។

១៤២. ដោយផ្អែកលើហេតុផលទាំងអស់ ដែលបានលើកឡើងក្នុងបណ្ដឹងឧទ្ធរណ៍នេះ ស.ច.ស បាន បដិសេធអ្នកដាក់ពាក្យសុំដោយភ័ន្តច្រឡំ ដោយឈរលើមូលហេតុថា ព្យសនកម្ម ដែលអ្នកដាក់ពាក្យទាំងនេះបានទទួលរង ពុំមានទំនាក់ទំនងជាមួយ "អង្គហេតុស្ថិតក្រោមកិច្ចស៊ើបសួរ" ដែល នៅក្នុងការសម្រេចទទួលយកពាក្យទាំងនេះ ស.ច.ស មានការយល់ច្រឡំ និងអនុវត្តខុស "អង្គហេតុ" ដែលពួកគេបានទទួលពី ក.ស.ព ដើម្បីធ្វើការស៊ើបអង្កេត។ ជាងនេះទៀត ស.ច.ស បានសម្រេចដោយភ័ន្តច្រឡំក្នុងដីកាសម្រេចខេត្តកំពង់ឆ្នាំងថា ព្យសនកម្មពុំមាន " ទំនាក់ទំនងជាមួយនឹងអង្គហេតុស្ថិតក្រោមការកិច្ចស៊ើបសួរ" ដោយធ្វើការបញ្ជាក់ថា ព្យសនកម្ម នេះ "ស្ថិតនៅខាងក្រៅវិសាលភាពភូមិសាស្ត្រ/ការធ្វើទុក្ខបុកម្នេញលើប្រជាជនវៀតណាម" ហើយដែលដឹងយ៉ាងច្បាស់ថា ព្យសនកម្មដែលអ្នកដាក់ពាក្យសុំដែលជាជនជាតិភាគតិច វៀតណាមបានទទួលរងក្នុងខេត្តកំពង់ឆ្នាំង *បង្កើតបាន* ជាអង្គហេតុស្ថិតក្រោមការស៊ើបអង្កេត។

១៤៣. ដោយសារបណ្ដឹងឧទ្ធរណ៍បានបញ្ជាក់ពីមូលដ្ឋានយ៉ាងត្រឹមត្រូវ ដែល ស.ច.ស *បានទទួល*នូវ អង្គហេតុដែលអ្នកដាក់ពាក្យសុំជាជនជាតិភាគតិចវៀតណាមបានលើកឡើង ហើយបណ្ដឹង ឧទ្ធរណ៍នេះធ្វើការបញ្ជាក់ថា ស.ច.ស បានបដិសេធអ្នកដាក់ពាក្យសុំទាំងនេះ ដោយភ័ន្តច្រឡំ ដោយសារការយល់មិនត្រឹមត្រូវពី "វិសាលភាពនៃកិច្ចស៊ើបសួរ" សហមេធាវីតំណាងអ្នកដាក់ពាក្យសុំទាំងនេះស្នើឲ្យ អ.ប.ជ ពិចារណាសាជាថ្មីពីឋានៈនៃអ្នកដាក់ពាក្យសុំជនជាតិវៀតណាម ទាំង ១៥នាក់ដែលបានដាក់បណ្ដឹងឧទ្ធរណ៍លើកដំបូងស្ដីពីការទទួលយកអ្នកដាក់ពាក្យសុំជន ជាតិវៀតណាម ដោយផ្អែកលើមូលដ្ឋានដូចគ្នានឹងការពិចារណាលើអ្នកដាក់ពាក្យសុំទាំង ២៩ នាក់ ដែលកម្មវត្ថុនៃបណ្ដឹងឧទ្ធរណ៍នេះ។

១៤៤. សហមេធាវីតំណាងអ្នកដាក់ពាក្យសុំដែលជាជនជាតិភាគតិចវៀតណាមនេះ មិនតវ៉ាថា ចៅក្រមនៃ អ.ប.ជ បានធ្វើការសម្រេចដោយភ័ន្តច្រឡំនៅពេល អ.ប.ជបានតម្កល់ការសម្រេច របស់ ស.ច.ស ដែលមិនទទួលយកអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីដែល ជាជនជាតិវៀតណាមទាំង១៦នាក់ ផ្ទុយទៅវិញ បណ្ដឹងឧទ្ធរណ៍តវ៉ាថា នៅពេលប្ដឹងឧទ្ធរណ៍នេះ

00634057



មានព័ត៌មានក្នុងដីកាសន្និដ្ឋានស្ថាពររបស់ ក.ស.ព និងដីកាដំណោះស្រាយ របស់ ស.ច.ស ដែលអាចយកមកប្រើប្រាស់បាន។ បណ្តឹងឧទ្ធរណ៍នេះក៏ធ្វើការយោងការបញ្ជាក់ពី ក.ស.ព អំពីវិសាលភាពនៃកិច្ចស៊ើបសួរ និងបង្ហាញពីបញ្ហាអង្គហេតុ និងអង្គច្បាប់ ដោយមានការបញ្ជាក់ច្បាស់ជាងការបង្ហាញនៅក្នុងបណ្តឹងឧទ្ធរណ៍ដំបូងស្តីពីភាពទទួលយកពាក្យសុំរបស់ជាជនជាតិភាគតិចវៀតណាម។ ដូចនេះ បណ្តឹងឧទ្ធរណ៍នេះដាក់ជូនចៅក្រមអង្គបុរេជំនុំជម្រះនូវព័ត៌មានអង្គហេតុពេញលេញ និងសេចក្តីសន្និដ្ឋានផ្លូវច្បាប់ល្អិតល្អន់ ក្នុងការសម្រេចលើភាពទទួលយកបាន ស្របតាមវិធានផ្ទៃក្នុង។

១៤៥. ផ្អែកលើមូលហេតុដែលបានលើកឡើងក្នុងបណ្តឹងឧទ្ធរណ៍នេះ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានបង្ហាញទំនាក់ទំនងសំខាន់រវាងព្យសនកម្មដែលអ្នកដាក់ពាក្យសុំដែលជាជនជាតិភាគតិចវៀតណាមពីខេត្តកំពង់ឆ្នាំងទទួលរង និង "អង្គហេតុដែលស្ថិតក្រោមកិច្ចស៊ើបសួរ"។ ទាំងនេះគឺជាអង្គហេតុ ដែល ក.ស.ច.សបានទទួលដើម្បីស៊ើបអង្កេត ហើយតាមការពិត*បានស៊ើបអង្កេត* និងជាអង្គហេតុ ដែលជាផ្នែកដ៏សំខាន់របស់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរនៃ ក.ស.ព និងដីកាដំណោះស្រាយរបស់ ស.ច.ស ទាក់ទងនឹងការធ្វើទុក្ខបុកម្នេញ និងការប្រព្រឹត្តិលើប្រជាជនវៀតណាម។ ទោះជាយ៉ាងនេះក្តី ការដែលកិច្ចស៊ើបសួរទាំងនេះត្រូវបានធ្វើឡើងដើម្បីបង្ហាញពី"ធាតុផ្សំផ្នែកយុត្តាធិការ" មិនបានធ្វើឱ្យអង្គហេតុដែលទទួលបានពីបទសម្ភាសន៍ទាំងនេះជាមួយកូនក្តីរបស់យើង មិនស្ថិតក្នុង "វិសាលភាពនៃកិច្ចស៊ើបសួរឡើយ"។

១៤៦. ដូចនេះ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីស្នើឱ្យធ្វើការពិចារណាសាជាថ្មីចំពោះពាក្យសុំទាំង១៥ (ដែលត្រូវបានបដិសេធក្នុងដីការបស់ ស.ច.ស លើកទីមួយសម្រេចបដិសេធដើមបណ្តឹងរដ្ឋប្បវេណីជាជនជាតិវៀតណាម និងដីកាសម្រេចពាក់ព័ន្ធរបស់ អ.ប.ជ) ដែលពាក្យសុំរបស់អ្នកដាក់ពាក្យទាំងនេះលើកឡើងពីអង្គហេតុ និងសេចក្តីសន្និដ្ឋានអង្គច្បាប់មានលក្ខណៈដូចគ្នាបេះបិទទៅនឹងអង្គហេតុ និងសេចក្តីសន្និដ្ឋានអង្គច្បាប់ ដែលបានលើកឡើងក្នុងបណ្តឹងឧទ្ធរណ៍នេះ។ អ្នកដាក់ពាក្យសុំទាំងនេះមានលេខសម្គាល់ D22/125[115]; D22/171[116]; D22/276[117];

---

[115] ទម្រង់ព័ត៌មានជនរងគ្រោះ និងព័ត៌មានបន្ថែម 08-VU-02397 (D22/125)។

[116] ទម្រង់ព័ត៌មានជនរងគ្រោះ និងព័ត៌មានបន្ថែម 08-VU-02380 (D22/171)។

D22/172[118]; D22/277[119]; D22/278[120]; D22/279[121]; D22/280[122]; D22/281[123]; D22/205[124]; D22/282[125]; D22/283[126]; D22/284[127]; D22/285[128]; D22/286[129] (សូមបញ្ជាក់ថា អ្នកដាក់ពាក្យសុំ D22/287 បានទទួលមរណភាពហើយ).[130]

## ៤. ក្នុងនាមជាអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលត្រូវបានកំណត់ជាជនជាតិភាគតិចវៀតណាមនៅ អ.វ.ត.ក អ្នកដែលរស់រានមានជីវិតពីការប្រល័យពូជសាសន៍ទាំងអស់ ដែលមានអាសយដ្ឋាននៅខេត្តកំពង់ឆ្នាំង គួរត្រូវបានទទួលស្គាល់ជាដើមបណ្តឹងរដ្ឋប្បវេណី ផ្អែកតាមគោលការណ៍សីលធម៌

១៤៧. ដូចមានការដកស្រង់ក្នុងដីកាដំណោះស្រាយ របាយការណ៍អ្នកជំនាញផ្នែកប្រជាសាស្ត្រ ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០០៩ បានសន្និដ្ឋានថា នៅខែមេសា ឆ្នាំ១៩៧៥ មានប្រជាជន ដែលជាជនជាតិភាគតិចវៀតណាមប្រមាណជា ២០.០០០ នាក់បានរស់ក្នុងប្រទេសកម្ពុជា ហើយថា

---

117 ទម្រង់ព័ត៌មានជនរងគ្រោះ និងព័ត៌មានបន្ថែម 08-VU-02378 (D22/276)។

118 ទម្រង់ព័ត៌មានជនរងគ្រោះ និងព័ត៌មានបន្ថែម 08-VU-02116 (D22/172)។

119 ទម្រង់ព័ត៌មានជនរងគ្រោះ និងព័ត៌មានបន្ថែម 09-VU-01723 (D22/277)។

120 ទម្រង់ព័ត៌មានជនរងគ្រោះ និងព័ត៌មានបន្ថែម 09-VU-01722 (D22/278)។

121 ទម្រង់ព័ត៌មានជនរងគ្រោះ និងព័ត៌មានបន្ថែម 09-VU-02241 (D22/279)។

122 ទម្រង់ព័ត៌មានជនរងគ្រោះ និងព័ត៌មានបន្ថែម 09-VU-02242 (D22/280)។

123 ទម្រង់ព័ត៌មានជនរងគ្រោះ និងព័ត៌មានបន្ថែម 09-VU-02243 (D22/281)។

124 ទម្រង់ព័ត៌មានជនរងគ្រោះ និងព័ត៌មានបន្ថែម 08-VU-02291 (D22/205)។

125 ទម្រង់ព័ត៌មានជនរងគ្រោះ និងព័ត៌មានបន្ថែម 09-VU-02239 (D22/282)។

126 ទម្រង់ព័ត៌មានជនរងគ្រោះ និងព័ត៌មានបន្ថែម 09-VU-02240 (D22/283)។

127 ទម្រង់ព័ត៌មានជនរងគ្រោះ និងព័ត៌មានបន្ថែម 09-VU-00687 (D22/284)។

128 ទម្រង់ព័ត៌មានជនរងគ្រោះ និងព័ត៌មានបន្ថែម 09-VU-00686 (D22/285)។

129 ទម្រង់ព័ត៌មានជនរងគ្រោះ និងព័ត៌មានបន្ថែម 09-VU-00688 (D22/286)។

130 អ្នកដាក់ពាក្យសុំ 09-VU-00685 (D22/287), ដែលបានបដិសេធ ដោយដីការបស់ ស.ច.ស លើកទីមួយសម្រេចបដិសេធសាក្សីជនជាតិវៀតណាម (ថ្ងៃទី១៣ ខែមករា ឆ្នាំ២០១០), បានទទួលមរណភាពហើយ។ សមាជិកគ្រួសាររបស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីពាក្យសុំ បានបញ្ជាក់បន្ថែមថា ពួកគេពុំមានបំណងចង់បន្តការទាមទាររដ្ឋប្បវេណី របស់អ្នកដាក់ពាក្យដែលបានទទួលមរណភាពនេះទេ។

*"ប្រជាជនវៀតណាមទាំង ២០.០០០ នាក់នេះបានស្លាប់ក្រោមកណ្តាប់ដៃរបស់ពួកខ្មែរក្រហម ក្នុងអំឡុងពេលពីខែមេសា ឆ្នាំ១៩៧៥ ដល់ខែមករា ឆ្នាំ១៩៧៩"* [131] ។ អត្រាលុបបំបាត់ជនជាតិភាគតិចវៀតណាម១០០ភាគរយនេះ បណ្តាលមកពីការអនុវត្តគោលនយោបាយប្រល័យពូជសាសន៍របស់ពួកខ្មែរក្រហមតាមរយៈការបញ្ជូនចេញពីប្រទេសកម្ពុជា និង/ឬការលុបបំបាត់ដោយការសម្លាប់។ កូនក្តីរបស់យើងស្ថិតក្នុងចំណោមក្រុមមនុស្ស ដែលរងការលុបបំបាត់ចេញពីប្រទេសកម្ពុជា ហើយបានវិលត្រឡប់មកប្រទេសកម្ពុជាវិញ ក្នុងអំឡុងពេលផ្សេងៗគ្នាបន្ទាប់ពីឆ្នាំ១៩៧៩ បន្ទាប់ពីការដួលរលំរបបខ្មែរក្រហម។

១៤៨. ក្នុងចំណោមប្រជាជន ១០០ ភាគរយ ដែលត្រូវបានលុបបំបាត់ពីស្ថិតិ កូនក្តីរបស់យើងពីខេត្តកំពង់ឆ្នាំង គឺជាអ្នករស់រានមានជីវិត ដែលត្រូវបានគេស្គាល់ថាជាជនជាតិភាគតិចវៀតណាម ក្នុងការដាក់ពាក្យសុំចូលរួមដំណើរការនីតិវិធីនៅឯ អ.វ.ត.ក។ បញ្ហានេះត្រូវបានបញ្ជាក់បន្ថែមដោយព័ត៌មានរួម ដែលបានទទួលតាមរយៈការស៊ើបសួរបន្ថែមពីអង្គភាពគាំពារជនរងគ្រោះ ក្រុមអ្នកដាក់ច្បាប់តំណាងដើមបណ្តឹងរដ្ឋប្បវេណី គណៈកម្មាធិការប្រព្រឹត្តកម្មនៃអង្គការសមាគមការពារសិទ្ធិមនុស្សកម្ពុជា និងអង្គការអន្តរការីមួយចំនួនទៀត ដូចជា មជ្ឈមណ្ឌលឯកសារកម្ពុជា ADHOC និង KID។ ភាគីពាក់ព័ន្ធទាំងនេះបានបញ្ជាក់បន្ថែមទៀតថា ក្រៅពីអ្នកដាក់ពាក្យសុំ ដែលបានទទួលយក ដោយសារ *ការធ្វើទុក្ខបុកម្នេញលើប្រជាជនវៀតណាម* រួមទាំងប្រជាជនវៀតណាមក្នុងខេត្ត ព្រៃវែង ខេត្តស្វាយរៀង និងការវាយលុកចូលក្នុងប្រទេសវៀតណាម ទីកន្លែងទាំងនេះត្រូវបានប្រកាសដោយ ក.ស.ច.ស ថាស្ថិតក្នុងវិសាលភាពភូមិសាស្ត្រនៃកិច្ចស៊ើបសួរ ដោយមានការបកស្រាយយ៉ាងចង្អៀត។ គ្មាននរណាម្នាក់ត្រូវបានកំណត់ថាជាជនជាតិភាគតិចវៀតណាមឡើយ។ ផ្ទុយទៅវិញ ដើមបណ្តឹងរដ្ឋប្បវេណីទាំងនេះត្រូវបានទទួលយកដោយមូលហេតុថា ពួកគេបានរងព្យសនកម្មពីការបាត់បង់សាច់ញាតិជាជនជាតិវៀតណាម ឬក្រៅពីនេះទទួលរងព្យសនកម្មការធ្វើទុក្ខបុកម្នេញ ដោយការយល់

[131] ក.ស.ច.ស "ដីកាដំណោះស្រាយ" ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០ ឯកសារលេខ D427 កថាខណ្ឌ ៧៩២ ដកស្រង់របាយការណ៍របស់អ្នកជំនាញផ្នែកប្រជាសាស្ត្រ បណ្ឌិត Ewa Tabeau និងលោក They Kheam ត្រង់ទំព័រ ៤៩ ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០០៩ ឯកសារលេខ D140/1/1។

00634060



ឃើញថាពួកគេជាប្រជាជនវៀតណាម ឬជាអ្នកមានទំនាក់ទំនងជាមួយនឹងប្រជាជនវៀតណាម។

១៤៩. សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីអះអាងថា តាមរយៈនិយមន័យ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ គឺជាឧក្រិដ្ឋកម្ម ដែលសំដៅប្រឆាំងនឹង*ក្រុម* ហើយថា ភស្តុតាងបញ្ជាក់ពីផែនការក្នុងការយកក្រុមមួយជាគោលដៅអាចធ្វើការទាញសន្និដ្ឋានបានតាមរយៈ "កម្រិតដែលឧក្រិដ្ឋកម្មទាំងនោះត្រូវបានប្រព្រឹត្ត[132]"។ ការសម្លាប់រង្គាលមនុស្សដោយចេតនា គឺជាឧក្រិដ្ឋកម្មដ៏រន្ធត់មិនអាចប៉ាន់ស្មានបាន ដែលកម្រិត និងលក្ខណៈនៃការឈឺចាប់របស់មនុស្សបន្ទាប់ពីអំពើប្រល័យពូជសាសន៍ ត្រូវបានគេចាត់ទុកថា "ឧក្រិដ្ឋកម្មធ្ងន់ធ្ងរបំផុតក្នុងប្រវត្តិសាស្ត្រ ក្នុងចំណោមជនរងគ្រោះ និងក្នុងចំណោមសាច់ញាតិរបស់គេ តាមការយល់ឃើញរបស់សហគមន៍អន្តរជាតិ"[133]។

១៥០. យោងតាមអត្រានៃការសម្លាប់រង្គាល ១០០ ភាគរយជនជាតិភាគតិចវៀតណាមពីប្រទេសកម្ពុជាក្នុងរបបខ្មែរក្រហម វាគឺជាការកម្រណាស់ក្នុងការជួបជាមួយអ្នករស់រានមានជីវិតជាជនជាតិវៀតណាមពីរបបនោះ។ តាមពិត វាអាចការប្រមាថមើលងាយមួយលើបទពិសោធន៍រួមរបស់ក្រុមជនរងគ្រោះនេះ និងជាការមិនសមហេតុផលទាល់តែសោះ ប្រសិនបើគ្មានដើមបណ្តឹងរដ្ឋប្បវេណីដែលជាជនជាតិភាគតិចវៀតណាមត្រូវបានទទួលយកឱ្យចូលរួមក្នុងដំណើរការនីតិវិធី *ដោយសារតែការធ្វើទុក្ខបុកម្នេញ ឬឧក្រិដ្ឋកម្មប្រល័យពូជសាសន៍លើប្រជាជន*

---

[132] *រដ្ឋអាជ្ញា តទល់ Milosevic* សេចក្តីសម្រេចលើសំណើសុំឱ្យចេញសាលក្រមលើកលែងបទចោទ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៤ កថាខណ្ឌ ២៤៦ ចែងថា "ចេតនាប្រល័យពូជសាសន៍របស់មេដឹកនាំបូស្នី ស៊ែប អាចទាញចេញពីភស្តុតាងនៃទំហំ និងទម្រង់នៃការវាយប្រហារ, ភាពធ្ងន់ធ្ងរនៃការវាយប្រហារ, ចំនួនដ៏ច្រើននៃជនម៉ូស្លីមដែលត្រូវបានសម្លាប់, ការឃុំឃាំងជនម៉ូស្លីម, ការប្រព្រឹត្តយ៉ាងសាហាវព្រៃផ្សៃក្នុងមន្ទីរឃុំឃាំង និងនៅតាមទីកន្លែងផ្សេងៗ, ព្រមទាំងការផ្តោតគោលដៅទៅលើបុគ្គលសំខាន់ៗដែលជាអ្នកការពារដល់ការរស់រានរបស់ក្រុមជនម៉ូស្លីម សុទ្ធតែជាកត្តាដែលនាំទៅដល់ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍"។

[133] អនុសញ្ញាស្តីពីការទប់ស្កាត់ និងផ្តន្ទាទោសចំពោះអំពើប្រល័យពូជសាសន៍ ដែលបានអនុម័តដោយសេចក្តីសម្រេច លេខ 260 (III) A នៃមហាសន្និបាតអង្គការសហប្រជាជាតិ ក្នុងមហាសន្និបាតអង្គការសហប្រជាជាតិ ថ្ងៃទី៩ ខែធ្នូ ឆ្នាំ១៩៤៨។ ចូលជាធរមាននៅថ្ងៃទី១២ ខែមករា ឆ្នាំ១៩៥១។

*វៀតណាម* បើទោះជាមានការចោទពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងជនជាប់ចោទទាំងអស់ ដែលផ្ទុះបញ្ជាំងពីការទទួលខុសត្រូវ និងការចូលរួមរបស់ពួកគេក្នុងសកម្មភាពនានាដែលបានអនុវត្តនៅទូទាំងប្រទេសកម្ពុជា ក្នុងគោលបំណងលុបបំបាត់ក្រុមជនជាតិភាគតិចវៀតណាមក៏ដោយ។

១៥១. នៅចំពោះមុខជនរងគ្រោះ ដីកាសម្រេចរបស់ ស.ច.ស ក្នុងការបដិសេធការមិនឱ្យសមាជិកនៃក្រុមជនជាតិភាគតិចវៀតណាមចូលរួមក្នុងតុលាការនេះ គឺស្រដៀងគ្នាទៅនឹងការបដិសេធថាពួកគេមិនមែនជាជនរងគ្រោះនៃឧក្រិដ្ឋកម្មប្រល័យពូជសាសន៍។ ការបដិសេធលើការទាមទារដ្ឋប្បវេណីរបស់ ស.ច.ស នេះបង្ហាញថា យុត្តិធម៌គឺជាដំណើរការមួយ ដែលត្រូវបានធ្វើឡើងតាមតែអំពើចិត្ត និងតាមជម្រើស ហើយថាឧក្រិដ្ឋកម្មប្រល័យពូជសាសន៍អាចប្រព្រឹត្តដោយគ្មានការដាក់ទោស និងគ្មានការទទួលស្គាល់ពីផលប៉ះពាល់ធ្ងន់ធ្ងរពីឧក្រិដ្ឋកម្មទាំងនេះលើជនរងគ្រោះ ដោយសារឧក្រិដ្ឋកម្មដ៏រន្ធត់ រួមទាំងផលប៉ះពាល់លើសាច់ញាតិរបស់គេទេ។

១៥២. ការបដិសេធរបស់ ស.ច.ស មិនផ្តល់សិទ្ធិចូលរួមដល់ក្រុមនេះគឺជាការរំលោភបំពានដល់គោលបំណងរួមរបស់ អ.វ.ត.ក ក្នុងការស្វែងរក "យុត្តិធម៌ ការបង្រួបបង្រួមជាតិ ស្ថេរភាព សន្តិភាព និងសន្តិសុខ"[134]។ ការបដិសេធនេះដកហូតសិទ្ធិរបស់ក្រុមជនរងគ្រោះនេះក្នុងការចូលរួមក្នុងដំណើរការនីតិវិធីស្វែងរកការពិត និងយុត្តិធម៌ចំពោះការរំលោភបំពានសិទ្ធិមនុស្ស និងភាពថ្លៃថ្នូរយ៉ាងធ្ងន់ធ្ងរ ទ្រង់ទ្រាយធំ និងហួសពីការស្មាន ហើយមិនឱ្យពួកគេអាចប្រឈមមុខនឹងចារីរបស់គេ ដើម្បីព្យាបាលព្យសនកម្មហួសពីការយល់បាន ដែលបុគ្គលម្នាក់ៗ គ្រួសាររបស់គេ និងសហគមន៍របស់គេទាំងមូល បានទទួលរងពីជំនាន់មួយទៅជំនាន់មួយ។

១៥៣. ឥទ្ធិពលនៃការបដិសេធនេះគឺការបំបិទសម្លេងជនរងគ្រោះក្នុងកាលៈទេសៈ ដែលមានអ្នករស់រានមានជីវិតតិចតួចប៉ុណ្ណោះពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ក្នុងប្រទេសកម្ពុជា និងក្នុងស្ថានភាពដែលក្រុមជនជាតិភាគតិចបានទទួលរងការរើសអើងជាប្រចាំក្នុងសង្គមកម្ពុជា និងក្នុងស្ថានភាពដែលសម្លេងរបស់ក្រុមជនជាតិភាគតិចវៀតណាមត្រូវបានគេបំបិទរួចហើយ។

---

[134] មហាសន្និបាតអង្គការសហប្រជាជាតិ សេចក្តីសម្រេចលេខ ៥៧/២២៨ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០១ និងបុព្វកថារបស់វិធានផ្ទៃក្នុង អ.វ.ត.ក។

ផ្អែកតាមទស្សនៈសីលធម៌ អ្នករស់រានមានជីវិតពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ត្រូវតែបានទទួលយកឱ្យចូលរួមក្នុងតុលាការនេះ ប្រសិនបើ អ.វ.ត.ក មានធម្មានុរូបនៅលើឆាកអន្តរជាតិ។

១៥៤. ជាងនេះទៀត ប្រសិនបើ អ.វ.ត.ក មានធម្មានុរូបចំពោះមុខជនរងគ្រោះ ប្រការសំខាន់គឺថា តុលាការទទួលស្គាល់ថា អ្នកដាក់ពាក្យសុំដែលជាជនជាតិភាគតិចវៀតណាម *ទាំងអស់* ក្នុងខេត្តកំពង់ឆ្នាំង គឺជា*ជនរងគ្រោះផ្ទាល់* នៃឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ បន្ទាប់ពីទទួលរងព្យសនកម្មផ្ទាល់ និងជាលក្ខណៈបុគ្គលពីអំពើប្រល័យពូជសាសន៍របស់ពួកខ្មែរក្រហមនេះ។ ឧក្រិដ្ឋកម្មនេះ *ត្រូវបានកំណត់ដោយការកំណត់គោលដៅក្រុមជាក់លាក់មួយនៅក្នុងការអនុវត្តគោលនយោបាយនានាក្នុងគោលបំណងបំផ្លាញក្រុមនោះ ដែលក្នុងករណីនេះ គឺក្រុមជនជាតិភាគតិចវៀតណាមពីព្រោះតែជាតិសាសន៍របស់គេ*។ ដូចនេះ ជនរងគ្រោះទាំងនេះត្រូវតែទទួលយកជាដើមបណ្តឹងរដ្ឋប្បវេណី ដោយសារ*ការធ្វើទុក្ខបុកម្នេញលើប្រជាជនវៀតណាម* ទោះបីជាស្ថិតនៅកន្លែងណាក៏ដោយ និងទោះបីជាអ្នកដាក់ពាក្យសុំនោះលើកអង្គហេតុ ដែលធ្វើឱ្យពួកគេស្ថិតនៅក្រោម ឬមិនស្ថិតនៅក្រោមឧក្រិដ្ឋកម្ម ក្នុងវិសាលភាពនៃកិច្ចស៊ើបសួរក៏ដោយ។

១៥៥. សំខាន់ជាងនេះទៀត ដូចបានគូសបញ្ជាក់នៅក្នុងផ្នែកខាងដើមនៃបណ្តឹងឧទ្ធរណ៍នេះ វាជាការសំខាន់ខាងផ្លូវច្បាប់បំផុតថា បទពិសោធជាក់ស្តែងរបស់អ្នកដាក់ពាក្យសុំទាំងនេះបង្កើតបានជាភស្តុតាងទាំងអស់ ហើយភស្តុតាងទាំងនេះត្រូវបានប្រើប្រាស់ដើម្បីចោទប្រកាន់ជនជាប់ចោទទីមួយៗពីបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ។ "អង្គហេតុស្ថិតក្រោមកិច្ចស៊ើបសួរ" ទាំងនេះមានទំនាក់ទំនងផ្ទាល់ជាមួយនឹងព្យសនកម្មផ្ទាល់ និងជាលក្ខណៈបុគ្គលរបស់អ្នកដាក់ពាក្យសុំម្នាក់ៗ ដែលនេះគឺជាការបំពេញលក្ខណៈវិនិច្ឆ័យដ៏សំខាន់ដើម្បីឱ្យមានការទទួលស្គាល់ពួកគេជាដើមបណ្តឹងរដ្ឋប្បវេណី។

១៥៦. សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីសុំឱ្យថា នៅក្នុងការពិចារណាពីលទ្ធភាពទទួលយកពាក្យសុំរបស់អ្នកដាក់ពាក្យសុំដែលជាជនជាតិភាគតិចវៀតណាមពីខេត្តកំពង់ឆ្នាំង ចៅក្រម អ.ប.ជ គិតគូរដល់កាលៈទេសទាំងនេះ ដែលរួមមាន ការបដិសេធយុត្តិធម៌ផ្នែកនីតិវិធីចំពោះអ្នកដាក់ពាក្យសុំដែលបានត្រូវបានបដិសេធក្នុងដីការបស់ ស.ច.ស លើកទីមួយសម្រេចបដិសេធដើមបណ្តឹងរដ្ឋប្បវេណីជាជនជាតិវៀតណាម ការពិតដែលថាជនរងគ្រោះទាំងនេះ ដែលជាអ្នក

រស់រានមានជីវិតពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍លើជនជាតិវៀតណាមដែលមានអត្តសញ្ញាណជាជនជាតិភាគតិចវៀតណាមនៅ អ.វ.ត.ក ត្រូវបានបដិសេធដោយតុលាការនេះម្តងហើយម្តងទៀត និងតម្រូវការឲ្យ អ.វ.ត.ក មានធម្មានុរូបនៅចំពោះមុខជនរងគ្រោះ និងពិភពលោកទាំងមូល។

១៥៧. សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីស្នើឲ្យចៅក្រម អ.ប.ជ ទទួលស្គាល់ថា អ្នកដាក់ពាក្យសុំគ្រប់រូបទាំងនេះគឺជាក្រុមជនរងគ្រោះផ្ទាល់នៃឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ប្រឆាំងនឹងប្រជាជនវៀតណាម និងផ្តល់ឲ្យអ្នកដាក់ពាក្យសុំជាជនជាតិវៀតណាម *ទាំងអស់នេះ* ពីខេត្តកំពង់ឆ្នាំងនូវឋានៈជាដើមបណ្តឹងរដ្ឋប្បវេណី *ស្របតាមសិទ្ធិក្នុងវិធានផ្ទៃក្នុង*។

១៥៨. ផ្អែកតាមហេតុផលដែលបានលើកឡើងខាងលើ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ស្នើសុំចៅក្រម អ.ប.ជ ច្រានចោលដីកាសម្រេចដែលបានធ្វើលើកមុន ហើយទទួលយកអ្នកដាក់ពាក្យសុំ D22/125, D22/171, D22/276, D22/172, D22/277, D22/278, D22/279, D22/280, D22/281, D22/205, D22/282, D22/283, D22/284, D22/285 និង D22/286 (ពីដីការបស់ ស.ច.ស លើកទីមួយសម្រេចបដិសេធដើមបណ្តឹងរដ្ឋប្បវេណីជាជនជាតិវៀតណាម) និងអ្នកដាក់ពាក្យសុំ D22/1901, D22/3180, D22/3183, D22/2057, D22/2154, D22/438, D22/3179, D22/3182, D22/816, D22/3177, D22/2157, D22/3181, D22/817, D22/2155, D22/2153, D22/404, D22/2156, D22/1136, D22/1969, D22/3175, D22/3176, D22/3178, D22/2158, និង D22/1092 ដោយសារថាអ្នកដាក់ពាក្យសុំនីមួយៗ បានរងព្យសនកម្មផ្ទាល់ និងជាលក្ខណៈបុគ្គល *ជាជនរងគ្រោះផ្ទាល់* ដែលព្យសនកម្មទាំងនេះអាចមានទំនាក់ទំនងផ្ទាល់ជាមួយនឹងអង្គហេតុស្ថិតក្នុងកិច្ចស៊ើបសួរ រួមទាំងការនិរទេសដោយបង្ខំ ឆ្លងកាត់ខេត្តព្រៃវែងទៅកាន់ប្រទេសវៀតណាម។

## VIII. សេចក្តីសន្និដ្ឋាន

១៥៩. មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីសន្និដ្ឋានថា ដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត មានការភ័ន្តច្រឡំលើអង្គហេតុ និងអង្គច្បាប់ នៅពេលពួកគាត់បានបដិសេធពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី D22/1901, D22/3180, D22/3183, D22/2057, D22/2154, D22/438, D22/3179, D22/3182, D22/816, D22/3177, D22/2157, D22/3181, D22/817,

D22/2155, D22/2153, D22/404, D22/2156, D22/1136, D22/1969, D22/3175, D22/3176, D22/3178, D22/2158, និង D22/1092 ដោយសារថា "ព្យសនកម្មពុំមានទំនាក់ទំនងនឹងអង្គហេតុស្ថិតក្រោមកិច្ចស៊ើបអង្កេត (នៅក្រៅវិសាលភាពភូមិសាស្ត្រ/ការធ្វើទុក្ខបុកម្នេញលើប្រជាជនវៀតណាម" ហើយពួកគាត់មានការភ័ន្តច្រឡំលើអង្គហេតុ និងអង្គច្បាប់ នៅពេលពួកគេបដិសេធអ្នកដាក់ពាក្យសុំ D22/2758 ដោយសារ "ព្យសនកម្មពុំមានទំនាក់ទំនងជាមួយនឹងអង្គហេតុស្ថិតក្រោមកិច្ចស៊ើបសួរ"។

១៦០. សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីសូមស្នើដោយគោរពដល់ អ.ប.ជ ឱ្យ៖

(i) ប្រកាសទទួលយកបណ្តឹងឧទ្ធរណ៍។

(ii) ច្រានចោលសេចក្តីសម្រេចរបស់ ស.ច.ស ដែលប្រកាសមិនទទួលយកពាក្យសុំទាំង ២៥ នាក់ ក្នុងបញ្ជីឈ្មោះខាងលើ។

(iii) ពិចារណាឯកសារគាំទ្រ ដែលបានដាក់នៅក្នុងឧបសម្ព័ន្ធ ក ឧបសម្ព័ន្ធ ខ និងឧបសម្ព័ន្ធ គ រួមទាំងកំណត់ហេតុនៃការស្តាប់ចម្លើយរបស់ ក.ស.ច.ស ជាមួយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលជាជនជាតិភាគតិចវៀតណាមក្នុងខេត្តកំពង់ឆ្នាំង។

(iv) ពិចារណាឡើងវិញពីភាពទទួលយកបាននៃអ្នកដាក់ពាក្យសុំខាងក្រោម ដែលរងផលប៉ះពាល់ដោយដីការបស់ ស.ច.ស លើកទីមួយសម្រេចបដិសេធដើមបណ្តឹងរដ្ឋប្បវេណីជាជនជាតិវៀតណាម និងដីកាសម្រេចក្រោយមកទៀតរបស់ អ.ប.ជ : D22/125, D22/171, D22/276, D22/172, D22/277, D22/278, D22/279, D22/280, D22/281, D22/205, D22/282, D22/283, D22/284, D22/285 និង D22/286, និង

(v) ផ្តល់ឱ្យម្ចាស់ដើមបណ្តឹងឧទ្ធរណ៍ទាំង៤០ នាក់ នូវឋានៈជាដើមបណ្តឹងរដ្ឋប្បវេណី។

សូមដាក់ជូនបណ្តឹងឧទ្ធរណ៍នេះដោយគោរពពី ៖

| | |
|---|---|
| លោក ទី ថាន់ឌី | លោកស្រី Lyma NGUYEN |
| សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីជាតិ | សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីអន្តរជាតិ |

002/19-09-2007-អ.វ.ត.ក/ក.ស.ច.ស(អបជ)

បានចុះហត្ថលេខានៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១០។